# ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩

## ក្រសួងសន្តិសុខសាធារណៈចិនចុះ MOU ប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមមធ្យោបាយទូរគមនាគមន៍

http://www.rasmeinews.com/ March 31, 2019, 10:12 AM

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ សម្តេចក្រឡាហោមសខេងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃអញ្ជើញបំពេញទស្សនកិច្ចផ្លូវការចាប់ពីថ្ងៃទី២៧ ដល់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩ នៅរដ្ឋធានីប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន។ ដើម្បីអញ្ជើញចូលរួមកិច្ចប្រជុំទ្វេភាគី និងធ្វើជាសហអធិបតីជាមួយលោកចាវយើជឺសមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈក្នុងពិធីបើកជាផ្លូវការឆ្នាំសហប្រតិបត្តិការអនុវត្តច្បាប់កម្ពុជាចិនឆ្នាំ២០១៩។

កម្មវិធីខាងលើ ត្រូវបានប្រារព្ធឡើងបន្ទាប់ពីជំនួបរវាងសម្តេចតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងលោកស៊ីជីងពីងប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិនកាលពីខែមករា ឆ្នាំ២០១៩។ បើកថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានព្រមព្រៀងកំណត់យកឆ្នាំ២០១៩ ជាឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងកម្ពុជា។ ក្នុងគោលបំណងធ្វើឲ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ ជាពិសេសការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត អំពើភេរវកម្ម ការជួញដូរមនុស្ស ការប្រយុទ្ធប្រឆាំងគ្រឿងញៀននិងការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។ល។

សម្តេចក្រឡាហោម ស ខេង និងលោក ចាវ យើជឺ បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើររវាងកងកម្លាំងអនុវត្តច្បាប់ នៃប្រទេសទាំងពីរក្នុងរយៈពេលកន្លងមកដែលបានខិតខំបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ឈរលើគោលការណ៍គោរពអធិបតេយ្យស្របតាមច្បាប់នៃប្រទេសរៀងៗ ខ្លួននិងមិត្តភាពជាភាតរៈរវាងប្រទេសទាំងពីរ។ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនេះភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការសំខាន់សំខាន់ចំនួន៣រួមមានៈ

1-អនុស្សារណៈ នៃការយោគយល់គ្នាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមមធ្យោបាយទូរគមនាគមន៍។

2-ផែនការសកម្មភាពសម្រាប់អនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខសាធារណៈ៥ឆ្នាំបន្ត(2019-2024)។

3-ផែនការការងារសម្រាប់ឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ឆ្នាំ2019 រវាងក្រសួងមហាផ្ទៃ និងក្រសួងសន្តិសុខសាធារណៈ។

ក្រៅពីជំនួបពិភាក្សាការងារជាមួយក្រសួងសន្តិសុខសាធារណៈ សម្តេចក្រឡាហោម ស ខេង ក៏បានជួបជាមួយលោក ហ្គ័រ សាំងយុន សម្រេចចិត្តការិយាល័យនយោបាយមជ្ឈឹមបក្សនិងជាលេខាគណៈកម្មាធិការកណ្តាលកិច្ចការនយោបាយ និងច្បាប់នៃបក្សកុម្មុយនីស្តចិន។

លោក ឆោម វិនឈីង សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិនៃសាធារណរដ្ឋប្រជាមានិតចិន ដោយបានជជែកពិភាក្សាលើកិច្ចការមួយចំនួនរួមមានការផ្លាស់ប្តូរពុទ្ធភូមិជកបទពិសោធន៍ការងារការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កងកម្លាំងអនុវត្តច្បាប់ និងការវាយតម្លៃការអនុវត្តអនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងទាំងពីរ។ ៕S/

# ស្នើមន្ត្រីគ្រប់ជាន់ថ្នាក់ ចូលរួមប្រយុទ្ធប្រឆាំង អំពើរជួញដូរ មនុស្សគ្រប់រូបភាព តាមភារកិច្ច មុខសញ្ញា និង ឆន្ទៈរៀងៗខ្លួន

http://www.cen.com.kh/archives/ March 29, 2019

សៀមរាប ៖ ដើម្បីទប់ស្កាត់ការការជួញដូរមនុស្ស និង អំពើកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារតាមគ្រប់រូបភាព មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ បានស្នើឲ្យមន្ត្រីគ្រប់ជាន់ថ្នាក់ ចូលរួមប្រយុទ្ធប្រឆាំង អំពើរជួញដូរ មនុស្សគ្រប់រូបភាព តាមភារកិច្ចមុខសញ្ញា និងឆន្ទៈរៀងៗខ្លួន និងឆ្លើយតប ទៅនឹងការជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

ឆ្លងតាមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់គណៈកម្មាធិការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាបអស់រយៈពេលមួយព្រឹកពេញ ក្រោមអធិបតីភាពលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធាន អចិន្ត្រៃយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំសាលាខេត្តសៀមរាប នាព្រឹកថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១៩នេះ ។

ឆ្លងតាមការធ្វើនូវបទអន្តរាគមន៍របស់ក្រុមការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ស្រុកវ៉ារិន ស្រុកក្រឡាញ់ និង ស្រុកស្រីស្នំ ព្រមទាំងលើកជាសំណួរ និង ការឆ្លើយតបទៅបញ្ហាមួយចំនួន ដែលអង្គប្រជុំលើកឡើង ធ្វើឲ្យកិច្ចប្រជុំកំណត់បាន នូវបញ្ហាប្រឈម និង ទិសដៅសម្រាប់អនុវត្តបន្ត ក៏ដូចឆ្នាំបន្តបន្ទាប់រួចមក លោកស្រី យូ សុភា អភិបាលរងខេត្ត និង ជាប្រធានលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានធ្វើការបូកសរុបលទ្ធផលនៃកិច្ចប្រជុំ ដោយបានផ្តោតទៅលើលទ្ធផលដែលអនុវត្តបាន យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស ការការពារ ស្តារនីតិសម្បទា សមារណកម្ម និង មាតុភូមិនិវត្តន៍ ការងារកិច្ចយុត្តិធម៌ និង កិច្ចសហប្រតិបត្តិការ ព្រមទាំងការងារបណ្តុះបណ្តាល លើកកម្ពស់សមត្ថភាពទៀតផង ។

មានប្រសាសន៍នោះលោកស្រី ជូ ប៊ុនអេង ក៏បានបញ្ជាក់គោលបំណង និង ការបង្ហាញអំពីឆន្ទៈមុះ មុតរបស់រាជ រដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោសជនល្មើស និង ការជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និង បំផុសការយល់ដឹង ការប្រុងស្មារតី និង ធ្វើសកម្មភាពប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សគ្រប់រូបភាព ។ លោកស្រី ក៏បានបន្តទៀតថា ដើម្បីទប់ស្កាត់ការការជួញដូរមនុស្ស និង អំពើកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និង កុមារតាមគ្រប់រូបភាព សំខាន់តាមទីកន្លែងណាដែលងាយរងគ្រោះ តាមតួនាទី ភារកិច្ច លទ្ធភាព សមត្ថភាព ការសហការ និង រួមចំណែកដោយឆន្ទៈនិងមនសិការ ព្រមទាំងធ្វើការពង្រីកការយល់ដឹង និង ទទួលបានព័ត៌មានពាក់ព័ន្ធ និង វិសាលភាពនៃបទល្មើសជួញដូរមនុស្ស និង កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និង ដៃគូរពាក់ព័ន្ធ ក្នុងការឆ្លើយតប និង ការចូលរួមទាំងអស់គ្នា ព្រមទាំងត្រូវ មានការប្រុងប្រយ័ត្ន នូវគ្រប់ល្បិចកលជនល្មើស និង ត្រៀមខ្លួនឲ្យបានល្អ ក្នុងការចូលរួមប្រយុទ្ធប្រឆាំង អំពើរជួញដូរ មនុស្សគ្រប់រូបភាព តាមភារកិច្ចមុខសញ្ញា និង ឆន្ទៈរៀងៗខ្លួន និង ជម្រុញធ្វើសកម្មភាពប្រកបដោយឆន្ទៈ ឆ្លើយតប ទៅនឹងការជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ។

លោកស្រី ជូ ប៊ុនអេង ក៏បានបញ្ជាក់ផងដែរ តាមរយៈនៃការបង្ហាញរបាយការណ៍របស់ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ព្រមទាំងបទអន្តរាគមន៍តាមបណ្តាស្រុក គឺបានបង្ហាញអំពីលទ្ធផលការ ងារប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ ការឆ្លុះបញ្ចាំងនូវបទពិសោធន៍ បញ្ហាប្រឈម ការផ្តល់យោបល់អនុសាសន៍របស់ក្រុមការងារថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និង អ្នកពាក់ព័ន្ធផងដែរ ។ ក្នុងនោះលោកជំទាវក៏បានលើផងដែរ ពីទុក្ខ សោករបស់ពលរដ្ឋខ្មែរយើងដែលរងគ្រោះ ដោយការជួញដូរមនុស្សទៅក្រៅប្រទេស ដោយការប្រថុយប្រថាន ក្នុងការចាញ់បោកមេខ្យល់ ដែលជាបទពិសោធន៍ សម្រាប់បងប្អូនប្រជាពលរដ្ឋ និង បានយល់ជ្រួតជ្រាប ពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្ម និង ផ្លូវភេទ ដែលជាមិនមែនជារឿងបុគ្គលណាម្នាក់ គឺជាភារកិច្ចយើងទាំងអស់គ្នាត្រូវធ្វើការចូលរួម ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និង អំពើកេងប្រវ័ញ្ចផ្លូវ

ភេទលើស្ត្រី និង កុមារ ទៅតាមគ្រប់រូបភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល (ធ្វើការក្នុងស្រុកក៏ល្អប្រសើ បើចេញទៅធ្វើការនៅក្រៅប្រទេសត្រូវមានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ) ។

លោកស្រី ជូ ប៊ុនអេង ក៏មានសង្ឃឹមជឿជាក់ថា ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ខេត្តសៀមរាបពិតនឹងទទួលបាននូវជ័យលាភីប្រចាំឆ្នាំ ព្រមទាំងបានផ្តល់នូវអនុសាសន៍ និង បទពិសោធន៍ល្អៗ ព្រមទាំងវិធានការមួយចំនួន សម្រាប់មន្ត្រីអនុវត្តច្បាប់នៅថ្នាក់ក្រោមជាតិ ជាយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅតាមមូលដ្ឋាន ឲ្យទទួលបានជោគជ័យ ៕ ដោយៈកូឡាប

## ជនជាតិម៉ាឡេស៊ី២នាក់ប្តីប្រពន្ធត្រូវជាប់អន្ទាក់សមត្ថកិច្ច

http://ppd-news.net/ Phnom Penh Daily 29-03-2019

ខេត្តកំពង់ធំ៖ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ដោយមានការបញ្ជាអោយឃាត់ខ្លួនរបស់លោក អ៊ិត សុជា ព្រះរាជអាជ្ញាខេត្តកំពង់ធំថ្ងៃទី28 ខែមិនា ឆ្នាំ2019 វេលាម៉ោង17.30នាទីនៅការិយាល័យប្រឆាំងការជួញដូរមនុស្សបានធ្វើការឃាត់ខ្លួនជនជាតិម៉ាឡេស៊ី02នាក់ជាប្តី និងប្រពន្ធករណីកេងប្រវ័ញ្ចកម្លាំងពលកម្មនៅប្រទេសម៉ាឡេស៊ីរយៈពេល12ឆ្នាំ។ យោងពាក្យបណ្តឹងរបស់ជនរងគ្រោះឈ្មោះ ស្វាយ គុ ហៅជន សារាយ នៅភូមិឬស្សីឃុំទំរីងស្រុកសណ្តាន់ខេត្តកំពង់ធំ មុខរបរបំរើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី បានប្តឹងឈ្មោះWoo CHong keongភេទប្រុសអាយុ47ឆ្នាំកាន់លិខិតឆ្លងដែនA 347627700ចុះថ្ងៃទី25 ខែកុម្ភះ ឆ្នាំ2015 និងប្រពន្ធឈ្មោះLee See Yeeអាយុ42ឆ្នាំ កាន់លិខិតឆ្លងដែនA38935264ចុះថ្ងៃទី29 កញ្ញា ឆ្នាំ2019ទីលំនៅប្រទេសម៉ាឡេស៊ី ជនសង្ស័យជាជនជាតិម៉ាឡេស៊ី បាននាំជនរងគ្រោះមកលេងផ្ទះដោយជនសង្ស័យស្នាក់នៅសណ្ឋាគារអារុណរះ ក្រុងស្ទឹងសែន, ខេត្តកំពង់ធំ ចាប់ពីថ្ងៃទី26 ខែមិនា ហើយអោយជនរងគ្រោះលួងលោមប្អូនស្រីរបស់ខ្លួនទៅធ្វើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ីដែរ។ ជនសង្ស័យត្រូវបានឃាត់ខ្លួនចងក្រងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តដើម្បីចាត់ការតាមផ្លូវច្បាប់៕ដោយៈដឹម ទូច

## ពលរដ្ឋខ្មែរ០២នាក់ ត្រូវបានថៃបញ្ជូនត្រឡប់មកវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration – GDI 29-03-2019

ឧត្តរមានជ័យ៖ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ខាងភាគីថៃ បានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកកម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកវាលស្បូវ ខេត្តព្រះវិហារ៕

## ថៃបញ្ជូនពលករខ្មែរ ០៣នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI March 30 at 10:47 AM

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៨និង០០នាទី ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់ ស្រី ០១នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

ថ្ងៃសុក្រ ៩រោច ខែផល្គុន ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករ និងចំនួនថ្ងៃដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជក/ថៅកែ។

ឆ្លៀតឱកាសនេះផងដែរ មន្ត្រីស្ថានទូតបានពន្យល់ណែនាំដល់បងប្អូនប្រជាពលរដ្ឋខ្មែរយើងយ៉ាងក្បោះក្បាយអំពីលិខិតស្នាមផ្សេងៗដែលចេញដោយស្ថានទូតក្នុងការយកទៅប្រើប្រាស់អោយមានការយល់ច្បាស់ និងអំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយ ក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗ ដែលកំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ ដែលមករកសេវាពីស្ថានទូត ហើយក៏បានចែកនំចំណីដល់កូនៗរបស់បងប្អូន។

ក្នុងបរិបទខាងលើនេះ ពិតជាបានឆ្លុះបញ្ចាំងថា មានបរិយាសកាស ស្និទ្ធិស្នាល សប្បាយរីករាយ បញ្ជាក់ដោយស្នាមញញឹម ពិតជាចេញវាចាផ្ទាល់មាត់ របស់បងប្អូន នូវការថ្លែងអំណរគុណដល់ស្ថានទូត តែងតែយកចិត្តទុកដាក់ជួយសម្រួលឯកសារជូនពួកគាត់។

## ជប៉ុនចេញច្បាប់អន្តោប្រវេសន៍ថ្មីបើកដៃឱ្យ១ទំហឹង

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ១៥:១៦ ណៃ ដាលីន

ប្រទេសជប៉ុន៖ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ វិសោធនកម្មថ្មីលើច្បាប់ស្តីពីការធ្វើអន្តោប្រវេសន៍នឹងចាប់ចូលជាធរមានដែលអនុញ្ញាតឲ្យមានចេញជាទិដ្ឋាការសម្រាប់ពលករមានជំនាញច្បាស់លាស់មួយចំនួន។ ប្រភេទទិដ្ឋាការថ្មីនេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាកង្វះពលករក្នុងស្រុកខណៈដែលចំនួនប្រជាជនសរុបក្នុងប្រទេសកំពុងតែធ្លាក់ចុះ។ ប្រសិនបើមានប្រសិទ្ធិភាព វាអាចបង្កឲ្យមានលំហូរចូលនៃពលករបរទេសក្នុងប្រទេសជប៉ុនដែលនឹងត្រូវការផ្ទះនិងសេវាកម្មផ្សេងៗ។

វិធានការថ្មីនេះមានគោលដៅនាំយកជនអន្តោប្រវេសន៍ប្រមាណ៣៤៥,០០០នាក់ចូលមកកាន់ប្រទេសជប៉ុនក្នុងកំឡុងពេល៥ឆ្នាំខាងមុខនេះ។ គោលដៅសម្រាប់ឆ្នាំទីមួយគឺប្រមាណ ៤៧,៥៥០នាក់។ ទិដ្ឋាការប្រភេទថ្មីនេះមានភាពខុសគ្នាពីកម្មវិធីហ្វឹកហាត់អ្នកហាត់ការបច្ចេកទេសដែលទទួលបានការរិះគន់យ៉ាងខ្លាំងព្រោះពលករបរទេសត្រូវបានចាត់ទុកជាបុគ្គលិកធម្មតា និងអាចទទួលបានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ទៀតផង។

យោងទៅតាមលោក Shotaro Tanaka ដែលជាភ្នាក់ងារលក់អចលនទ្រព្យមួយរូបនៅ Apts.jp ដែលជាក្រុមហ៊ុនផ្តល់សេវាស្នាក់នៅដល់ជនបរទេសក្នុងប្រទេសជប៉ុនបានឲ្យដឹងថា ការផ្លាស់ប្តូរនេះអាចនឹងបង្កឥទ្ធិពលយ៉ាងខ្លាំងសម្រាប់តំបន់ជាយទីក្រុងធំៗ។ លោកបាននិយាយថា «អ្នកដែលធ្វើការក្នុងវិស័យមួយចំនួនដូចជាការងាររោងចក្រ សាងសង់ និងកសិកម្មនឹងត្រូវការកន្លែងស្នាក់នៅក្នុងតំបន់ជាយទីក្រុង ឬនៅជនបទ។ ជាទូទៅមានភ្នាក់ងារអចលនទ្រព្យដែលចេះនិយាយភាសាអង់គ្លេសតិចណាស់ក្នុងតំបន់ទាំងនេះ ហើយម្ចាស់ផ្ទះក្នុងតំបន់អាចនឹងមិនស្វាគមន៍អ្នកជួលជាជនបរទេសផងដែរ ប៉ុន្តែមានអង្គការមួយចំនួនកំពុងតែព្យាយាមសម្របទៅតាមតម្រូវការទីផ្សារហើយ»។ ដូច្នេះអ្នកដែលអាចទទួលបានអត្ថប្រយោជន៍ច្រើនជាងគេអាចជាក្រុមហ៊ុនផ្តល់សេវាស្នាក់នៅដូចជា Village House ដែលជាក្រុមហ៊ុនបង្កើតឡើងដោយក្រុមវិនិយោគអាមេរិកក្រោម Softbank Group ៕

## សកម្មជនស្វាគមន៍ដោយប្រុងប្រយ័ត្នចំពោះកិច្ចព្រមព្រៀងជប៉ុននិងកម្ពុជាលើពលករចំណាកស្រុក

https://khmer.voanews.com/ 29 មិនា 2019 ម៉ែន គឹមសេង

រដ្ឋាភិបាលកម្ពុជានិងជប៉ុនបានព្រមព្រៀងគ្នា ដើម្បីទទួលពលករជំនាញកម្ពុជាចាប់ពី ខែមេសាទៅដែលជាការអនុញ្ញាតជាលើកដំបូងសម្រាប់កម្ពុជា និងប្រទេសនៅអាស៊ីចំនួន ៨ទៀត ហើយមានការធានាថា នឹងទប់ស្កាត់ក្រុមហ៊ុនជ្រើសរើសពលករ ដែលមិនសុច្ចរិតផងដែរ។ សកម្មជនសហគមន៍ គឺលោក ហៃ វណ្ណា ដែលរស់នៅក្នុងប្រទេសជប៉ុន បានស្វាគមន៍ ប៉ុន្តែយល់ថា គេត្រូវតាមដានមើលតទៅទៀតរវាងការអនុវត្តជាក់ស្តែង និងការព្រមព្រៀង ដែលសម្រេចបានកាលពីដើមសប្តាហ៍នេះ។ លោកបារម្ភតិចតួចចំពោះក្រុមហ៊ុនជប៉ុន ប៉ុន្តែព្រួយបារម្ភពីការបន្តកេងប្រវ័ញ្ចដោយក្រុមហ៊ុនជ្រើសរើសពលករនៅកម្ពុជា។ កញ្ញា ឆែម ស្រីពៅ ជាកម្មសិក្សាការីមួយរូបក៏ស្នើឲ្យបន្ថយកម្រៃឈ្នួលសម្រាប់ជ្រើសរើសពលករដែលបច្ចុប្បន្នមានតម្លៃខ្ពស់៕

## បញ្ចប់វិវាទរវាងពលករខ្មែរធ្វើការក្នុងរោងចក្រក្នុងខេត្តឈុនបុរី ដែលត្រូវរោងចក្របញ្ឈប់ពីការងារនិងមិនបើកប្រាក់ឈ្នួល

https://www.facebook.com/OfficialPheaktra/ ពលករកម្ពុជាបំរើការងារក្នុងប្រទេសថៃ 31-03-2019

ប្រទេសថៃ៖ នៅរសៀលថ្ងៃអាទិត្យទី31 ខែមីនា ឆ្នាំ2019នេះ មន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ តំណាងអោយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះបញ្ចប់រឿងវិវាទរវាងពលករខ្មែរជាង៥០នាក់ធ្វើការក្នុងរោងចក្រមួយក្នុងតំបន់អាំម៉ាតាក់ណាខនឈុនបុរី បន្ទាប់ពីត្រូវរោងចក្របានបញ្ឈប់ពីការងារដោយមិនបើកប្រាក់ឈ្នួល និងប្រាក់មួយចំនួនទៀតដែលកាត់ពីពួកគាត់ថ្លៃដំណើរការនិតិវិធីស្របច្បាប់។ បន្ទាប់ពីការចរាចរគ្នារវាងភាគីរោងចក្រនិងមន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេស អស់រយៈពេលជាងពីរសប្តាហ៍ ខាងភាគីរោងចក្របានយល់ព្រមបើកប្រាក់ខែ និងប្រាក់ផ្សេងៗដែលកាត់ពីពួកគាត់ នៅដោយសន្យាប្រគល់ថវិកាជាកញ្ចប់តាមកិច្ចសន្យានៅក្នុងថ្ងៃអាទិត្យទី31 ខែមីនា ឆ្នាំ2019នេះ លុះដល់ថ្ងៃកំណត់ភាគីរោងចក្របាននាំយកថវិកាតាមចំនួនចរាចរមកប្រគល់ជូនតំណាងពលករខ្មែរ ដោយមានមន្ត្រីទីប្រឹក្សាពលករចូលរួមសង្កេតការណ៍នៅអធិការដ្ឋានតម្រួតជនហ្បូឡស្លិតក្នុងស្រុកមឿង ឈុនបុរី ។

ក្រោយពីទទួលបានថវិកាតាមចំនួនកំណត់តំណាងពលករខ្មែរបាននាំយកថវិកាទាំងនោះទៅបែងចែកជូនពលករខ្មែរទាំងជាង៥០នាក់ ដោយម្នាក់ៗទទួលបានថវិកាតាមចំនួនដែលចរចារគ្នា។ លើសពីនេះពលករខ្មែរទាំងអស់សូមថ្លែងអំណរគុណដល់មន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ តំណាងអោយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ ដែលចុះមកដោះស្រាយបញ្ហាជូនពលករទាំងអស់តាំងដើមរហូតដល់ចប់ទទួលបានប្រាក់សំណងគ្រប់ៗគ្នា។

# ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩

## ក្រសួងសង្គមកិច្ច៖ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅរួម និងបានខិតខំគ្រប់ផ្នែក និងគ្រប់វិស័យពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់

http://www.freshnewsasia.com/index.php/ 2019-04-02

**(ភ្នំពេញ)៖** អំពើជួញដូរមនុស្ស ជាបញ្ហាស្មុគស្មាញ និងជាអំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលកំពុងតែមានស្ទើគ្រប់ប្រទេស នៅលើសាកលលោក។ រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅរួម និងបានខិតខំគ្រប់ផ្នែក និងគ្រប់វិស័យពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់។ យើងត្រូវធ្វើផែនការអនុវត្តឲ្យបានច្បាស់

លាស់ ដោយគ្រោងថវិកា សំភារៈ មធ្យោបាយគ្រប់គ្រាន់ ក្នុងការអនុវត្តភារកិច្ចទៅតាមផែនការ និងជំនាញរបស់នាយកដ្ឋាន ដោយពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយអង្គការដៃគូពាក់ព័ន្ធ ក្នុងការផ្តល់សេវាជូនដល់ជនរងគ្រោះ និងដោះស្រាយឲ្យទាន់ពេលវេលា ជូនជនរងគ្រោះ។ នេះជាការលើកឡើងរបស់ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្រ្តីក្រសួងសង្គមកិច្ច នៅក្នុងកិច្ចប្រជុំស្តីពី ការពិនិត្យ និងតាមដានធនុវត្តការងារកន្លងមក។ កិច្ចប្រជុំនេះ រៀបចំធ្វើនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសង្គមកិច្ច។ បន្ថែមពីលើនេះ លោក ញឹក វណ្ណារ៉ា បានឲ្យដឹងថា នៅតាមក្រសួងស្ថាប័ន និងអង្គការ មិនមែនរដ្ឋាភិបាល ដែលជាអនុប្រធាន សមាជិក នៃក្រុមការងារការពារជនរងគ្រោះដោយអំពើហិង្សា ជួញដូរមនុស្ស បានអនុវត្តសកម្មភាពជាច្រើន ពិសេសនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមារណកម្មជនរងគ្រោះ គឺជាការងារស្នូលរបស់នាយកដ្ឋាននេះ។

កិច្ចប្រជុំនាពេលនេះ មានគោលបំណងពង្រីក និងលើកកម្ពស់ប្រសិទ្ធភាពការការពារ និងជួយជនរងគ្រោះគ្រប់រូបភាព ការអនុវត្តច្បាប់ ការផ្តន្ទាទោស ជនល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រកបដោយភាពអយុត្តិធម៌ និងការផ្តល់សេវា ដែលមានគុណភាព និងសមស្រប ក្នុងគោលដៅរួមដើម្បីដោះស្រាយ និងលុបបំបាត់ទម្រង់នៃអំពើជួញដូរមនុស្ស ព្រមទាំងអំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើគេងប្រវ័ញ្ចគ្រប់រូបភាប ដែលកើតមាននៅក្នុងប្រទេសកម្ពុជា។ លោក ញឹក វណ្ណារ៉ា សង្ឃឹមថា លិខិតបទដ្ឋានគត្តិយុត្តិជាតិ អន្តរជាតិ ត្រូវបាន និងកំពុងអនុវត្តយ៉ាងសកម្ម និងប្រសិទ្ធភាពត្រូវតែបន្តឲ្យបានទូលំទូលាយ សម្រាប់ជាឧត្តមប្រយោជន៍ជួយដល់ជនរងគ្រោះ។

គួរបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មការជួញដូរមនុស្ស បានបែងចែកក្រុមការងារអន្តរក្រសួងស្ថាប័នចំនួន០៦ ក្នុងនោះក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារការពារជនរងគ្រោះ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥។ វិស័យសង្គមកិច្ច មានច្បាប់គោលនយោបាយ បទដ្ឋានគតិយុទ្ធជាច្រើនសម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះ ដូចជា ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួស ចំពោះកុមារ និងបទដ្ឋានការថែទាំ ជនរងគ្រោះដោយអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅមណ្ឌល និងមានឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ៕

## ស្នងការនគរបាលខេត្តបន្ទាយមានជ័យរំលឹកដល់កម្លាំងវរៈសេនាតូចការពារព្រំដែនទាំង៤ ត្រូវការពារបូរណភាពទឹកដីឱ្យបានល្អ

http://cambodiapolice.com/policekh/ 9:38 pm 1 មេសា 2019

ខេត្តបន្ទាយមានជ័យ៖ ថ្លែងក្នុងឱកាសសាកសួរសុខទុក្ខ និងនាំយកអំណោយរបស់អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន ផ្តល់ជូនអង្គភាពវរៈសេនាតូចនគរបាលការពារព្រំដែន គោកទាំង៤ អង្គភាពវរៈសេនាតូច៨១៥ វរៈសេនាតូច៨៩១ អង្គភាពវរៈសេនាតូច៩១១ និងអង្គភាពវរៈសេ សេនាតូច៨០៧ ដែលជាកងកម្លាំងជួរមុខមានតួនាទីភារកិច្ចការពារបូរណភាពទឹកដីកម្ពុជា នៅក្នុងភូមិ សាស្រ្តខេត្តបន្ទាយមានជ័យប្រឈមនិងប្រទេសថៃ។ ពិធីនេះបានប្រព្រឹត្តធ្វើឡើងនៅព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ នៅអង្គភាពវរៈសេនាតូចលេខ ៨១៥។

លោកឧត្តមសេនីយ៍ទោ អាត់ ខែម តំណាងដ៏ខ្ពង់ខ្ពស់ អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានរំលឹកដល់កងកម្លាំងអង្គភាពវរសេនាតូចការពារព្រំដែនគោកទាំង៤ ត្រូវការ ពារបូរណភាពទឹកដីកម្ពុជាឱ្យបានគត់មុតនិងបំពេញតួនាទីប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះជាតិមាតុភូមិដោយទប់ស្កាត់

រាល់សកម្មភាពទាំងឡាយណាពីប្រទេសជិតខាងដែលមានគំនិតអាក្រក់ប៉ុនប៉ងចង់រំលោភយកទឹកដីកម្ពុជា។មិនតែប៉ុណ្ណោះកងកម្លាំងនគរបាលជាតិត្រូវប្រកាន់គោលជំហរច្បាស់លាស់ ស្មោះត្រង់ការពារ រដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រនិងការពាររាជរដ្ឋាភិបាលស្របច្បាប់។ ជុំវិញការងារការពារបូរណភាពទឹកដីនោះដែរស្នងការនគរបាលខេត្តបន្ទាយមានជ័យឧត្តមសេនីយ៍ទោ អាត់ ខែម ក៏បានជម្រុញឱ្យកម្លាំងនគរបាលការពារព្រំដែនគោកទាំង៤ ត្រូវបន្តយកចិត្តទុកដាក់ការដើរល្បាតត្រួតពិនិត្យតាម បន្ទាត់ព្រំដែនជាប្រចាំដើម្បីក្តាប់សភាពការណ៍ប្រែប្រួលនៅតាមបន្ទាត់ព្រំដែនក៏និងរក្សារៀបចំទុកដាក់ត្រួតពិនិត្យគ្រឿងសព្វាវុធក៏ដូចជាកសាងស្ថាលានដ្ឋានឱ្យបានល្អនិងរឹងមាំ។មិនតែប៉ុណ្ណោះត្រូវត្រៀមកម្លាំងប្រយុទ្ធជាប្រចាំដើម្បីដោះស្រាយសភាពការណ៍ដែលកើតឡើងដោយប្រការមួយនោះ។

លោកឧត្តមសេនីយ៍ស្នងការក៏បានណែនាំដល់អង្គភាពវរៈសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ ក៏បន្តសហការជាមួយអង្គភាពយោធានិងអាជ្ញាធរដែនដីឱ្យបានល្អ និងជាពិសេសបន្តកិច្ចសហប្រតិបត្តិការជាមួយភាគីថៃ ឈរលើស្មារតីយោគយល់គ្នា ដោយប្រែក្លាយតំបន់ព្រំដែនជាព្រំដែនសន្តិភាព និងការអភិវឌ្ឍន៍។ ស្នងការនគរបាលខេត្តបន្ទាយមានជ័យលោកឧត្តមសេនីយ៍ទោ អាត់ ខែម ក៏បានណែនាំដល់អង្គភាពវរៈសេនាតូចការពារព្រំដែនគោកទាំង៤ សម្រាប់ឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនៅពេលខាងមុខ ត្រូវសម្រួលដល់ការធ្វើដំណើររបស់ពលករខ្មែរធ្វើការងារនៅប្រទេសថៃឱ្យពួកគាត់ឆ្លងដែនចូលមកលេងស្រុកកំណើតឱ្យមានសុវត្ថិភាព និងកុំប៉ះពាល់យកលុយកាក់ពីពលករខ្មែរ។

លោកឧត្តមសេនីយ៍ទោ អាត់ ខែម ក៏បានលើកឡើងពាំនាំនូវការសាកសួរសុខទុក្ខក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរពីសំណាក់អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន តែងតែគិតគូយកចិត្តទុកដាក់ពីសុខទុក្ខជីវភាពរស់នៅរបស់កងកម្លាំងនគរបាលការពារព្រំដែនជួរមុខ ដែលបានលះបង់សព្វបែបយ៉ាងក្នុងបុព្វហេតុជាតិមាតុភូមិ។ អំណោយដែលផ្តល់ជូនទៅអង្គភាពវរៈសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤និងអធិការដ្ឋាននគរបាលស្រុកម៉ាឡៃរួមមានៈអង្ករ៦តោន ថវិកា៥លាន៣សែនរៀល, ត្រីខកេសធំ១៤កេស,មី១២កេសធំ,ទឹកត្រី២០យួរ,ទឹកស៊ីអ៊ីវ២០យួរ,ខ្ទឹមស១០គីឡូក្រាម,ប៊ីចេង១០គីឡូក្រាម,ស្ករស១០គីឡូក្រាម៕ សំ វិច្ឆិកា

## ថៃអនុញ្ញាតឲ្យខ្មែរទៅសួរសុខទុក្ខញាតិដែលជាប់គុកនៅថៃ ចុងខែមេសានេះ

https://www.postkhmer.com/ នៀម ឆេង | Publication date 01 April 2019 | 10:18 ICT

**ភ្នំពេញៈ** អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងស្តីពីការអនុញ្ញាតឲ្យសាច់ញាតិជនជាតិខ្មែរជួបសួរសុខទុក្ខ និងផ្ញើប្រាក់ជូនសាច់ញាតិដែលជាប់ឃុំ នៅពន្ធនាគារខ្លងព្រេម ក្នុងប្រទេស ថៃ។ យោងតាមឯកសារផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធនាគារដែលផ្សាយកាលពីថ្ងៃទី ២៩ មីនា បានបញ្ជាក់ថា ពន្ធនាគារខ្លងព្រេមរបស់ថៃ បានអនុញ្ញាតឲ្យសាច់ញាតិចូលសួរសុខទុក្ខអ្នកជាប់ឃុំនៅពន្ធនាគារនេះរយៈពេល ៤ ម៉ោងក្នុងរយៈពេល ២ ថ្ងៃគឺថ្ងៃទី ២៩ និង ៣០ ខែ មេសា នេះ។ ការចូលសួរសុខទុក្ខនេះអាចធ្វើឡើងចាប់ពីម៉ោង ៩ ព្រឹកដល់ម៉ោង ១ រសៀល ដោយសាច់ញាតិអាចជួបសួរសុខទុក្ខផ្ទាល់ មិនមានរបាំង។

យោងតាមឯកសារចេញពីពន្ធនាគារខ្លងព្រេមចុះថ្ងៃទី ៤ មករា ២០១៩ ដែលអគ្គនាយកដ្ឋានពន្ធនាគារបានបង្ហោះ ការអនុញ្ញាតឲ្យចូលសួរសុខទុក្ខនេះនឹងធ្វើឡើងចាប់ពីឆ្នាំ ២០១៩ នេះតទៅ ហើយការជួបនេះគឺបន្ថែមទៅលើការជួបសួរសុខទុក្ខធម្មតាដែលធ្វើឡើងរៀងរាល់ថ្ងៃធ្វើការ។ ពន្ធនាគារខ្លងព្រេមបញ្ជាក់ថា ការអនុញ្ញាតឲ្យជួបសួរសុខទុក្ខនេះ «អនុញ្ញាតឲ្យសាច់ញាតិសួរសុខទុក្ខអ្នកទោសបានយ៉ាងជិតស្និទ្ធក្នុងលក្ខណៈប៉ះគ្នាបាននៅក្នុងពន្ធនាគារដោយមិនមានអ្វីជាឧបសគ្គនៅក្នុងសន្ទនា និងមានការទទួលទានអាហាររួមគ្នា ដែលនឹងជួយពង្រឹងទំនាក់ទំនងដ៏ល្អនៅ ក្នុងក្រុមគ្រួសារ និងជាឧបករណ៍ដើម្បីលើកទឹកចិត្តអ្នកទោស (ឲ្យ) ប្រព្រឹត្តខ្លួនជាមនុស្សល្អ ប្រតិបត្តិខ្លួនឲ្យនៅតាមរបៀបវិន័យរបស់ពន្ធនាគារ»។ ការចូលសួរសុខទុក្ខត្រូវបានអនុញ្ញាតសម្រាប់សាច់ញាតិរហូតដល់ ១២ នាក់

ដោយចូលសួរសុខទុក្ខព្រមគ្នាតែម្តង។ ទោះយ៉ាងណាអ្នកចូលសួរសុខទុក្ខត្រូវដាក់ពាក្យស្នើសុំមុនដោយមានឯកសារដែលចាំបាច់។ ក្រៅពីការចូលសួរសុខទុក្ខរយៈពេលវែង និងដោយសាច់ញាតិច្រើននេះ ពន្ធនាគារក៏អនុញ្ញាតឲ្យសាច់ញាតិផ្ញើប្រាក់ទៅបងប្អូនដែលកំពុងជាប់ឃុំនៅពន្ធនាគារនេះដែរ ដោយត្រូវធ្វើឡើងតាមរយៈគណនីរបស់ធនាគារក្រុងថៃ (Krung Thai Bank) ដោយការផ្ញើប្រាក់តាមនេះមិនគិតសេវាទេ ប៉ុន្តែសាច់ញាតិត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើ «ប័ណ្ណប្រើប្រាស់សេវាកម្មផ្ញើប្រាក់ នៅពន្ធនាគារជាមុន។

លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងកាលពីម្សិលមិញថា លោកមិនមានតួលេខក្នុងដៃទេអំពីចំនួនជនជាតិខ្មែរដែលជាប់ឃុំនៅពន្ធនាគារនេះ ឬតួលេខដែលជាប់នៅទូទាំងប្រទេសថៃ ដោយសារលោកមានវត្តមាននៅក្រៅប្រទេស ហើយវាជាថ្ងៃអាទិត្យទៀត។

លោក នុត សាវនា អ្នកនាំពាក្យអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃថ្លែងថា លោកក៏មិនមានតួលេខផ្លូវការដែរ ប៉ុន្តែតាមលោកដឹងជនជាតិខ្មែរដែលកំពុងជាប់ឃុំនៅប្រទេសថៃមានមិនតិចជាង ៤ ពាន់នាក់ទេ៕

## ពលករថា ស្ថានទូតខ្មែរនៅទីក្រុងបាងកកបន្ថែមម៉ោងធ្វើការ ជាការដោះស្រាយមួយគ្រា បន្ទាប់ពីមានការរិះគន់ពីពលករ

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា 2019-04-01

ពលករខ្មែរធ្វើនៅប្រទេសថៃសាទរចំពោះវិធានការរបស់ស្ថានទូតខ្មែរនៅទីក្រុងបាងកក ដែលបានបន្ថែមម៉ោងធ្វើការរបស់ខ្លួន ដើម្បីជួយសម្រួលពលករបំពេញឯកសារបានឆាប់នោះ។ ក៏ប៉ុន្តែពួកគាត់ លើកឡើងថា វិធានការនេះគ្រាន់តែជាការបន្លំភ្នែករបស់មន្ត្រីទូតធ្វើឲ្យល្អមើលដើម្បីកែខ្លួន ដោយសារតែថ្មីៗ នេះពួកគាត់បានរិះគន់មន្ត្រីទូតមិនយកចិត្តទុកដាក់បំពេញការងារជូនពលករ។

ពលករខ្មែរនៅខេត្តសមុទ្រប្រាកាន (Samut Prakan) លោក វិន មករា ថ្លែងឲ្យដឹងនៅថ្ងៃទី៣១ មីនាថា ពួកគាត់នឹងតាមដានការងាររបស់មន្ត្រីស្ថានទូតបន្តទៀត ព្រោះជាទូទៅមន្ត្រីទូតខ្វះខ្នែងការងារជួលដល់ពលករនៅពេលដែលពួកគាត់ប្ដឹងតវ៉ា ប៉ុន្តែមួយរយៈក្រោយមកស្ថានភាពនៅដដែល៖ «នេះបើអាចទៅរួចសុំកុំយកលុយពីពលករខ្មែរនៅថៃ ព្រោះពលករមិនមែនមកកើបលុយទេ គឺធ្វើការលំបាកណាស់ទម្រាំបានលុយ ២០០បាតបង់ឲ្យទូតថ្លៃណាស់សម្រាប់ពលករ ព្រោះធ្វើការមួយថ្ងៃបានតែ ៣០០បាតទេ។ ដូច្នេះទូតគួរតែអាណិតដល់ពលករខ្មែរផង»។ ប្រតិកម្មរបស់ពលករខ្មែរនៅពេលនេះដោយសារកាលពីថ្ងៃទី២៧ មីនា មន្ត្រីស្ថានទូតបានចេញជូនដំណឹងបន្ថែមម៉ោងធ្វើការនៅថ្ងៃសៅ និងថ្ងៃអាទិត្យ ចាប់ពីថ្ងៃផ្សាយដំណឹងរហូតដល់ថ្ងៃទី១៣ មីនា ដើម្បីជួយបំពេញឯកសារជូនពលករបានត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរបានឆាប់រហ័ស។

ពលករខ្មែរធ្វើការនៅរ៉ាក់យ៉ង (Rayong) លោក ឡេង ឡុង លើកឡើងថា មន្ត្រីទូតគួរតែយកចិត្តទុកដាក់បំពេញការងារសម្រួលដល់ពលករឲ្យបានច្រើនបន្ថែមទៀត មិនមែនធ្វើការត្រឹមតែថ្ងៃបុណ្យចូលឆ្នាំខ្មែរមួយរយៈខ្លីប៉ុណ្ណោះទេ ព្រោះពួកគាត់ធ្វើការនៅប្រទេសថៃត្រូវការលិខិតបញ្ជាក់ពីស្ថានទូតញឹកញាប់ ជាពិសេស ពលករដែលមានកូនតូចយកទៅធ្វើការជាមួយ គឺលំបាកក្នុងការធ្វើលិខិតស្នាមពីទូតដោយត្រូវចំណាយពេលអស់ជាច្រើនថ្ងៃនោះ៕

## ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩

# មន្ត្រីសិទ្ធិមនុស្សជំរុញអាជ្ញាធរឱ្យជួយពលរដ្ឋខ្មែរ ១២នាក់ ដែលត្រូវថៃចាប់ខ្លួន សង្ស័យពាក់ព័ន្ធការកាប់ឈើប្រណិត

https://www.rfa.org/khmer/news/ ដោយ ហេង រស្មី 2019-04-02

អ្នកការពារសិទ្ធិមនុស្សជំរុញឱ្យអាជ្ញាធរកម្ពុជាប្រឹងប្រែងជួយដល់ពលរដ្ឋខ្មែរ ១២នាក់ ដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ដោយជាប់សង្ស័យថា ឆ្លងដែនចូលកាប់ឈើខុសច្បាប់នៅលើទឹកដីថៃ។ ពួកគេថ្លែងថា អន្តរាគមន៍បន្ទាន់ក្នុងករណីនេះ គឺការផ្តល់មេធាវី ដើម្បីផ្តល់សេវាផ្លូវច្បាប់ដល់ពលរដ្ឋទាំងនោះ។

អ្នកនាំពាក្យសមាគម អាដហុក លោក ស៊ឹង សែនករុណា ថ្លែងថា អាជ្ញាធរកម្ពុជាមានកាតព្វកិច្ចជួយដល់ប្រជាពលរដ្ឋរបស់ខ្លួន ដែលមានបញ្ហានៅក្រៅប្រទេស ទោះបីជាពួកគេបានប្រព្រឹត្តបទល្មើស ឬមិនបានប្រព្រឹត្តបទល្មើសក្តី។ លោកបន្តថា ករណីពលរដ្ឋខ្មែរជាង ១០នាក់ ដែលត្រូវបានចាប់ខ្លួននៅក្នុងប្រទេសថៃនោះ អាជ្ញាធរកម្ពុជា តាមរយៈស្ថានទូតខ្មែរនៅក្នុងទីក្រុងបាងកក ត្រូវពិនិត្យមើលករណីនេះឱ្យបានជិតដល់ ដើម្បីការពារផលប្រយោជន៍ពលរដ្ឋរបស់ខ្លួន៖ «ត្រូវស្រាវជ្រាវរកព័ត៌មានរបស់ពួកគាត់ហ្នឹងថាតើគាត់បានប្រព្រឹត្តដូចមានការចោទប្រកាន់របស់អាជ្ញាធរចាប់ហ្នឹងដែរឬទេ?ហើយវាមានភស្តុតាងគ្រប់គ្រាន់មានវិមតិសង្ស័យយ៉ាងម៉េចខ្លះ ហើយប្រសិនបើពួកគាត់អត់បានប្រព្រឹត្តអាហ្នឹងគួរតែមានកិច្ចអន្តរាគមន៍យ៉ាងណា ដើម្បីភាគីថៃដោះលែងពួកគាត់អោយបានវិលត្រឡប់មកប្រទេសកម្ពុជាវិញហើយបើទោះបីជារកឃើញថា ពួកគាត់បានប្រព្រឹត្តខុសទាស់អីមែនគួរតែស្ថានទូតធ្វើយ៉ាងណា ដើម្បីរកមេធាវីធ្វើការការពារក្តីពួកគាត់តាមនីតិវិធីផ្លូវច្បាប់ទៅក្នុងន័យមួយដែលថាប្រទេសមួយដែលយកចិត្តទុកដាក់ចំពោះពលរដ្ឋរបស់ខ្លួន»។

កាលពីថ្ងៃទី៣១ មីនា កន្លងទៅ អាជ្ញាធរចម្រុះរបស់ថៃ បានចុះឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ១២នាក់ នៅចំណុចចម្ការកៅស៊ូមួយកន្លែង ក្នុងស្រុកខនបូរី (Khon Buri) ខេត្តនគររាជសីមា (Nakhon Ratchasima) ពាក់ព័ន្ធនឹងការលបឆ្លងដែនចូលក្នុងប្រទេសថៃដោយខុសច្បាប់។ អាជ្ញាធរថៃសង្ស័យថា ពួកគេត្រូវបានជួលឱ្យមកកាប់ឈើគ្រញូង នៅក្នុងតំបន់ឧទ្យានជាតិ ថាប ឡាន (Thap Lan National Park) ខេត្តនគររាជសីមា។

កាសែតបាងកកប៉ុស្តិ៍ (Bangkok Post) បានស្រង់សម្តីរបស់មន្ត្រីថៃថា ពលរដ្ឋខ្មែរទាំងនោះបានសារភាពថាពួកគេបានលបឆ្លងដែនចូលក្នុងប្រទេសថៃដោយខុសច្បាប់ តាមការណែនាំពីមេខ្យល់មួយក្រុម ដែលអះអាងថា ពួកគេនឹងត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅតាមតំបន់ផ្សេងៗ នៃប្រទេសថៃ ដោយទទួលបានប្រាក់ឈ្នួលក្នុងម្នាក់រហូតដល់ ១ម៉ឺនបាតក្នុងមួយថ្ងៃ។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេសលោក កេត សោផាន់ ដើម្បីសាកសួរអំពីរឿងនេះបានទេ នៅថ្ងៃទី២ មេសា ដោយលោកមិនលើកទូរស័ព្ទ ចំណែកមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកក៏មិនមានអ្នកលើកទូរស័ព្ទដូចគ្នា ទោះបានហៅជាច្រើនសាក្តី។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក ខុំ ចេហ្យ៉ា ថ្លែងថា ករណីនេះត្រូវតែមានការស៊ើបអង្កេតឱ្យបានច្បាស់លាស់ ព្រោះលោកជឿជាក់ថា ពលរដ្ឋខ្មែរទាំងនោះគ្មានលទ្ធភាពឆ្លងចូលជ្រៅក្នុងទឹកដីថៃ ដើម្បីទៅកាប់ឈើប្រណីតនោះឡើយ ប្រសិនបើគ្មានការរៀបចំ និងឃុបឃិតគ្នាជាប្រព័ន្ធរវាងមន្ត្រីថៃ និងក្រុមមេខ្យល់ខ្មែរទេនោះ។ លោកបន្តថា ពលរដ្ឋខ្មែរទាំង ១២នាក់នោះ គឺជាជនរងគ្រោះទៅវិញទេ ព្រោះត្រូវបានមេខ្យល់នាំឱ្យទៅប្រទេសថៃ ដោយសន្យាថា នឹងផ្តល់ការងារឱ្យធ្វើ៖ «វាមើលទៅឃើញថា ជារូបភាពរៀបចំជាផែនការរវាងអ្នកពាក់ព័ន្ធនៅថៃ និងឈ្មួញនៅខ្មែររកស៊ីជាមួយគ្នា។ អ៊ីចឹងហើយ យើងសង្កត់ធ្ងន់ទៅលើធ្វើម៉េចឲ្យមានការស៊ើបអង្កេតស្វែងរកជនល្មើស ដែលរៀបចំគម្រោងបែបហ្នឹងឱ្យបានច្បាស់លាស់ ជាជាងចាប់ពលករដែរ

ស៊ីឈ្នួលគេហ្នឹង គាត់ជាអ្នករងគ្រោះក្នុងការនាំមនុស្សទៅធ្វើការឱ្យហើយ ហើយត្រូវបានគេចោទប្រកាន់អីផ្សេងៗទៀត។ ខ្ញុំគិតថា វាអយុត្តិធម៌សម្រាប់ពួកគាត់»។

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋ៤នាក់មកកម្ពុជាវិញបន្ទាប់ពីជាប់ពន្ធនាគារករណីកាប់ឈើខុសច្បាប់

http://www.rasmeinews.com/ April 2, 2019, 9:57 PM

ដោយបាយ័ន/ខេត្តសៀមរាបៈ កាលពីវេលាម៉ោង១២.៥០នាទីថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋកម្ពុជាចំនួន៤នាក់មកមាតុភូមិវិញតាមរយៈច្រកអន្តរជាតិជាំស្រងាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចនគរបាលបានឲ្យដឹងទៀតថា ប្រជាពលរដ្ឋទាំង៤នាក់ដែលត្រូវអាជ្ញាធរថៃបញ្ជូនមកវិញនេះ គឺបន្ទាប់ពីពួកគេទាំង៤នាក់បានធ្វើការចូលពីកាប់ឈើគ្រញូងខុសច្បាប់នៅក្នុងទឹកដីថៃ។ត្រូវសមត្ថកិច្ចថៃចាប់ខ្លួននៅថ្ងៃទី៦ខែមេសាឆ្នាំ២០១៦និងបានចោទប្រកាន់ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ចូលតាមច្រកអូរស្វាយហើយបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃផងដែរ។ សមត្ថកិច្ចនគរបាលក៏បានបន្តឲ្យដឹងទៀតថាពលរដ្ឋខ្មែរចំនួន៤នាក់មានឈ្មោះ១ ឈ្មោះ ពិន ពោ ភេទប្រុស ៤៤ឆ្នាំ, ទី២ឈ្មោះ ខៀវ ជា ភេទប្រុស ៤៣ឆ្នាំ, ទី៣ឈ្មោះ ហ៊ន ភ័ក្រ ភេទប្រុស ៤០ឆ្នាំនិងទី៤ឈ្មោះ ជា ធី ភេទប្រុស ៥៥ឆ្នាំ។ អ្នកទាំងបួនរស់នៅ ភូមិចាន់ហៀ ឃុំបឹងមាលា ស្រុកស្វាយលើខេត្តសៀមរាប។បច្ចុប្បន្នជនទាំង៤នាក់នេះត្រូវបានសមត្ថកិច្ចអាជ្ញាធរខ្មែរធ្វើការអប់រំបន្ត និងបានបញ្ជូនទៅកាន់លំនៅឋានវិញផងដែរ។ទS/

## សមត្ថកិច្ចថៃនៅច្រកព្រំដែនឡែមបានត្រៀមកន្លែងចាំទទួលបងប្អូនពលករខ្មែរដែលធ្វើការនៅប្រទេសថៃ

https://www.facebook.com/ ទឹកចិត្តពលករឆ្លងដែន 03-04-2019

នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរខាងមុខនេះ ចាប់ពីថ្ងៃទី៥-៣០ ខែមេសា ឆ្នាំ២០១៩នេះ នៅក្នុងឆ្នាំនេះសមត្ថកិច្ចថៃនៅច្រកព្រំដែនឡែមបានកែសម្រួលចាំទទួលបងប្អូនពលករខ្មែរធ្វើដំណើរចេញ-ចូលច្រកព្រំដែនឡែមលឿនជាងឆ្នាំមុនៗ ជាសវាងបងប្អូនពលករខ្មែរធ្វើដំណើរមានការស្ទះនៅច្រកព្រំដែន ។

ខ្ញុំសុំបញ្ជាក់ប្រាប់បងប្អូនពលករខ្មែរចាប់ពីទី៥ ខែមេសា រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ សមត្ថកិច្ចថៃនៅច្រកព្រំដែនអន្តជាតិបានអនុញ្ញាតអោយបងប្អូនពលករខ្មែរធ្វើដំណើរចេញ-ចូលច្រកព្រំដែនដោយសេរី ដោយមិនចាំបាច់បង់ថ្លៃសេវាកម្ម វ៉ែប៉ាស្ត័រ ចេញ-ចូលច្រកព្រំដែនថៃ-កម្ពុជា បងប្អូនពលករខ្មែរធ្វើដំណើរដោយសេរី។

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ

https://www.facebook.com ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ 03-04-2019

នាថ្ងៃច័ន្ទ ១២រោច ខែផល្គុន ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករ និងចំនួនថ្ងៃដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជក/ថៅកែ។

ឆ្លៀតឱកាសនេះផងដែរ មន្ត្រីស្ថានទូតបានចែកនំដល់កូនៗរបស់បងប្អូនពលករ និងបានពន្យល់ណែនាំដល់បងប្អូនពលករ ដែលមកទទួលសេវានៅស្ថានទូត អំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។

# ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៩

## ពលករខ្មែរចាប់ផ្តើមសម្រុកចេញពីប្រទេសថៃ មកចូលរួមបុណ្យចូលឆ្នាំថ្មីជាបន្តបន្ទាប់

http://www.rasmeinews.com/ April 4, 2019, 11:11 AM

**ដោយៈគ្រញូង/បាត់ដំបងៈ** ពលករខ្មែរដែលទៅធ្វើការងារនៅប្រទេសថៃ បានវិលត្រឡប់ចូលមកស្រុកកំណើតវិញតាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀងនិងច្រកទ្វារអន្តរជាតិភ្នំដី ស្រុកសំពៅលូន ដើម្បីអបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិដែលជិតចូលមកដល់នាពេលខាងមុខនេះ។

លោកផាន់ ផានណា ប្រធានប៉ុស្តិ៍អន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិដូងស្រុកកំរៀងខេត្តបាត់ដំបង បានឱ្យដឹងនៅថ្ងៃទី៣ខែមេសានេះថា រយៈពេល៣ថ្ងៃជាប់ៗគ្នា ចាប់តាំងពីថ្ងៃទី១ដល់ថ្ងៃទី៣ខែមេសាឆ្នាំ២០១៩នេះ ពលករខ្មែរទាំងប្រុស ទាំងស្រីបានចាប់ផ្តើមនាំគ្នាចេញពីប្រទេសថៃចូលមកកម្ពុជាវិញ ក្នុងគោលបំណងមកជួបជុំក្រុមគ្រួសារ សាច់ញាតិកូនចៅក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលនឹងមកដល់នៅថ្ងៃទី១៤ខែមេសាឆ្នាំ២០១៩ខាងមុខនេះ។ លោកនាយប៉ុស្តិ៍បានបន្តថា ការសម្រុកពីប្រទេសថៃរបស់ពលករខ្មែររយៈពេល៣ថ្ងៃនេះសរុបចំនួន៦.៩៦២នាក់ដោយនៅថ្ងៃទី១ខែមេសាមានចំនួន២១៥៦នាក់នៅថ្ងៃទី២និងទី៣ខែមេសាមានចំនួន៤.៨០៦នាក់។

ពលករខ្មែរដែលធ្វើចំណាកស្រុកវិលត្រឡប់មកស្រុកវិញនេះភាគច្រើនជាពលករដែលបានបំពេញបែបបទត្រឹមត្រូវស្របតាមច្បាប់កំណត់ ផ្ទុយទៅវិញតួលេខពលករដែលធ្វើចំណាកស្រុកដោយខុសច្បាប់មានត្រឹមចំនួនតិចតួចប៉ុណ្ណោះ។ ពលករខ្មែរដែលបានសម្រុកចេញនេះដែរមានច្រើនចម្រុះគ្នាមកពីតាមបណ្តាខេត្តនានា ដូចជាខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ ពោធិសាត់ កំពង់ឆ្នាំង ព្រៃវែង ហើយនឹងខេត្តស្វាយរៀងជាដើម។ពួកគាត់បញ្ជាក់ដំហរថា ក្រោយការវិលត្រឡប់មកស្រុកវិញនេះពួកគាត់មួយចំនួនមិនត្រឡប់ទៅកាន់ប្រទេសថៃវិញទេ គឺរកការងារធ្វើនៅក្នុងប្រទេសក៏មានការងារច្រើនមិនខ្វះដែរ។

ផ្ទុយទៅវិញពលករមួយចំនួនទៀតក៏បានបញ្ជាក់ថា ក្រោយពេលបញ្ចប់ពិធីបុណ្យចូលឆ្នាំថ្មីរួចរាល់ពួកគាត់នឹងវិលទៅប្រទេសថៃវិញដើម្បីរកប្រាក់ចំណូលទ្រទ្រង់ជីវភាពគ្រួសារបន្តទៀត៕S/Ha

## អាជ្ញាធរថៃបន្តឃុំខ្លួនពលរដ្ឋខ្មែរ ១២នាក់ ពាក់ព័ន្ធនឹងការលបឆ្លងដែនខុសច្បាប់

https://www.rfa.org/khmer/news/ ដោយ អាស៊ីសេរី 2019-04-03

អាជ្ញាធរថៃអះអាងថា ពលរដ្ឋខ្មែរ ១២នាក់ ដែលត្រូវបានឃាត់ខ្លួននៅស្រុកខនបូរី (Khon Buri) ខេត្តនគររាជសីមា កាលពីពេលថ្មីៗ នេះ បានចូលមកក្នុងប្រទេសថៃដោយខុសច្បាប់ ហើយគិតត្រឹមរសៀលថ្ងៃទី៣ មេសា ពួកគេកំពុងជាប់ឃុំនៅក្នុងឧទ្យានជាតិថាបឡាន (Thap Lan National Park) នៅឡើយ។

មេប៉ូលីសស្រុកខនបូរី (Khon Buri) វរសេនីយ៍ឯក សថេន ឡាវកើង (Pol. Col. Sathein Laokerng) អះអាងប្រាប់អាស៊ីសេរីនៅថ្ងៃទី៣ មេសាថា នៅពេលណាពលរដ្ឋខ្មែរទាំងនោះត្រូវបញ្ជូនមកដល់កន្លែងរបស់លោក ពួកលោកនឹងធ្វើរបាយការណ៍ ហើយបញ្ជូនពួកគេបន្តទៅផ្នែកអន្តោប្រវេសន៍នៅខេត្តនគររាជសីមា។ ទោះជាយ៉ាងណា លោកមិនទាន់អាចបញ្ជាក់បាននៅឡើយទេថា តើពលរដ្ឋខ្មែរទាំងនោះនឹងត្រូវចោទប្រកាន់រឿងកាប់ឈើខុសច្បាប់ដែរ ឬមួយក៏អត់។

កាលពីថ្ងៃទី៣១ មីនាកន្លងទៅ អាជ្ញាធរចម្រុះរបស់ថៃ បានចុះឃាត់ខ្លួនពលរដ្ឋខ្មែរទាំងនោះ ដោយសង្ស័យថាពួកគេត្រូវបានជួលឱ្យមកកាប់ឈើគ្រញូង នៅក្នុងតំបន់ឧទ្យានជាតិថាបឡាន។ ទោះជាយ៉ាងណា ពួកគេបានសារភាពក្រោយពេលឃាត់ខ្លួនថា ពួកគេបានលបឆ្លងដែនចូលក្នុងទឹកដីថៃដោយខុសច្បាប់ តាមការណែនាំពីមេខ្យល់

មួយក្រុម ដែលសន្យាថានឹងផ្តល់ឱ្យពួកគេនូវការងារ ដែលអាចទទួលបានប្រាក់ឈ្នួលក្នុងម្នាក់ រហូតដល់ ១ ម៉ឺនបាត ក្នុងមួយថ្ងៃ។

អាស៊ីសេរីនៅមិនទាន់អាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសាកសួរអំពីអន្តរាគមន៍ក្នុងករណីនេះបាននៅឡើយទេ គិតត្រឹមម៉ោងផ្សាយនេះ៕

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 04-04-2019

ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើរទៅវិញទៅមករបស់បងប្អូនពលករ និងចំនួនថ្ងៃដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជក/ថៅកែ។

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានចុះមកស្រុកបាងសាយ ខេត្តឈុនបុរី ដើម្បីបន្តដោះស្រាយបញ្ហាជូនពលករខ្មែរចំនួន៥២នាក់

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 03-04-2019

កាលពីថ្ងៃអាទិត្យ ១១រោច ខែផល្គុន ឆ្នាំច ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានចុះមកស្រុកបាងសាយ ខេត្តឈុនបុរី ដើម្បីបន្តដោះស្រាយបញ្ហាជូនពលករខ្មែរចំនួន៥២នាក់ ដែលត្រូវនិយោជកបញ្ឈប់ពីការងារ មិនបើកប្រាក់ឈ្នួល និងបានកាត់ប្រាក់ពីពលករទៅដំណើរការឯកសារ កាលពីថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៩។ ដោយទទួលលទ្ធផលជោគជ័យដូចខាងក្រោម៖

-និយោជកបានបើកប្រាក់ឈ្នួលជូនពលករវិញគ្រប់ចំនួន

-និយោជកបានប្រគល់ប្រាក់ ដែលកាត់ពីពលករទៅដំណើរការឯកសារប៉ុន្តែពុំបានដំណើរការឯកសារ

-និងនិយោជកបានប្រគល់ប្រាក់សំណងជំងឺចិត្តដែលពលកររង់ចាំចាប់ពីថ្ងៃ១៣ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

ការបើកប្រាក់ទាំងអស់ជូនពលករចប់រួចរាល់នៅវេលាម៉ោង ២២:០០នាទី បងប្អូនពលករខ្មែរសប្បាយចិត្ត និងបានថ្លែងអំណរគុណដល់ស្ថានទូតដែលបានជួយដោះស្រាយបញ្ហាជូនពួកគាត់។

## ក្រុមហ៊ុនមិត្តហ្វូននឹងចូលរួមចំណែកផ្តល់ជូនការជិះឡានក្រុងដោយឥតគិតថ្លៃ ពីព្រំដែនប្រទេសថៃ សម្រាប់បងប្អូនពលករខ្មែរ ដែលត្រលប់មកលេងស្រុកកំណើតវិញ

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ 04-04-2019

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងមុខនេះ ក្រុមហ៊ុនមិត្តហ្វូននឹងចូលរួមចំណែកផ្តល់ជូនការជិះឡានក្រុងដោយឥតគិតថ្លៃ ពីព្រំដែនប្រទេសថៃ សម្រាប់បងប្អូនពលករខ្មែរ ដែលត្រលប់មកលេងស្រុកកំណើតវិញ។ បងប្អូនអាចស្វែងរកឡានក្រុងរបស់មិត្តហ្វូននៅតាមបណ្តាច្រកព្រំដែន នៃខេត្តបន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ ចាប់ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១២ ខែមេសា ឆ្នាំ2019 បងប្អូនអាចស្វែងរកសំបុត្រដោយឥតគិតថ្លៃនៅតាមស្តង់មិត្តហ្វូន សូមបងប្អូនពលករជ្រាបទាំងអស់គ្នា។

# ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩

## ភរិយាទន្ទឹងរង់ចាំជួបប្ដីបន្ទាប់ពីទទួលដំណឹងថៃអនុញ្ញាតឱ្យសាច់ញាតិសួរសុខទុក្ខអ្នកទោសខ្មែរក្នុងពន្ធនាគារ ២ថ្ងៃនៅចុងខែមេសា

https://www.rfa.org/khmer/news/ ដោយ មាន ឫទ្ធិ 2019-04-04

ភរិយាអ្នកទោសខ្មែរជាប់ពន្ធនាគារនៅប្រទេសថៃ មានអារម្មណ៍រំភើបនៅពេលទទួលដំណឹងថា ខាងសមត្ថកិច្ចអនុញ្ញាតសាច់ញាតិពលករជាប់ពន្ធនាគារនៅថៃអាចចូលសួរសុខទុក្ខបានចំនួន២ថ្ងៃនោះ។ ពលករខ្មែររស់នៅខេត្តបាត់ដំបង ធ្វើការនៅប្រទេសថៃ អ្នកស្រី សុខ ស្រីហ៊ុន ថ្លែងប្រាប់អាស៊ីសេរីនៅថ្ងៃទី៣ មេសាថា តាំងពីតម្រួតថៃចាប់ស្វាមីរបស់ខ្លួន កាលពីថ្ងៃទី៥ ខែមេសាឆ្នាំ២០១៧ មក គឺមិនដែលបានចូលជួបនិយាយផ្ទាល់មាត់ជាមួយប្ដីម្ដងនៅឡើយទេ។ អ្នកស្រីថា ជាទូទៅខាងថៃឱ្យជួបក្នុងបន្ទប់មានរបាំងបិទកញ្ចក់និយាយគ្នាតាមទូរស័ព្ទជាមួយស្វាមីមានរយៈពេល ១០នាទីក្នុងមួយសប្ដាហ៍៖ «នៅពេលខ្ញុំបានជួបប្ដីខ្ញុំផ្ទាល់ខ្ញុំមានអារម្មណ៍រំភើបសប្បាយចិត្ត ហើយសូមឱ្យបងប្អូនទាំងអស់គ្នាសង្ឃឹមថា បានជួបសួរសុខទុក្ខទាំងអស់គ្នា អ្នកខ្លះជាប់រាប់ឆ្នាំហើយ គ្មានសាច់ញាតិទៅសួរសុខទុក្ខក៏មានដែរ ប្ដីខ្ញុំធ្លាប់និយាយ។ ចំពោះខ្ញុំទើបតែមួយរយៈនេះទេ គឺ ៣ខែហើយ ដែលខ្ញុំមិនបានទៅសួរសុខទុក្ខប្ដី។ រាល់ដងកន្លះខែទៅ មួយខែ ខ្ញុំទៅមើលប្ដីម្ដង»។

ក្ដីរំភើបរបស់ពលករខ្មែរនេះបន្ទាប់ពីគេហទំព័រអគ្គនាយកដ្ឋានពន្ធនាគារចុះផ្សាយ កាលពីថ្ងៃទី២៩ មីនាថា ពន្ធនាគារខ្លងព្រេម (Klong pram) របស់ថៃ បានអនុញ្ញាតឲ្យសាច់ញាតិចូលសួរសុខទុក្ខអ្នកជាប់ឃុំក្នុងពន្ធនាគារនេះដោយផ្ទាល់ មិនមានរបាំងរយៈពេល ៤ម៉ោងចំនួន ២ថ្ងៃ ចាប់ពីម៉ោង ៩ព្រឹកដល់ម៉ោង ១រសៀល នៅថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែមេសា។

ការអនុញ្ញាតនេះបន្ថែមលើការជួបសួរសុខទុក្ខធម្មតា ដែលធ្លាប់មានពីមុនមក ដោយចាប់អនុវត្តន៍ពីឆ្នាំ២០១៩ តទៅ។ អគ្គដ្ឋានពន្ធនាគារបន្តថា សាច់ញាតិត្រូវដាក់ពាក្យស្នើសុំជាមុន ដោយមានឯកសារបញ្ជាក់ច្បាស់លាស់ ហើយសាច់ញាតិអាចចូលទៅជួបសួរសុខទុក្ខអ្នកជាប់ឃុំម្ដងបាន ១២នាក់។ សាច់ញាតិអាចទាក់ទងសាកសួរបន្ថែមជុំវិញបញ្ហានេះទៅខាងពន្ធនាគារខ្លងព្រេម (Klong prem) នៅទីក្រុងបាងកក តាមលេខទូរស័ព្ទ+៦៦ ២៥ ៩១ ៥៥ ១៦។

អ្នកនាំពាក្យអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃលោក នុត សាវនា ថ្លែងប្រាប់កាសែត ភ្នំពេញ ប៉ុស្ដិ៍ (Phnom Penh Post) ថា ជនជាតិខ្មែរដែលកំពុងជាប់ឃុំនៅប្រទេសថៃមានមិនតិចជាង ៤ ពាន់នាក់ទេ។

## ទីតាំងម៉ាស្សា យីហោ ចាន់ សៀងហៃ ត្រូវបានសមត្ថកិច្ចចុះបង្ក្រាប ករណីបង្កប់សេវាផ្លូវភេទ

https://chsknews.com/ 2019/04/04/ មាណព ភាព

សៀមរាប៖ នៅយប់ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង៩ និង៤០នាទីយប់ នៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុង ខេត្ត សៀមរាប កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបង្ក្រាបហាងម៉ាស្សាយីហោ ចាន់ សៀងហៃ នៅក្នុងក្រុងសៀមរាប។ កម្លាំងជំនាញបានស្រាវជ្រាវរហូតឈានដល់ឃាត់ខ្លួន បានថៅកែហាងម៉ាស្សឈ្មោះ ម៉ាន់ ខទីចាស់ ភេទស្រី អាយុ៣៧ឆ្នាំ រស់នៅក្នុងហាង ដោយឃាត់ខ្លួនតាមបញ្ជាលោក កើត វណ្ណារេត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ព្រមទាំងប្រមូលស្ត្រីរកស៊ីផ្លូវភេទចំនួន ៥នាក់ និងឆែករកឃើញស្រោមអនាម័យប្រើប្រាស់ចំនួន៨ ស្រោមមិនទាន់ប្រើចំនួន៧សំបកស្រោមមួយចំនួន និងសៀវភៅកត់ត្រា ១ក្បាល ។ នៅក្នុងហាងមាស្សា អារី បានបើករកស៊ីផ្លូវភេទ ជ្រកក្រោមផ្លាកមាស្សាកោសជប់ ការរួមភេទម្ដងតម្លៃ២០$ ទៅ៣០$ ត្រូវបានថៅកែដកយកពី ៣ $ទៅ១០$ក្នុងពេលរួមភេទម្ដង។ ឃាត់ខ្លួនថៅកែ ម៉ាស្សារួចមក កម្លាំងជំនាញបានរៀបចំ

បញ្ជូន ស្ត្រីរកស៊ីផ្លូវទាំង ៥នាក់ ទៅមន្ទីរសង្គមកិច្ចខេត្តដើម្បីអប់រំកែប្រែ និងផ្តល់ជំនាញផ្សេងៗដែលពួកគាត់អាចទទួលយកបានផងដែរ ៕

## ចេះតែឆ្ងល់មិចបានខារ៉ាអូខេកន្លែងនឹងគេចូលយូរៗម្តង ក្រោយពេលចុះឆែកមើលឃើញសុទ្ធតែ

http://khmertopnews.com/ April 4, 2019

កណ្តាលៈ នៅថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៩ នេះតាមការចង្អុលបង្ហាញរបស់ ឯកឧត្តមស្នងការនគរបាលខេត្តកណ្តាល និងតាមរយៈលោកស្រីស្នងការរង ទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ការិ.ជំនាញបានចុះបង្ក្រាបហាងខារ៉ាអូខេម្លប់ស្វាយ777 លួចលាក់បំរើសេវាកម្មពិសេស នៅក្នុងហាង ស្ថិតនៅភូមិកំពង់ស្វាយ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល។ សង្គ្រោះបាននារីរងគ្រោះចំនួន07 នាក់ ។ ឃាត់ខ្លួនជនសង្ស័យចំនួនមួយនាក់ឈ្មោះ សៅ វុទ្ធី ភេទស្រីអាយុ 50ឆ្នាំ ជនជាតិខ្មែរ មុខរបរម្ចាស់ហាងខារ៉ាអូខេ បានកសាងសំណុំរឿង និងបញ្ជូនជនសង្ស័យទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធី ពីបទផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ។

## កម្ពុជា-អាមេរិក នឹងចុះអនុស្សរណៈយោគយល់គ្នាប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 05 April 2019 | 09:19 ICT

**ភ្នំពេញៈ** កម្ពុជា និងការិយាល័យសហព័ន្ធស៊ើបអង្កេត (FBI) របស់សហរដ្ឋអាមេរិកនឹងចុះអនុស្សរណៈយោគយល់គ្នា (MoU) ជាលើកដំបូង លើកិច្ចសហប្រតិបត្តិការ ជុំវិញការអនុវត្តច្បាប់ប្រឆាំងបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនក្នុងអំឡុងពេលមន្ត្រីជាន់ខ្ពស់ទៅបំពេញទស្សនកិច្ចនៅប្រទេសមហាអំណាចមួយនេះដែលរំពឹងថាកម្ពុជានឹងទទួលបានសម្ភារ និងបច្ចេកទេសដើម្បីចូលរួមទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ។

លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ដោយមានការអមដំណើរដោយលោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ទៅបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិក រយៈពេល ៥ថ្ងៃ ចាប់ពីថ្ងៃទី ៥ ដល់ថ្ងៃទី ១០ ខែ មេសា តបតាមការអញ្ជើញរបស់ការិយាល័យស៊ើបអង្កេតបទឧក្រិដ្ឋ របស់សហរដ្ឋអាមេរិក ក្នុងគោលបំណងដើម្បីផ្លាស់ប្តូរបទពិសោធ និងពង្រឹងកិច្ចសហប្រតិបត្តិការ ប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលរួមមានបញ្ហាគ្រឿងញៀន ភេរវកម្ម ការជួញដូរមនុស្ស ការលាងលុយកខ្វក់។

លោក ឆាយ គឹមខឿន អ្នកនាំពាក្យ និងជាអគ្គស្នងការរងនគរបាលជាតិ ថ្លែងក្នុងសន្និសីទកាសែតមុនចេញដំណើរនៅព្រលានយន្តហោះភ្នំពេញ កាលពីម្សិលមិញថា ទស្សនកិច្ចនេះ មានគោលបំណង ២ គឺទី១ ផ្លាស់ប្តូរបទពិសោធកិច្ចសហប្រតិបត្តិការ ការជេដែកគ្នាពង្រឹងឡើងវិញនូវការប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋ និងទី២ គឺដើម្បីចុះហត្ថលេខាលើការចុះអនុស្សរណៈយោគយល់គ្នាបង្កើតក្រុមប្រតិបត្តិការរួមមួយ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងបទឧក្រិដ្ឋឆ្លងដែន និងបញ្ហាផ្សេងៗទៀត ដែលភាគីទាំង ២ ចាប់អារម្មណ៍។ លោកបន្តថាឧក្រិដ្ឋកម្មឆ្លងដែនទាំងនេះគឺសំដៅលើបទល្មើសគ្រឿងញៀន ភេរវកម្ម ការជួញដូរមនុស្ស ការលាងលុយកខ្វក់ និងបទឧក្រិដ្ឋកុំព្យូទ័រជាដើម។ អ្នកនាំពាក្យរូបនេះបញ្ជាក់ថា៖ «ការចុះហត្ថលេខានេះ គឺធ្វើឡើង រវាងអគ្គស្នងការនគរបាលជាតិ ជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង FBI។ មាននិយាយជារួម ដែលអាចផ្តល់ជាសម្ភារបច្ចេកទេសមួយចំនួន ក្នុងប្រតិបត្តិការ រួមទាំងការបណ្តុះបណ្តាលដល់មន្ត្រីជំនាញកម្ពុជា»។ លោកបន្តថា៖ «ជាមួយ FBI នេះ គឺធ្វើឡើងជាលើកទី១ ក្រៅតែពីមានសហប្រតិបត្តិការល្អជាមួយស្ថាប័ននេះរវាងករណីឆ្លងដែនផ្ទាល់រវាងប្រទេស និងប្រទេសដែលមានការសហការគ្នាក្នុងការស៊ើបអង្កេតព្រោះបទឧក្រិដ្ឋឆ្លងដែនបែបនេះ មានការរីករាលដាលខ្លាំង ដែលចាំបាច់ត្រូវរួមគ្នាទប់ស្កាត់»។ លោក ឆាយ គឹមខឿន

អះអាងថា លទ្ធផលនៃដំណើរទស្សនកិច្ចនេះ នឹងបញ្ជាក់លម្អិតនៅពេលក្រោយការបំពេញទស្សនកិច្ចចប់ ព្រោះក្នុងពេលនោះ ភាគី FBI នឹងបង្ហាញពីបទពិសោធរបស់គេមកកម្ពុជា។

លោកស្រី Emily Zeeberg អ្នកនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា និយាយថា ទីភ្នាក់ងារអនុវត្តច្បាប់របស់សហរដ្ឋអាមេរិក ដែលរួមមានទាំង FBI ផងនោះធ្វើការជាមួយនឹងប្រទេសកម្ពុជាជាដៃគូ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស ទេសចរណ៍ផ្លូវភេទលើកុមារ ការជួញដូរគ្រឿងញៀន បទល្មើសបច្ចេកទេស ទំនិញក្លែងក្លាយ ការឆបោកលក់ទិដ្ឋាការ និងបទល្មើសឆ្លងដែនផ្សេងៗទៀត។

លោក សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា យល់ថា ការមើលជាទូទៅតាមរយៈរលកនយោបាយហាក់គិតថា កម្ពុជា និងអាមេរិក មានទំនោរមិនល្អរវាងគ្នា តែវាមិនដូច្នេះទេ ព្រោះថា ក្នុងពេលនេះ សហរដ្ឋអាមេរិក ត្រូវតែក្រឡេកមកអាស៊ី ដែលមានកម្ពុជាផងនោះ គឺមិនអាចចាត់ទុកជាសត្រូវបានទេ។ ដូច្នេះលោកថា ទំនាក់ទំនងរវាងកម្ពុជា និងអាមេរិក តាមរយៈស្ថាប័ន FBI នេះ គឺត្រូវតែធ្វើឡើង ដោយក្នុងក្របខ័ណ្ឌមួយចាំបាច់ ព្រោះថា ឧក្រិដ្ឋកម្មឆ្លងដែន ជាឧក្រិដ្ឋកម្មមួយគ្មានដែនកំណត់។ លោកបញ្ជាក់ថា៖ «ភេរវកម្មឆ្លងដែន គឺគ្មានព្រំដែនទេ អ៊ីចឹងការរួមសហការគ្នាទូទាំងពិភពលោក គឺជាឱកាសមួយ សម្រាប់ទប់ស្កាត់រឿងទាំងអស់ហ្នឹង។ កាលណាយើងនៅបែងចែកនយោបាយអ៊ីចេះអ៊ីចុះ ភេរវកម្មជាឱកាសយកប្រទេសណាមួយ ជាកន្លែងឆ្លងកាត់»។

លោក មាស នី អ្នកស្រាវជ្រាវការអភិវឌ្ឍសង្គម និងជាអ្នកវិភាគនយោបាយ ថ្លែងថា នេះគឺជាភាពចាំបាច់ ដែលអាមេរិក ត្រូវតែមានកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាក្នុងតំបន់ ដូចជាកម្ពុជា ព្រោះថា អាមេរិក បារម្ភពីការរីករាលដាលចំពោះឧក្រិដ្ឋកម្មទាំងនេះ ដែលអាចបង្កឲ្យគ្រោះថ្នាក់ដល់ប្រទេសខ្លួន និងប្រទេសនៅក្នុងតំបន់ ដែលក្នុងនោះ ពួកភេរវជនអាចនឹងឆ្លៀតឱកាសយកប្រទេសកម្ពុជា ជាតំបន់គោលដៅ ឬជាជម្រក ដោយសារតែប្រព័ន្ធគ្រប់គ្រងកម្ពុជានៅមានកម្រិតខ្សោយ។ លោក មាស នី បន្តថា៖ «បើនិយាយមែនទែនទៅ ឲ្យតែការសហការគ្នា ដើម្បីកាត់បន្ថយ នូវឧក្រិដ្ឋកម្មឆ្លងដែន សុទ្ធតែមានប្រយោជន៍រៀងខ្លួន ក៏ប៉ុន្តែអ្វីដែលអាមេរិកកំពុងតែសម្លឹងមើល គឺការសហការជាមួយប្រទេសតូចៗដើម្បីទប់ស្កាត់កុំឲ្យកើតមានក្នុងប្រទេសតូចៗនោះ ដែលអាចជាទីតាំងភេរវជនអ៊ីចឹង»។ ទោះយ៉ាង ណា លោក មាស នី សង្កត់ធ្ងន់ថា ការចុះ MoU រវាង កម្ពុជា និងអាមេរិកនៅពេលនេះ ក៏មិនសំដៅថា ប្រទេសទាំង ២ នេះមានទំនាក់ទំនងល្អកល្អិន ជាមួយគ្នាដែរ វាគ្រាន់តែជាចំណែកមួយ ដែលកម្ពុជាត្រូវតែឆ្លៀតឱកាសយកផលចំណេញផ្នែកនយោបាយពីទំនាក់ទំនងនេះ ខណៈវាគ្រាន់តែជាសហប្រតិបត្តិការក្នុងការការពារសន្តិសុខប៉ុណ្ណោះ៕

## ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩

## អគ្គស្នងការរងនគរបាលជាតិ ជំរុញឲ្យមន្ត្រីខិតខំទប់ស្កាត់ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវ ភេទបន្ថែមទៀត

http://bayontv.com.kh/ 05/04/2019

ភ្នំពេញ ៖ អគ្គស្នងការរងនគរបាលជាតិ លោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា បានជំរុញដល់មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ត្រូវខិតខំបន្ថែមទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ខណៈករណីនេះ នៅតែកើតឡើងគួរឲ្យព្រួយបារម្ភនៅប្រទេសកម្ពុជានោះ។ ថ្លែងនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ នាព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩នេះអគ្គស្នងការដ្ឋាននគរបាលជាតិលោកជំទាវ យក់ សុខា បានលើកឡើងថា ក្នុងនាម យើងជានគរបាលរកយុត្តិធម៌ និងប្រឆាំងការជួញដូរមនុស្សត្រូវតែស្រាវជ្រាវរកករណីខាងលើនេះឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីធ្វើយ៉ាងណាស្វែងរកចាប់ខ្លួនជនល្មើសឲ្យបានដើម្បីយកមកផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

សូមបញ្ជាក់ថា នៅក្នុងឆ្នាំ២០១៨ កន្លងទៅនេះ អាជ្ញាធរបានធ្វើការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ បាន១០៤ ករណី ថយចុះ៤៧ករណីស្មើ និងជាង៣១ភាគរយ ដោយចាប់ជនសង្ស័យបានចំនួនជិតពីររយនាក់ ក្នុងនោះជនបរទេសជិត២០នាក់ និងសង្គ្រោះជនរងគ្រោះបានជាងពីររយនាក់។

ដោយឡែកទាក់ទងនិងករណីរំលោភសេពសន្ថវៈ ដែលបង្ករឡើងដោយឪពុកបង្កើត ឪពុកចុង ជីតាឬក៏ពូអ៊ុំជាដើមនោះគឺបានកើតឡើងជាងមួយរយករណី ដោយឃាត់ខ្លួនជនសង្ស័យបានជាងមួយរយនាក់ និងសង្គ្រោះជនរងគ្រោះបាន១១៧នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំជិត៧០នាក់។

យ៉ាងណាក៏ដោយលោកជំទាវ នាយឧត្តមសេនីយ៍ យក់ សុខា បានអំពាវនាវដល់មន្ត្រី និងភាគីពាក់ព័ន្ធ ទាំងអស់ត្រូវបង្កើនសកម្មភាពចុះអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឲ្យបានសកម្មបន្ថែមទៀតទាក់ទង និងផលប៉ះពាល់នៃការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទនេះ៕

## ប៉ូលិសកម្ពុជាជំរុញឱ្យអប់រំស្ត្រីឈប់ស៊ីឈ្នួលពពោះជំនួស

https://khmer.voanews.com/ 07 មេសា 2019

អាជ្ញាធរប៉ូលិសកម្ពុជាបានជំរុញដល់មន្ត្រី នគរបាលប្រឆាំងការជួញដូរមនុស្ស និងភាគីពាក់ព័ន្ធទាំងអស់ឱ្យបង្កើនសកម្មភាពចុះអប់រំដល់ប្រជាពលរដ្ឋ ជាពិសេសគឺស្ត្រីទាក់ទងនឹងការស៊ីឈ្នួលពពោះជំនួសព្រោះវាជាបទល្មើសជួញដូរមនុស្សដោយឆ្លងដែន។ នេះបើតាមសេចក្ដីរាយការណ៍របស់អគ្គស្នងការនគរបាលជាតិកម្ពុជា។

លោកស្រីនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនរគបាលជាតិបានលើកឡើងនៅក្នុងពិធីបិទសន្និបាតនៃការបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទកាលពីថ្ងៃសុក្រថាករណីស៊ីឈ្នួលពពោះជំនួសនៅតែមាននៅកម្ពុជា ដូច្នេះដើម្បីបង្ការមិនឲ្យមានទៀតមន្ត្រីគប្បីបង្កើនសកម្មភាពបន្ថែមទៀតចុះអប់រំ ដល់ពលរដ្ឋតាមមូលដ្ឋានឱ្យយល់ដឹងកាន់តែច្រើនពីបញ្ហានេះ។ លោកស្រីបានបន្ថែមថា៖ «យើងត្រូវចុះអប់រំពួកគាត់ថាករណីស៊ីឈ្នួលពពោះជំនួសនេះគឺជា ករណីខុសច្បាប់ ហើយការចាក់បញ្ចូលមេជីវិតទៅដល់ពួកគាត់គឺជាមេជីវិតរស់ដោយពុំមាន អត្តសញ្ញាណជាឱពុកច្បាស់លាស់ ដូច្នេះយើងមិនត្រូវឲ្យករណីនេះកើតមានបន្តទៀតនោះទេ»។

នៅប្រទេសកម្ពុជាករណីស៊ីឈ្នួលពពោះជំនួសនេះត្រូវបានការិយាល័យប្រឆាំងការជួញដូរមនុស្ស រាជធានីភ្នំពេញបានឃាត់ខ្លួនមនុស្សចំនួន ៣៥នាក់ កាលពីខែមិថុនា ឆ្នាំ២០១៨ ក្នុងនោះមានស្ត្រីមានផ្ទៃពោះ ដែលជាអ្នកពពោះជំនួសចំនួន៣២នាក់ និងមេខ្យល់ ៥នាក់ ក្នុងនោះមានម្នាក់ជាជនជាតិចិន។ នេះបើតាមសេចក្ដីរាយការណ៍ដដែលរបស់អគ្គស្នងការនគរបាលជាតិ៕

## មន្ត្រីនគរបាលជាន់ខ្ពស់ជំរុញដល់ភាគីពាក់ព័ន្ធទាំងអស់ចុះអប់រំដល់ពលរដ្ឋបន្ថែមទៀត ទាក់ទងនឹងការពពោះជំនួស

http://bayontv.com.kh/ 05/04/2019

ភ្នំពេញ៖ អគ្គស្នងការរងនគរបាលជាតិលោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា បានជំរុញដល់មន្ត្រីនគរបាលប្រឆាងការជួញដូរមនុស្ស និងភាគីពាក់ព័ន្ធទាំងអស់ត្រូវបង្កើនសកម្មភាពចុះអប់រំ ដល់ប្រជាពលរដ្ឋជាពិសេសគឺស្ត្រីបន្ថែមទៀត ទាក់ទងនិងការពពោះជំនួសដោយករណីនេះ គឺត្រូវបានចាត់ទុកថាជាបទល្មើសជួញដូរមនុស្សដោយឆ្លងដែន។ ថ្លែងនៅបិទសន្និបាត នៃការបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩នារសៀលថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩នេះនៅអគ្គស្នងការដ្ឋាននគរបាលជាតិ លោកជំទាវ យក់ សុខា បានលើកឡើងថា ករណីស៊ីឈ្នួលពពោះជំនួសនោះគឺវានៅតែមាននៅកម្ពុជាដូច្នេះ ដើម្បីបង្ការមិនឲ្យមានទៀតយើងទាំងអស់គ្នាដែលជាមន្ត្រីគប្បីបង្កើនសកម្មភាពបន្ថែមទៀត ចុះ

អប់រំ ដល់ពួកគាត់តាមមូលដ្ឋាន និងមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើទៅបាន។ លោកជំទាវ បានបញ្ជាក់ថា « យើងត្រូវចុះអប់រំពួកគាត់ថាករណីស៊ីឈ្នួលពពោះជំនួសនេះគឺជា ករណីខុសច្បាប់ ហើយការចាក់បញ្ចូលមេជីវិតទៅដល់ពួកគាត់គឺជាមេជីវិតរស់ដោយពុំមាន អត្តសញ្ញាណជាឪពុកច្បាស់លាស់ ដូច្នេះយើងមិនត្រូវឲ្យករណីនេះ កើតមានបន្តទៀតនោះទេ»។

សូមជម្រាបថា ទាក់ទងនិងករណីស៊ីឈ្នួលពពោះជំនួសនេះការិយាល័យប្រឆាំងការជួញដូរមនុស្ស រាជធានីភ្នំពេញ កាលពីខែមិថុនា ឆ្នាំ២០១៨ បានឃាត់ខ្លួនមនុស្សចំនួន ៣៥នាក់ក្នុងនោះ មាន ៣២នាក់ជាស្ត្រីមានផ្ទៃពោះដែលជាអ្នកពពោះជំនួស និងមេខ្យល់ ៥នាក់ ក្នុងនោះ មានម្នាក់ជាជនជាតិចិន នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ក្រុមស្ត្រីមានផ្ទៃពោះត្រូវចោទប្រកាន់ពីបទ «ការជួញដូរមនុស្សដោយឆ្លងដែន» ក្រោមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្ម។ ចំណែកមេខ្យល់ត្រូវចោទពីបទ «ការជួញដូរមនុស្សដោយឆ្លងដែន និងបទអន្តរការីជាមួយស្ត្រីពពោះ៕

## ខ្មែរជាង២សែននាក់បានការងារថ្មីធ្វើ និងជិត៧ម៉ឺនទៅធ្វើការក្រៅប្រទេស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៩ ម៉ោង ១១:០០ ព្រឹក

ឯកសារមួយរបស់រដ្ឋាភិបាលបានបង្ហាញអោយឃើញថា ប្រជាពលរដ្ឋចំនួន២០៨.៤០០នាក់ បានទទួលការងារថ្មីធ្វើនៅឆ្នាំ២០១៨ ហើយក៏មានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺននាក់ បានទៅធ្វើការងារនៅបរទេស ។ ឯកសារដែលសារព័ត៌មានកោះសន្តិភាពទទួលបាននោះបាននិយាយបន្តទៀតថា ក្នុងចំណោមមនុស្សទាំង ២០៨.៤០០នាក់ ដែលបានទទួលការងារថ្មីធ្វើនោះ គឺមានស្ត្រីចំនួន ១១៧.៧០០នាក់ ។ក្នុងចំណោមនោះចំនួន ១៤០.០០០នាក់ បានធ្វើការងារនៅក្នុងប្រទេស ហើយចំនួនជិត៧ម៉ឺននាក់បានទៅធ្វើការងារនៅក្រៅប្រទេស។ ក្នុងចំណោមទាំងអស់នោះដែរ គឺមានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺនបានទៅធ្វើការងារនៅក្រៅប្រទេស ជាពិសេសប្រទេសថៃ ចំនួន៦ម៉ឺននាក់ ប្រទេសកូរ៉េខាងត្បូង ចំនួនជិត៥.០០០នាក់ និងជប៉ុនជាង៣ពាន់នាក់ ៕

## ឃាត់ខ្លួននាយកសាលាបង្ហាត់ភាសាកូរ៉េម្នាក់ពីបទឆបោក

http://cambodiapolice.com/policekh/ 6:56 pm 6 មេសា 2019

កំពង់ឆ្នាំង ៖ កម្លាំងអធិការដ្ឋាននគរបាលក្រុង សហការជាមួយកម្លាំងការិយាល័យព្រហ្មទណ្ឌ បានឃាត់ខ្លួនជនសង្ស័យម្នាក់ពីបទឆបោក លំនៅភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង កាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៩ ។

ជនសង្ស័យឈ្មោះ សេង សុគង់ ភេទប្រុស អាយុ៣៣ឆ្នាំ មានទីលំនៅភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង មានមុខរបរ ជានាយកសាលាបង្ហាត់ភាសាកូរ៉េ ដែលមានយីហោ (កាបេង) ពីបទ (ឆបោក) សិស្សដែលមករៀនអោយបង់លុយមុន រួចសន្យាជានាអោយបានទៅធ្វើការនៅប្រទេសកូរ៉េ ៕

## ពលករខ្មែរជាង២០.០០០នាក់ បានសម្រុកចេញពីប្រទេសថៃតាមច្រកទ្វារអន្តរជាតិដូង

http://vdoamazing.com/ sky | April 7, 2019

នៅក្នុងអំឡុងពេលប៉ុន្មានថ្ងៃនេះ គិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ មានពលករខ្មែរទាំងប្រុសស្រីសរុបចំនួន ២៥៤៧៥នាក់ (ពីរម៉ឺនប្រាំពាន់បួនរយចិតសិបប្រាំនាក់) បានសម្រុកចេញពីប្រទេសថៃ មកក្នុងទឹកដីប្រទេសកម្ពុជា ដែលនេះគឺជាការបញ្ជាក់ប្រាប់ពីមន្ត្រីនគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិដូង នៃស្រុកកំរៀង ។ ចំពោះការសម្រុកចេញរបស់បងប្អូនខ្មែរពីប្រទេសថៃត្រឡប់ចូលមកប្រទេសកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិដូង ក្នុង

គោលបំណង ដើម្បីមកជួបជុំក្រុមគ្រួសារ និងសាច់ញាតិក្នុងឱកាសចូលរួមអបអរសាទរ ពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ដែលនឹងប្រព្រឹត្តទៅឡើង ចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៩ខាងមុខនេះ។

ក្នុងចំណោមតួលេខទាំង០៧ថ្ងៃ ដែលមានពលករចំនួនសរុបជាង ២០...០០០នាក់ក្នុង នោះមាន៖

-ថ្ងៃទី១ មានចំនួន ២១៥៦នាក់ (ពីរពាន់មួយរយហាសិបប្រាំមួយនាក់)

-ថ្ងៃទី២ មានចំនួន២៨៥២នាក់ (ពីរពាន់ប្រាំបីរយហាសិបពីរនាក់)

-ថ្ងៃទី៣ មានចំនួន១៩៥៤នាក់ (មួយពាន់ប្រាំបួនរយហាសិបបួននាក់)

-ថ្ងៃទី៤ មានចំនួន២០៣០ (ពីរពាន់សាមសិបនាក់)

-ថ្ងៃទី៥ មានចំនួន៣២៣៥នាក់ (បីពាន់ពីររយសាមសិបប្រាំនាក់)

-ថ្ងៃទី៦ មានចំនួន៦៧៥៨ (ប្រាំមួយពាន់ប្រាំពីររយហាសិបប្រាំបីនាក់)

-ថ្ងៃទី៧ មានចំនួន៦៤៩០នាក់(ប្រាំមួយពាន់បួនរយកៅសិបនាក់)។

ចំពោះពលករខ្មែរ ដែលបានសម្រុកចាកចេញពីប្រទេសថៃ ភាគច្រើនជាអ្នកខេត្តបាត់ដំបង ចំណែកឯមួយចំនួនទៀតនោះ គឺមានដូចជា ពោធិ៍សាត់ កំពង់ធំ ព្រៃវែង កំពង់ឆ្នាំង និងខេត្តស្វាយរៀងជាដើម។ ក្នុងនោះដែរ ពលករខ្មែរ ដែលបានធ្វើចំណាកស្រុក ហើយបានវិលត្រឡប់មកវិញពេលនេះ គឺភាគច្រើនពួកគាត់ បានបំពេញបែបបទត្រឹមត្រូវទៅតាមច្បាប់កំណត់ផងដែរ។

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ២០នាក់មកកម្ពុជាករណីចូលកាប់ឈើ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 05/04/2019

រយៈពេល៣ខែដើមឆ្នាំ២០១៩នេះ អាជ្ញាធរថៃបានដោះលែង និងបញ្ជូនពលរដ្ឋខ្មែរ២០នាក់មកវិញ បន្ទាប់ពីពួកគេទាំងនោះចូលទៅកាប់ឈើនៅទឹកដីប្រទេសជិតខាងមួយនេះដោយខុសច្បាប់។ នេះបើយោងតាមការអះអាងរបស់មន្ត្រីអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កេត សោផាន់ អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជាក់ថាកន្លងមក ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរមកកម្ពុជាវិញជារឿយៗពាក់ព័ន្ធនឹងករណីផ្សេងៗ ហើយទន្ទឹមនឹងនេះដែរ ក្រសួងពាក់ព័ន្ធតែងតែរំឭកដល់ពលរដ្ឋខ្មែរកុំឲ្យចូលទៅកាប់ឈើ ឬប្រព្រឹត្តបទល្មើសខុសច្បាប់ ៕

## ពលករខ្មែរ កំពុងតែមានការព្រួយបារម្ភខ្លាំង រឿងប៉ូលិសតាមច្រកព្រំដែន គៀបយកលុយគ្មានប្រណីដៃ

https://khmer.social/social/ sir heang April 6, 2019

ដូចដែលប្រិយមិត្តបានជ្រាបហើយថា បងប្អូនដែលជាពលករខ្មែរដែលបានធ្វើការចំណាក់ស្រុកទៅប្រទេសថៃ ពេលនេះពួកគាត់កំពុងតែធ្វើដំណើរត្រឡប់មកស្រុកកំណើតរបស់ពួកគាត់ជាបណ្ដើរៗហើយ ដើម្បីមកចូលរួមអបអរសាទរ ទទួលទេវតាឆ្នាំថ្មីៗ ប្រពៃណីជាតិខ្មែរខាងមុខនេះផងដែរ ដូច្នេះហើយឃើញថា នៅតាមច្រកអន្តរជាតិ និងតំបន់ព្រំដែន កម្ពុជា ថៃ នៅក្នុងនោះដែរគេបានឃើញថា មានបងប្អូនខ្មែរយើងដែលបានបំរើការងារនៅប្រទេសថៃ ក៏កំពុងតែមកស្រុកកំណើតរបស់ខ្លួនជាបន្តបន្ទាប់ហើយ ។

ដោយឡែកសម្តតិច្ចថៃ ក៏កំពុងតែធ្វើការរៀបចំនិង សំរួលដល់ពលករខ្មែរយើង ដែលកំពុងនិងធ្វើដំណើរវិលត្រលប់មកជួបជុំក្រុមគ្រួសាររបស់ខ្លួនក្នុងឱកាសចូលឆ្នាំថ្មី ប្រពៃណីខ្មែរយើងខាងមុខនេះហើយយើងខ្ញុំសូមអគុណដល់សមត្ថកិច្ច ទាំង ថៃ នឹង កម្ពុជា ដែលបានជួយសំរួល នឹងរៀបចំក្នុងការធ្វើតំណើររបស់ពលករកម្ពុជាហើយក៏សូមជូនតំណឹងដល់បងៗសមត្ថកិច្ចទាំងអស់ ថៃ នឹង ខ្មែរ ដែលមានទួលនាទី នៅតាមច្រក អន្តរជាតិ ក៏ដូចជា តាម របៀង

នោះសូមមេត្តា កុំបន្តអោយមានការ យកលុយ ទៅលើពលករខ្មែរយើង ដែលបានវិលមក ជួបជុំគ្រួសារ ដើម្បី ទទួលទេវតា ចូលឆ្នាំថ្មី ប្រពៃណីខ្មែរយើង ខាងមុខនោះអី។ ព្រោះក្រសួងការងារថៃនឹងសមត្ថកិច្ចថៃ នឹង អគ្គរាជទូត កម្ពុជានៅប្រទេស ថៃ នោះបានមានប្រសាសន៍ ហើយថា សូមឲ្យសមត្ថកិច្ច ថៃ ឬសមត្ថកិច្ច ខ្មែរ នៅតាមច្រក ព្រំដែនឡើយហាមយកលុយលើកម្មករ ខ្មែរដែលបានវិលមកចូលឆ្នាំថ្មីនេះដាច់ខាត់ ចាប់តាំងពីរថ្ងៃ ទី 05/ 04/ 2019 ដល់ថ្ងៃទី 30/04/2019។ ចំពោះបងប្អូនដែលមាន ប៉ាស្ព័រ ឯកសារ គ្រប់គ្រាន់នោះ ខ្ញុំបាទសូមឲ្យទេវតាឆ្នាំថ្មី ជូនពរជ័យសេរីសួស្តីដល់ពុកម៉ែបងប្អូនទាំងអស់សូមធ្វើតំណើរជួបតែសេចក្តីសុខទាំងទៅនឹងវិលត្រលបមកផង។ សូមអគុណា។ ជួយស៊ែនឹងចែករំលែកឲ្យពលករ ធ្វើការនៅប្រទេសថៃ បានដឹងផង។

## កម្ពុជាទទួលយកពលករខ្មែរឆ្លងដែនខុសច្បាប់ ០៥នាក់ ពីភាគីថៃ

https://www.facebook.com/ General-Department-of-Immigration-GDI 07/04/2019

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧ និង៤៥នាទី ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៥នាក់ ស្រី០២នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ថៃបញ្ជូនពលរដ្ឋខ្មែរ ០៣នាក់ ឲ្យមកកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General-Department-of-Immigration-GDI April 6 at 1:15 PM

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០៣នាក់ ឲ្យមកកម្លាំនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្មាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩

## សង្គមស៊ីវិលស្នើលោក ហ៊ុន សែន ឱ្យណែនាំមន្ត្រី កុំយកលុយពីពលករដែលមកលេងស្រុកនៅពេលចូលឆ្នាំ

https://www.rfa.org/khmer/news/ ដោយ ហេង វស្នី 2019-04-08

អង្គការសង្គមស៊ីវិលផ្នែកសិទ្ធិកម្មករចំណាកស្រុក ស្នើដល់មេដឹកនាំរបបក្រុងភ្នំពេញលោក ហ៊ុន សែន ឱ្យណែនាំដល់មន្ត្រីនៅតាមព្រំដែន កុំឱ្យយកលុយពីពលករខ្មែរដែលត្រឡប់មកលេងស្រុកកំណើត នៅអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិ។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក មឿន តុលា ថ្លែងថា រដ្ឋាភិបាលថៃបានអនុញ្ញាតឱ្យពលករបរទេសក្នុងនោះក៏មានពលករខ្មែរដែរ បានឈប់សម្រាក ដើម្បីវិលត្រឡប់ទៅស្រុកកំណើត ចូលរួមពិធីបុណ្យចូលឆ្នាំថ្មី។ លោកបន្តថា រដ្ឋាភិបាលថៃបានណែនាំមន្ត្រីរបស់ខ្លួន មិនឱ្យទារលុយពីពលករនៅពេលពួកគេឆ្លងដែនទៅលេងស្រុកកំណើតវិញនោះឡើយ ក៏ប៉ុន្តែបញ្ហាបែរជាកើតមាននៅខាងភាគីខ្មែរទៅវិញ។ មន្ត្រីសិទ្ធិការងាររូបនេះឱ្យដឹងថា ព័ត៌មានដែលអង្គការលោកទទួលបាននៅពេលនេះ គឺមានពលករមួយចំនួនបានត្អូញត្អែរថា ខាងមន្ត្រីខ្មែរនៅតែមានការទារលុយពីពួកគេ។ លោកថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គួរប្រាប់ទៅមន្ត្រីព្រំដែនខ្មែរ មិនត្រូវយកលុយកាក់ពីពលករចំណាកស្រុកឡើយ ព្រោះដើម្បីកាត់បន្ថយការចំណាយរបស់ពួកគេ ខណៈពលករមួយចំនួន បានចាប់ផ្តើមវិលមកស្រុកកំណើតវិញជាបណ្តើរៗ ហើយ៖ «ខ្ញុំគិតថា បញ្ហាពលករចំណាកស្រុក

នេះ គឺជាបញ្ហាមួយដែលថ្នាក់ដឹកនាំរដ្ឋាភិបាលប្រហែលជាភ្លេច អ៊ីចឹងទៅការដែលដឹងព័ត៌មានពីពលករមកហើយ គួរតែយើងប្រាប់បញ្ហានេះទៅដល់អ្នកដឹកនាំប្រទេសដែរ ព្រោះពលករចំណាកស្រុក(ខ្មែរ)ដែលនៅក្នុងប្រទេសថៃនេះមានរហូតដល់លាននាក់។ ហើយឆ្នាំនេះ គឺជាឆ្នាំមួយដែលយើងឃើញថា អាជ្ញាធរថៃបានសម្រួលច្រើន ហេតុដូច្នេះហើយបើយើងមិនជួយជ្រោមជ្រែងពួកគាត់ទេ ហាក់ដូចជាយើងបំភ្លេចគាត់ចោលអ៊ីចឹង»។

ការអំពាវនាវរបស់អ្នកការពារសិទ្ធិកម្មករចំណាកស្រុករូបនេះ ធ្វើឡើងក្រោយពេលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើកុំឱ្យមានការដំឡើងថ្លៃឈ្នួលរថយន្ត និងកន្លែងស្នាក់នៅ នៅអំឡុងពេលពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិនៅសប្តាហ៍ក្រោយនេះ។

លោក ហ៊ុន សែន ថ្លែងក្នុងហ្វេសប៊ុកនៅថ្ងៃទី៧ មេសា ដោយសំណូមពរដល់ម្ចាស់រថយន្តឈ្នួលកុំដំឡើងថ្លៃជិះរថយន្ត និងស្នើឱ្យម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់ កុំឱ្យដំឡើងថ្លៃស្នាក់នៅ ដើម្បីឱ្យប្រជាពលរដ្ឋ និងអ្នកទេសចរសន្សំសំចៃថវិកាបានខ្លះសម្រាប់ការចាយវាយ និងធ្វើបុណ្យក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៤ ដល់ទី១៦ មេសាខាងមុខនេះ។ បន្ថែមពីលើនេះ របបរបស់លោកក៏បានបញ្ចេញឡានក្រុងចំនួន ១២០ គ្រឿង ដើម្បីផ្តល់សេវាដឹកជញ្ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី១២ ដល់ទី១៨ មេសាផងដែរ។

ក្រសួងការងារអះអាងថា ពលករចំណាកស្រុកខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ មានចំនួនជាង ១លាន ១សែននាក់ ក៏ប៉ុន្តែអង្គការសង្គមស៊ីវិលវិញ អះអាងថា ពលរដ្ឋខ្មែរដែលធ្វើការនៅថៃ អាចមានរហូតដល់ ២ លាននាក់ បើរួមបញ្ចូលទាំងអ្នក ដែលទៅធ្វើការក្នុងលក្ខខណ្ឌមិនស្របច្បាប់។

ការងារដែលពលករខ្មែរធ្វើ ភាគច្រើនជាប្រភេទការងារបែបកខ្វក់ លំបាក និងគ្រោះថ្នាក់ (3D Job—Dirty, Dangerous, Demeaning) ហើយប្រាក់ឈ្នួលជាមធ្យមដែលពួកគាត់ទទួលបាន គឺប្រមាណ ៣០០ដុល្លារអាមេរិកក្នុងមួយខែ។

សកម្មជនសិទ្ធិការងារអះអាងថា ពលករខ្មែរនៅក្រៅប្រទេស ជាពិសេសនៅប្រទេសថៃនៅតែប្រឈមនឹងបញ្ហាជាច្រើន ជាពិសេស គឺការរំលោភបំពានសិទ្ធិការងារ។ ករណីទាំងនោះមានជាអាទិ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការធ្វើការក្នុងបរិយាកាសមិនល្អ និងមានគ្រោះថ្នាក់ ការហូតឯកសារពីសំណាក់និយោជក ឬថៅកែ និងការទូទាត់ប្រាក់ឈ្នួលមិនសមស្របទៅនឹងចំនួន ដែលពួកគាត់ត្រូវទទួលបានជាដើម៕

## ល្បីថាពលករខ្មែរធ្វើការនៅប្រទេសថៃធ្វើដំណើរត្រឡប់មកលេខស្រុក ចូលតាមច្រកទ្វារប៉ោយប៉ែត ត្រូវគេទាលុយម្នាក់ពី300 - 350បាត សូមលោកមន្ត្រីច្រកទ្វារមេត្តាមើលផង

https://www.facebook.com ព័ត៌មាន សុខភាព កម្សាន្ត និង រៀនភាសាថៃ 08-04-2019

បទពិសោធន៍មហាវេទនានៅច្រកប៉ោយប៉ែតខាងថៃនាថ្ងៃទី៥ មេសា ២០១៩ ចេញពីបាងកកម៉ោង៣យប់មកដល់ព្រំដែនពីព្រឹកមុនម៉ោង៧ មានអីឡើងណែន មិនមែនណែនដោយសារមនុស្សច្រើនហួសហេតុទេ គឺមន្ត្រីខាងត្រួតពិនិត្យនៅច្រកចេញពីថៃធ្វើការយឺត (របៀបអូសក្រឡា) ហើយបែរជាមានខ្មែរមួយក្រុមមិនដឹងជាតួនាទីស្អីទេនៅខាងទឹកដីថៃតម្រូវឱ្យអ្នកឆ្លងដែនពីថៃទៅខ្មែរទាំងលិខិតឆ្លងដែនកម្មករ និងទេសចរណ៍ គឺត្រូវតម្រង់ជួរនៅខាងក្រោម (កន្លងមកកន្លែងលិខិតឆ្លងដែនទេសចរណ៍ត្រូវទៅផ្សេង កម្មករផ្សេង) និងបង់លុយ 300-350បាត សម្រាប់ការឆ្លងបែប VIP ពេលនោះខ្ញុំឈរចាំមើល ហើយសួរថាអាហ្នឹងច្បាប់ទម្លាប់ខាងណាធ្វើអីចឹង? ពួកវាអត់ឆ្លើយទេ វាថា ចង់ទៅមុនទាល់តែ VIP ម្នាក់ 350បាត អ្នកខ្លះក៏អស់ 300បាតអីចឹងទៅ គឺអាអ្នកធ្វើហ្នឹងវាហាក់មានប្រព័ន្ធវាឱ្យធ្វើ ហើយដូចឡេមឡឺមពេលកំពុងធ្វើ។ ខ្ញុំឡូឡាអ៊ើរសួរដេញដោលដាក់ពួកយកលុយនោះ បន្ទាប់មកមានអ្នកផ្សេងក៏ឡូឡា ហើយអាក្រុមធ្វើស៊ីអ្នកឆ្លងចូលពីថៃទៅខ្មែរនោះឱ្យខ្ញុំទៅមុនដោយមិនបាច់បង់លុយ។

បញ្ជាក់៖ អ្នកចង់លឿន ចំណាយ 350បាត ទទួលបានក្រដាសមានសរសេរអក្សរខ្មែរមួយសន្លឹក ខ្ញុំស្មានតែសន្លឹកស្អី សួរទៅគឺគេថាក្រដាសជូនដំណឹងពីការឆ្លងដែនត្រឡប់ទៅស្រុកកំណើតដែលគេត្រូវជូនដំណឹងកម្មករ (ខ្ញុំក៏អត់ច្បាស់ដែរ ព្រោះសួរគេ មិនបានអាន ឬថតមកទេ) ម្នាក់ៗ អស់ 350បាត បានឡើងទៅលើ ហើយគិតថា VIP មានស្អីឡើងទៅលើកន្លែងវាយលិខិតឆ្លងដែនចេញ មនុស្សឡើងក្តាំងដែលខ្ញុំនិយាយថាមន្ត្រីខាងថៃធ្វើការអូសក្រឡាដើម្បីសម្រួលដល់អ្នកទារលុយ 350បាត។ រឿងដែលចុកឈាមនោះគឺអ្នក VIP ទាំងនោះទៅផ្តុំគ្នាឈរចាំដូចតែនៅក្រោមដែរ និយាយទៅគឺចញ់បោកគេធ្វើស៊ីម្នាក់ 350បាត រាប់រយនាក់ ហើយក្រដាសមួយសន្លឹកនោះ គ្មានបានការស្អីទេ។ តាំងពីម៉ោង ៧ព្រឹកដល់ម៉ោងជិត១០ព្រឹក ទើបខ្ញុំឆ្លងព្រំដែនបាន ពេលមានមេគេម្នាក់ខាងថៃមកស្រែកយកបុង ហើយថតរូបសង្ស័យបង្អួតមេលើថា ខ្លួនសស្រាក់សស្រាំធ្វើការណាស់។ ចុះទម្រាំថ្ងៃនេះរហូតដល់ចូលឆ្នាំ តើការឆ្លងដែនលំបាកយ៉ាងណាទៅ?។ ប្រភព. Channa Nuon BC Man

## កិច្ចប្រជុំស្តីពីកិច្ចសហប្រត្តិបត្តិការបង្ការទប់ស្កាត់បទល្មើសនៅលើខ្សែបន្ទាត់ព្រំដែន

http://gdlf-kh.com/ 08/04/2019 Dy Ramorn ខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរី÷ នៅព្រឹកថ្ងៃច័ន្ទ ៤កើត ខែ ចេត្រ ឆ្នាំ ច សំរិទ្ធស័ក ព.ស.២៥៦២ ត្រូវនិងថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៩នាវេលាម៉ោង ៨ៈ៣០ នាទីនៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី។ គណៈប្រតិភូនគរបាលនៃខេត្តប៊ិញហ្វឿកសាធារណៈរដ្ឋសង្គមនិយមវៀតណាមដឹកនាំដោយលោកវរសេនីយ៍ឯក វ៉ ហុងមិញ ស្នងការរងនគរបាលខេត្តប៊ិញហ្វឿក ជាប្រធានប្រត្តិភូរួមជាមួយសមាជិកប្រតិភូចំនួន១២រូបបានអញ្ជើញចូលរួមប្រជុំលើកិច្ចសហប្រត្តិបត្តិការបង្ការទប់ស្កាត់បទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែលប្រចាំឆ្នាំ២០១៨និងបន្តអនុវត្តន៍ក្នុងសហប្រត្តិបត្តិការឆ្នាំ២០១៩។ ភាគីកម្ពុជាដឹកនាំដោយលោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្តលោកវរសេនីយ៍ឯក ឆាយ សុខា ជំនួយការសេនាធិការអគ្គស្នងការនគរបាលជាតិរួមជាមួយសមាជិកប្រតិភូសរុបចំនួន ១៩នាក់។

ជាកិច្ចចាប់ផ្តើមបើកកិច្ចប្រជុំលោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្តបានអានសន្ទរកថាស្វាគន៍ចំពោះគណៈប្រតិភូនិងបានលើកឡើងពីសភាពការណ៍និងលទ្ធផលកិច្ចសហប្រត្តិបត្តិការបង្កាទប់ស្កាត់បទល្មើសនៅតាមខ្សែបន្ទាត់ព្រំដែនឆ្នាំ២០១៨ រវាងស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី(កម្ពុជា) និងស្នងការដ្ឋាននគរបាលខេត្តប៊ិញហ្វឿក(វៀតណាម) និងបន្តអនុវត្តន៍លើកិច្ចសហប្រត្តិបត្តិការណ៍ឆ្នាំ២០១៩បន្តទៀត។ ស្ថិតក្នុងឱកាសនោះផងដែរលោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្តបានលើកឡើងពីចំណងសាមគ្គីភាព និងកិច្ចសហប្រត្តិបត្តិការបង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទនៅតាមខ្សែបន្ទាត់ព្រំដែនក្នុងឆ្នាំ២០១៨ កន្លងមកនេះគឺភាគីនៃខេត្តយើងទាំងពីរបានសហការណ៍គ្នាបានយ៉ាងល្អប្រសើរ ក្នុងការទប់ស្កាត់បទល្មើសគ្រប់ប្រភេទនៅតាមខ្សែបន្ទាត់ព្រំដែនរវាងខេត្តយើងទាំងពីរ មិនតែប៉ុណ្ណោះឆ្នាំ២០១៩នេះ លោកឧត្តមសេនីយ៍ទោ ឡោ សុខា ស្នងការនគរបាលខេត្តបានសំណូមពរដល់ភាគីមិត្តបន្តសហការណ៍ទប់ស្កាត់បទល្មើសឆ្លងដែន ដែលបានឆ្លងកាត់ព្រំដែនទៅប្រទេសផ្សេងទៀត និងបន្តសហការណ៍ជួយស្កាត់ការជួញដូរស្ត្រីនិងកុមារឆ្លងដែនខុសច្បាប់ និងបន្តការទប់ស្កាត់ការជួញដូរគ្រឿងញៀនខុសច្បាប់ឆ្លងកាត់តាមខ្សែបន្ទាត់ព្រំដែន។

បន្ទាប់មកលោកវរសេនីយ៍ឯក វ៉ ហ៊ុងមិញ ស្នងការរងនគរបាលខេត្តប៊ិញហ្វឿកបានលើកឡើងពីកិច្ចសហប្រត្តិបត្តិរវាងស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរីនិងស្នងការដ្ឋាននគរបាលខេត្តប៊ិញហ្វឿក (វៀតណាម) ជានិច្ចជាកាលភាគីយើងទាំងពីរតែងតែសហការណ៍គ្នាបានល្អប្រសើរ ភាគីយើងទាំងពីរបានឯកភាពខ្ពស់ចំពោះលទ្ធផលដែលសំរេចបាននិងបញ្ហាដែលសេសសល់មួយចំនួនទៀតនៃកិច្ចសហប្រត្តិបត្តិបត្តិបង្ការទប់ស្កាត់និងបង្រ្កាបបទល្មើសប្រចាំឆ្នាំ២០១៨កន្លងមក ដូចបានបង្ហាញក្នុងរបាយការណ៍ក្នុងកិច្ចប្រជុំនេះយកទៅអនុវត្តន៍បន្តទៀតក្នុងកិច្ចសហប្រត្តិបត្តិការឆ្នាំ២០១៩បន្តទៀត។

ភាគីទាំងពីរបានចុះហត្ថលេខាលើកំណត់ហេតុ នៃកិច្ចប្រជុំស្តីពីកិច្ចសហប្រត្តិបត្តិការបង្ការទប់ស្កាត់បទល្មើសនៅលើខ្សែបន្ទាត់ព្រំដែនប្រចាំឆ្នាំ២០១៨និងកិច្ចសហប្រត្តិបត្តិការឆ្នាំ២០១៩។ មុននិងបញ្ចប់លោកវរសេន៍យ៍ឯក វ៉

ហ៊ុងមិញ ស្នងការរងខេត្តប៉ិញហ្វៀកបានជូននៅវត្តអនុស្សាវរីយ៍ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរដែលនៅសល់ប៉ុន្មានថ្ងៃខាងមុខនេះសូមអោយកម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរីទាំងមូលជួបតែសេចក្ដីសុខកុំបីឃ្លាងឃ្លាតឡើយ។

## ពលករខ្មែរជាង ២ ម៉ឺននាក់ ចេញពីថៃមកចូលរួមពិធីបុណ្យចូលឆ្នាំ

https://www.postkhmer.com/ ខន សាវិ | Publication date 09 April 2019 | 09:08 ICT

**បាត់ដំបង:** ចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ៧ ខែ មេសា មានពលករខ្មែរជាង ២ ម៉ឺននាក់ បានធ្វើដំណើរឆ្លងកាត់តាមច្រកទ្វារអន្តរជាតិដូងនៃខេត្តបាត់ដំបង ដើម្បីត្រឡប់មកលេងស្រុកកំណើតវិញនៅអំឡុងពិធីបុណ្យចូលឆ្នាំខាងមុខនេះ។ នៅច្រកទ្វារអន្តរជាតិនៅប៉ោយប៉ែត ឯណោះវិញ ត្រូវបានមន្ត្រីអះអាងថា ពុំទាន់មានពលករដែលសម្រុកធ្វើដំណើរចេញពីថៃច្រើននៅឡើយទេ។

លោក រស់ សារុំ ប្រធានមន្ទីរការងារខេត្តបន្ទាយមានជ័យ បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍នៅថ្ងៃម្សិលមិញថា តាមរបាយការណ៍ពីច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងមណ្ឌលសំចតសម្រាប់ទទួលពលករនៅក្រុងប៉ោយប៉ែត គឺមកដល់ពេលនេះ ពុំទាន់មានពលករខ្មែរដែលនាំគ្នាធ្វើដំណើរសម្រុកចេញច្រើនពីប្រទេសថៃ ដើម្បីមកលេងស្រុកកំណើតក្នុងពិធីបុណ្យចូលឆ្នាំនៅឡើយទេ ហើយពលករដែលចាប់ផ្ដើមសម្រុកចេញច្រើនពីប្រទេសថៃគឺអាចនៅថ្ងៃទី ១២ ទៅដល់ថ្ងៃទី ១៣ ខែ មេសា។ លោកថ្លែងថា៖ «ប៉ុន្មានថ្ងៃកន្លងមកនេះ ពលករដែលបានឆ្លងចូលប្រទេសយើងវិញ វាអត់ទៀងទេ មានថ្ងៃណាខ្លះមាន ១ ឡាន ហើយ ១ ឡានហ្នឹងមាន ៤០ នាក់អ៊ីចឹង ហើយថ្ងៃខ្លះ ក៏ ២ ឡាន តែបូកសរុបទៅ ២ ហ្នឹង មានគ្នាប្រហែល ៧ ទៅ ៨ នាក់ រហូតដល់ ១០ នាក់។ ម្យ៉ាងថ្ងៃនេះ គឺជាថ្ងៃទី ៨ ហើយពាក់ព័ន្ធនឹងច្បាប់ការងារមិនទាន់ដល់ថ្ងៃដែលកម្មករនិយោជិតសម្រាកនៅឡើយ»។

លោក សេម មករា នាយផ្នែកសេនាធិការនគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតបានបញ្ជាក់ថា លោកពុំមានតួលេខនៅក្នុងដៃអំពីចំនួនពលរដ្ឋដែលវិលត្រឡប់មកលេងស្រុកកំណើតនៅឡើយទេ។

ប៉ុន្តែបើតាមលោក រស់ សារុំ សព្វថ្ងៃពលរដ្ឋខ្មែរធ្វើដំណើរចេញចូលទៅថៃ គឺប្រើប្រាស់លិខិតឆ្លងដែនចំនួន ២ ប្រភេទទី១ ពលរដ្ឋខ្មែរដែលរស់នៅជាប់ព្រំដែនថៃ និងជាអាជីវករ គឺពួកគាត់ប្រើប្រាស់លិខិតឆ្លងដែនដែលទទួលស្គាល់ត្រឹមខេត្តសម្រាប់ចេញចូលព្រឹក-ល្ងាច ឬចេញចូលក្នុងរយៈពេល ១អាទិត្យម្ដង ចំណែកទី២ គឺពលរដ្ឋជាពលករដែលមានលិខិតឆ្លងដែន និងមានប័ណ្ណការងារ ដើម្បីចេញទៅធ្វើការតាមរោងចក្រ និងសហគ្រាស។ ការលើកឡើងរបស់ប្រធានមន្ទីរការងារខេត្តបន្ទាយមានជ័យនេះ ក្រោយពីមន្ត្រីនគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិដូងនៃស្រុកកំរៀង ខេត្តបាត់ដំបង បានអះអាងប្រាប់សារព័ត៌មានក្នុងស្រុកមួយថា គិតពីថ្ងៃទី ១ ដល់ថ្ងៃទី ៧ ខែមេសានេះ មានពលករខ្មែរចំនួន ២៥ ៤៧៥ នាក់ បានធ្វើដំណើរតាមច្រកទ្វារព្រំដែនរបស់ខេត្តបាត់ដំបងនេះ ដើម្បីវិលមកលេងស្រុកកំណើតអំឡុងពិធីបុណ្យចូលឆ្នាំខាងមុខ។

នគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិដូងអះអាងថា ក្នុងចំណោមពលករជាង ២ ម៉ឺននាក់នោះ គឺភាគច្រើនជាពលរដ្ឋនៅខេត្តបាត់ដំបង ហើយខ្លះទៀត មកស្រុកកំណើតនៅខេត្តកំពង់ធំ ពោធិ៍សាត់ កំពង់ឆ្នាំង ព្រៃវែង និងខេត្តស្វាយរៀង ដែលក្នុងនោះមួយចំនួនតូចជាអ្នកលួចធ្វើចំណាកស្រុកដោយខុសច្បាប់ដែរ ។

លោក អ៊ុច សុខុន ស្នងការនគរបាលខេត្តបាត់ដំបងបានលើកឡើងដែរថា នៅច្រកទ្វារអន្តរជាតិដូង ក្នុងរយៈពេលប៉ុន្មានថ្ងៃមកនេះ ពិតជាមានពលករច្រើនត្រឡប់មកកម្សាន្តសម្រាប់ពិធីបុណ្យចូលឆ្នាំនៅស្រុកកំណើតមែន ហើយនឹងមានពលរដ្ឋចូលមកបន្តបន្ទាប់ទៀតរហូតដល់ថ្ងៃចូលឆ្នាំតែម្ដង។ លោកថា៖ «គេមកស្រុកកំណើតចូលឆ្នាំបើកលុយបើកអីបាន គេឱ្យមកហើយ»។

យោងតាមរបាយការណ៍របស់ក្រសួងការងារកាលពីឆ្នាំ ២០១៨ មានពលករខ្មែរប្រមាណ ១ លាន ៧ ម៉ឺននាក់ ដែលទទួលបានឯកសារស្របច្បាប់ និងកំពុងធ្វើការងារនៅតាមរោងចក្រ សហគ្រាស នៅក្នុងវិស័យសំណង់ នេសាទ និងកសិកម្មនៅក្នុងប្រទេសថៃ៕

# ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

## ពលករថា សមត្ថកិច្ចច្រកអន្តរជាតិដូងយកប្រាក់ពីពួកគាត់ ជាថ្នូរបានឆ្លងដែនត្រឡប់នៅលេងបុណ្យចូលឆ្នាំខ្មែរ

https://www.rfa.org/khmer/news/ ដោយ ហេង វស្នី 2019-04-09

ពលករខ្មែរធ្វើការនៅប្រទេសថៃរាប់ពាន់នាក់ នាំគ្នាសម្រុកឆ្លងដែនត្រឡប់មកលេងបុណ្យចូលឆ្នាំប្រពៃណីជាតិនៅស្រុកកំណើតតាមច្រកព្រំដែនអន្តរជាតិដូង ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង។ ប៉ុន្តែពលករត្អូញត្អែរថា សមត្ថកិច្ចខ្មែរ និងថៃប្រចាំច្រកនេះប្រព្រឹត្តអំពើពុករលួយដោយបង្ខំឱ្យពួកគាត់បង់ប្រាក់ក្រៅផ្លូវការម្នាក់ប្រមាណ ១០ដុល្លារ ដើម្បីជាថ្នូរអនុញ្ញាតឱ្យឆ្លងដែន។ មន្ត្រីសង្គមស៊ីវិល ចាត់ទុកទង្វើនេះថា ជាអំពើពុករលួយកេងចំណេញពីពលករដោយខុសច្បាប់។

ពលករពីស្រុកថ្មគោលខេត្តបាត់ដំបង លោក ហេង ចាន់ហ៊ាញ ប្រាប់អាស៊ីសេរីនៅថ្ងៃទី៩ មេសាថា លោក និងភរិយាធ្វើការងារនៅប្រទេសថៃប្រមាណ ១០ឆ្នាំ គឺមានទាំងការងារសំណង់ និងក្នុងការងាររោងចក្រ។ លោកបន្តថា សព្វលោកធ្វើការក្នុងរោងចក្រផលិតទូទឹកកកនៅខេត្តឈុនបូរី (Chonburi) ប្រទេសថៃ ដោយបានប្រាក់ឈ្នួលប្រមាណ ១ពាន់បាត ឬស្មើប្រមាណ ៤៥០ដុល្លារអាមេរិកក្នុងមួយខែ។ ពលកររូបនេះថា លោកសប្បាយចិត្តណាស់នៅពេលបានត្រឡប់ទៅលេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរនៅស្រុកកំណើត ក៏ប៉ុន្តែការសប្បាយរបស់លោកបានរសាត់ទៅវិញមួយរំពេចនៅពេលត្រឡប់មកដល់ច្រកព្រំដែនអន្តរជាតិដូង ដោយសមត្ថកិច្ចថៃបានបង្ខំឱ្យពួកគាត់បង់ប្រាក់ម្នាក់ ២០០បាត ឬស្មើប្រហែល ៦ដុល្លារអាមេរិក និងខាងប៉ូលិសខ្មែរយកប្រាក់ ១០០បាត ស្មើជាង ៣ដុល្លារក្នុងម្នាក់៖ «បើឱ្យលុយមានបញ្ហាហើយ ព្រោះអីពេលនោះគេឱ្យពលករផ្តុំគ្នាមួយកន្លែង បើគ្នាមាន ១ពាន់ គេមានរោង ៤ជួរ ដោយឱ្យពលករចូលទៅអង្គុយទីនោះទាំង ៤ជួរ រួចហើយគេដើរឆ្លងដែនម្តងមួយជួរ។ ដូច្នេះពេលនោះទាំងនិយាយ និងកាយវិការធ្វើឱ្យពលករខ្លាច ដោយខ្លាចមានបញ្ហាពេលត្រឡប់មកវិញ ព្រោះអ្នកខ្លះខ្វះចំណេះដឹង និងខ្លះគិតថាមិនចង់មានរឿងឱ្យលុយគេទៅ។ ខ្ញុំគិតបើសិនជាទាំងគ្នារាប់ពាន់ហ្នឹងតវ៉ាប្រហែលជាបានជោគជ័យ»។

ពលករខ្មែរជាច្រើននាក់បានត្អូញត្អែរអំពីប៉ូលិសច្រកព្រំដែនអន្តរជាតិ ដូង ស្រុកកំរៀង បង្ខំឱ្យពួកគាត់បង់ប្រាក់ក្រៅផ្លូវការនេះស្ទើរគ្រប់គ្នា ហើយបានប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍របស់ពលករទៀតផង។

ពលករខ្មែរម្នាក់ទៀតលោក លន់ សំណាង ថ្លែងថា លោកធ្វើការនៅថៃជាង ១០ឆ្នាំហើយ គឺមិនដែលជួបប្រទះដូចឆ្នាំនេះទេ ដែលប៉ូលិសខ្មែរ និងថៃប្រចាំច្រកអន្តរជាតិ ដូង ហាក់ដូចជាសហការគ្នាយកលុយពីពលករឆ្លងដែនត្រឡប់មកលេងបុណ្យចូលឆ្នាំខ្មែរ។ លោកបន្តថា ប៉ូលិសហាមមិនឱ្យពួកគាត់កាន់ទូរស័ព្ទជាប់ដៃនោះទេ ដោយខ្លាចពួកគាត់ថតរូបភាពសមត្ថកិច្ចយកប្រាក់ពីពលករ៖ «គេថា បើសិនយើងមិនឱ្យលុយគេទេ គឺគេមិនឱ្យចេញ ឬមួយគេដកលិខិតឆ្លងដែនទុក ឬមួយគេហែកចោលតែម្តង គឺខ្ញុំជួបបញ្ហានេះផ្ទាល់ហើយ។ ខ្ញុំនៅរង់ចាំ ៥ម៉ោងទម្រាំបានចេញ ហើយពេលចេញ គឺចង្អៀតណែនខ្លាំងណាស់ ហើយអ្នកខ្លះសុខភាពមិនល្អ អាចដួលសន្លប់ក៏មានដែរ។ ប៉ុន្តែគេមិនឱ្យយើងថតរូបឬថតវីដេអូទេ»។

ចំណែកពលករខ្មែរធ្វើការនៅប្រទេសថៃម្នាក់ទៀត លោក នេត ភិរម្យ អះអាងថា លោកធ្វើដំណើរពីកន្លែងធ្វើការនៅខេត្តឈុនបូរី (Chonburi) មកដល់ព្រំដែនម៉ោង ១០ព្រឹកថ្ងៃទី៨ មេសា ហើយបានឆ្លងដែនមកដល់កម្ពុជានៅព្រឹកថ្ងៃដដែលនេះ។ លោកថា ប៉ូលិសខ្មែរ និងថៃយកពីលោកម្នាក់ ៣០០បាត ឬប្រមាណ ១០ដុល្លារអាមេរិក៖ «គឺគេឱ្យយើងដើរតម្រង់ជាជួរដើរទៅហើយគេយកលុយយើងតែម្តង។ គេនិយាយប្រាប់ថា បង់ម្នាក់ ២០០បាតនៅទឹកដីថៃ ហើយមកដល់ខ្មែរប៉ូលិសយើងពលករដើរទៅបង់លុយនៅកន្លែងគេដាក់ចាំនៅច្រកនោះ។ រឿងនេះវាមិនសមទេ ព្រោះខ្ញុំធ្វើការមួយថ្ងៃបានតែ ៣០០បាត ហើយគាត់អង្គុយចាំ តែយកលុយពីពលករ យើងមិនដឹងថា លុយនោះគាត់យកទៅណាទេ»។

ឆ្លើយតបនឹងបញ្ហានេះ មន្ត្រីប៉ូលិសអន្តោប្រវេសន្តប្រចាំការនៅច្រកអន្តរជាតិដូង ស្រុកកំរៀង លោក សុខ គុណ មានប្រសាសន៍ប្រាប់អាស៊ីសេរីថា សមត្ថកិច្ចនៃប្រទេសទាំង២ បានសម្រួលឱ្យពលករឆ្លងដែនបានឆាប់រហ័ស ដោយមិនមានបញ្ហាអ្វីនោះទេ។ ចំណែកការយកលុយយកកាក់ពីពលករវិញលោកអះអាងថា រឿងនេះជាទឹកចិត្ត អាណិតស្រលាញ់របស់ពលករទេ គឺមិនមែនប៉ូលិសបង្ខំពួកគេឱ្យបង់ប្រាក់ដូចការចោទប្រកាន់នោះឡើយៈ «នឹងថ្លៃ ទឹកតែសម្រួលរឿងមិនយកថ្លៃវីសា និយាយឱ្យចំ គឺមិនដែលមានបញ្ហាអីផង គឺវារលូន គឺមិនមានការងារអីឱ្យរាំងស្ទះទេ គឺងាយស្រួលជាងឆ្នាំមុនៗ នោះទេ។ អ្នកប្រថាប់ត្រាលើលិខិតឆ្លងដែនតិចតួចទេ អ្នកប្រថាប់ត្រាភាគច្រើនខាងក្រុម ហ៊ុនគេបញ្ជាឱ្យប្រថាប់ត្រា ដើម្បីងាយស្រួលគេត្រួតពិនិត្យមើលពលករណា ដែលចេញមកលេងខ្មែរ ប៉ុន្តែពួកគាត់នៅ តែទទួលបានទិដ្ឋាការរយៈពេល ២ឆ្នាំដដែលទេ»។

ទោះយ៉ាងណាមន្ត្រីអង្គការសង្គមស៊ីវិលធ្វើការងារផ្នែកការពារសិទ្ធិពលករលើកឡើងថា បញ្ហានេះជាអំពើពុក រលួយឱកាសនិយមគាបសង្កត់ធ្វើបាបពលករចំណាកស្រុកដោយខុសច្បាប់ ព្រោះក្រសួងការងារថៃអនុញ្ញាតឱ្យពលករ ខ្មែរ ថៃ និងភូមា ឈប់សម្រាកបានទៅលេងបុណ្យចូលឆ្នាំនៅស្រុកកំណើត ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ មេសា ដោយ មិនចំណាយប្រាក់ថ្លៃធ្វើទិដ្ឋាការនៅច្រកព្រំដែនឡើយ។

មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក ឌី ថេហូយ៉ា ថ្លែងថា នៅតាមច្រកព្រំដែន ជាពិសេស ច្រកធំៗ ដូចជា ច្រកដូង ប៉ោយប៉ែត ច្រកភ្នំដី ក្នុងស្រុក សំពៅលូន និងច្រកអន្តរជាតិព្រំខេត្តប៉ៃលិនជាដើម ជាកន្លែងដែលពលករខ្មែរឆ្លងដែនមកលេងស្រុកកំណើតរាប់ពាន់ នាក់ក្នុងមួយថ្ងៃ។ លោកបន្តថា សមត្ថកិច្ចច្រកទាំងអស់នេះ បានអនុវត្តផ្ទុយពីសេចក្តីប្រកាសរបស់រដ្ឋាភិបាលថៃ ដែល បានណែនាំមន្ត្រីរបស់ខ្លួន មិនឱ្យទារលុយពីពលករ នៅពេលពួកគេឆ្លងដែនទៅលេងស្រុកកំណើតវិញនោះ។ មន្ត្រី សង្គមស៊ីវិលរូបនេះស្នើសុំឱ្យរដ្ឋាភិបាលក្រុងភ្នំពេញ ចាត់វិធានការលើរឿងនេះជាបន្ទាន់ ព្រោះបានប៉ះពាល់យ៉ាងខ្លាំង ដល់សតិអារម្មណ៍របស់ពលករ ហើយក៏ជាការជួយសម្រួលដល់ការធ្វើដំណើររបស់ពលករត្រឡប់មកលេងបុណ្យចូល ឆ្នាំខ្មែរឱ្យបានឆាប់៖ «បើខាងថៃ វិញជាគោលការណ៍ពលរដ្ឋគេ គឺគេត្រៀមបញ្ចុះតម្លៃឡានឈ្នួល ហើយថែមចំនួន ឡានដឹកអ្នកដំណើរដើម្បីជួយសម្រួលឱ្យពលរដ្ឋគេបានទៅជួបជុំបងប្អូននៅស្រុកកំណើត។ ប៉ុន្តែដោយឡែកបើខាង ខ្មែរវិញ យើងមើលទៅហាក់ដូចជាមិនសូវអើពើ ព្រោះយើងដឹងហើយថា ពលករធ្វើការនៅស្រុកថៃរាប់លាននាក់ឯ ណោះ ហើយវាគួរតែមានគោលនយោបាយសម្រាប់ជួយសម្រួលឱ្យពលករយើងបានធ្វើដំណើរស្រួលដោយមិនបាច់ បង់លុយនៅព្រំដែន និងសម្រួលនៅច្រកព្រំដែនឱ្យឆាប់បានចេញទៅដល់ស្រុកកំណើត ព្រោះអ្នកខ្លះរង់ចាំពេលមួយ ថ្ងៃមិនបានចេញមកក៏មានដែរ»។

ការងារដែលពលករខ្មែរធ្វើ ភាគច្រើនជាប្រភេទការងារបែបកខ្វក់ លំបាក និងគ្រោះថ្នាក់ (3D Job-Dirty, Dangerous, Demeaning) ហើយប្រាក់ឈ្នួលជាមធ្យម ដែលពួកគាត់ទទួលបាន គឺប្រមាណ ៣០០ដុល្លារអាមេរិក ក្នុងមួយខែ។ អង្គការសង្គមស៊ីវិលអះអាងថា ពលករខ្មែរនៅក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ នៅតែប្រឈមបញ្ហា ជាច្រើន ជាពិសេស គឺការរំលោភបំពានសិទ្ធិការងារ។ ករណីទាំងនោះមានជាអាទិ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការ ធ្វើការក្នុងបរិយាកាសមិនល្អ និងមានគ្រោះថ្នាក់ ការហូតឯកសារពីសំណាក់និយោជក ឬថៅកែ និងការទូទាត់ប្រាក់ ឈ្នួលមិនសមស្របទៅនឹងចំនួន ដែលពួកគាត់ត្រូវទទួលបានជាដើម។ ពលករទាំង ៣នាក់អះអាងថា ពួកគេខំប្រឹងធ្វើ ការងារសន្សំប្រាក់មិនហ៊ានឈប់សម្រាកនោះទេ ហើយជាទូទៅក្នុងមួយឆ្នាំ ពួកគេមានឱកាសបានមកលេងស្រុក កំណើតម្តងក្នុងពេលបុណ្យចូលឆ្នាំខ្មែរ។

មន្ត្រីប៉ូលិសច្រកទ្វារព្រំដែនអន្តរជាតិដូងឱ្យដឹងថា ពលករសម្រុកឆ្លងដែនខ្លាំងតាមច្រកមួយនេះចាប់ពីថ្ងៃទី៧ មេសាមក មានបន្លោះពី ៥ ទៅ ៦ពាន់នាក់ក្នុងមួយថ្ងៃ។

ក្រសួងការងារអះអាងថា ពលករចំណាកស្រុកខ្មែរ ដែលកំពុងធ្វើការនៅប្រទេសថៃ មានចំនួនជាង ១លាន ១សែននាក់។ ក៏ប៉ុន្តែអង្គការសង្គមស៊ីវិលវិញ អះអាងថា ពលរដ្ឋខ្មែរដែលធ្វើការនៅថៃ អាចមានរហូតដល់ ២លាននាក់ ដោយរាប់បញ្ចូលទាំងពលករធ្វើការក្នុងលក្ខខណ្ឌមិនស្របច្បាប់៕

## ពលករសម្រុកចេញទៅស្រុកកំណើត ដើម្បីចូលឆ្នាំខ្មែរតាមច្រកព្រំខេត្តប៉ៃលិនដូចទឹកបាក់ទំនប់

http://www.rasmeinews.com/ April 10, 2019, 9:28 AM

*ដោយៈគ្រញូង/ប៉ៃលិន ៖* កាលពីព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ស្ថិត នៅច្រកទ្វារអន្តរជាតិព្រំ ក្នុងភូមិព្រំយុំ ស្ទឹងកាច់ ស្រុកសាលាក្រៅ មានពលករខ្មែរដែលទៅធ្វើការងារនៅប្រទេសថៃនានា នាំគ្នាទាំងចាស់ទាំងក្មេងសម្រុកចេញទៅ ស្រុកកំណើតដើម្បីជួបជុំក្រុមគ្រួសារក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនាពេលខាងមុខនេះ។

មន្ត្រីប៉ុស្តិ៍អន្តោប្រវេសន៍ប្រចាំច្រកទ្វារអន្តរជាតិផ្សារព្រំបានឱ្យដឹងថា ឱ្យតែជិតដល់រដូវបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ គឺពលករក្មេងចាស់ប្រុសស្រីជាច្រើននាក់ សម្រុកឆ្លងដែនចូលមកក្នុងទឹកដីប្រទេសខ្មែរ ដោយអ្នកខ្លះមានទាំងអីវ៉ាន់ សម្ភារប្រើប្រាស់ ផ្ទាំង ចាន គ្រឿងបំពងសំឡេងជាដើម វេចខ្ចប់យ៉ាងល្អ ក្នុងគោលបំណងយកទៅរាំលេងកម្សាន្តនាថ្ងៃបុណ្យចូលឆ្នាំខ្មែរ។ មន្ត្រីដដែលបានបន្តថា ការឆ្លងដែនចូលមកក្នុងទឹកដីប្រទេសកម្ពុជាវិញ មិនមានការបង់លុយទេ។

ដោយឡែកលោកសុខ សាវុធ ប្រធានការិយាល័យច្រកទ្វារអន្តរជាតិព្រំបានឱ្យដឹង ថា រហូតមកដល់ឥឡូវនេះ មានពលករជាច្រើនពាន់នាក់ ដែលរស់នៅតាមបណ្ដា ខេត្តនានាក្នុងប្រទេសកម្ពុជាបាននាំគ្នាធ្វើដំណើរឆ្លងកាត់ច្រកទ្វារអន្តរជាតិព្រំ ដែល ក្នុង១ថ្ងៃៗ ប្រជាពលរដ្ឋខ្មែរចូលមកចំនួន២០០នាក់ ជួនកាល៣០០នាក់ ហើយថ្ងៃខ្លះ ទៀត រហូតដល់៤០០នាក់ជាបន្តបន្ទាប់ឥតដាច់តាមរយៈក្រុមហ៊ុន ដឹកជញ្ជូនមួយប្រចាំនៅក្បែរនោះតែម្តង៕B/Ha

## ប្តឹងមន្ត្រីច្រកទ្វារប៉ោយប៉ែត ទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយ អំពីករណីយកលុយពីពលករក្នុងម្នាក់ចំនួន

http://vdoamazing.com/ sky | April 9, 2019 | General News

យោងតាមរយៈគេហទំព័រ សារព័ត៌មាន Town News បានប្រាប់ឱ្យដឹងថា លោកហ៊ាង គឹមស្រឿន ដែលជាអ្នកវិភាគនយោបាយដ៏ល្បីឈ្មោះ និងជាអ្នកឃ្លាំមើលការអនុវត្តព្រឹត្តិការណ៍សង្គម នឹងដាក់ពាក្យបណ្ដឹងជូនលោក ឱម យិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ដោយស្នើសុំបើកការស៊ើបអង្កេតលើប្រធានច្រកទ្វារប៉ោយប៉ែត និងមន្ត្រីមួយចំនួនទៀត ពាក់ព័ន្ធនៅក្នុងករណីទទួលយកលុយពីប្រជាពលរដ្ឋ ដែលជាពលករចំណាក់ស្រុកក្នុងម្នាក់ៗ ៣៥០បាត ដោយមិនមានចេញឯកសារច្បាស់លាស់ ដែលចាត់ទុកជាការប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធក្នុងការបំពេញការងារ សម្រាប់សេវាកម្មសាធារណៈរបស់រដ្ឋ។

ពាក្យបណ្តឹងប្តឹងរបស់ លោក ហ៊ាង គឹមស្រឿន ដែលនឹងដាក់ពាក្យបណ្តឹង ប្តឹងប្រធានច្រកទ្វារប៉ោយប៉ែត នឹងដាក់ទៅអង្គភាពប្រឆាំងអំពើពុករលួយនៅថ្ងៃស្អែកនេះ ទី១០ ខែមេសា ឆ្នាំ២០១៩ ដោយលោក ហ៊ាង គឹមស្រឿន បានជម្រាបជូនប្រធានអង្គភាពប្រឆាំងអំពើពុករលួយ លោក ឱម យិនទៀង ថា៖ ”កាលពីពេលថ្មីៗនេះ ឃើញមានមន្ត្រីច្រកទ្វារប៉ោយប៉ែតបានធ្វើសកម្មភាពយកលុយពីពលករក្នុងម្នាក់ៗចំនួន៣៥០បាត គ្មានឯកសារច្បាស់លាស់សម្រាប់ជាថវិការដ្ឋ ដែលអំពើនេះចាត់ទុកជាការប្រព្រឹត្តអំពើពុករលួយជាលក្ខខណៈប្រព័ន្ធដែលត្រូវតែអង្គភាពប្រឆាំងអំពើពុករលួយគួរមានវិធានការផ្លូវច្បាប់ បើកការស៊ើបអង្កេតកោះហៅមន្ត្រីពាក់ព័ន្ធ និងមន្ត្រីបក្ខពួកខាងលើអោយមកចូលខ្លួនបំភ្លឺនៅចំពោះអង្គភាពតាមនីតិវិធីច្បាប់ជាធរមាន”៕

## តំណាង ឯកអគ្គរាជទូត កម្ពុជា ប្រចាំ ប្រទេស ថៃ ចុះសួរសុខទុក្ខពលករខ្មែរចំនួន០៧ នាក់ កំពុង ជាប់ ឃុំ ក្នុង ពន្ធនាគារ ណងប៉ាឡៃ

https://www.facebook.com/officillabour/ แรงงานกัมพูชา 10-04-2019

នៅព្រឹកថ្ងៃពុធ ទី១០ខែមេសា ឆ្នាំ២០១៩ តំណាងឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ សហការជាមួយមូនិធិលើកកម្ពស់គុណភាពជីវិត និងសុខមាលភាពពលករ (LPN) ចុះសួរសុខទុក្ខពលករខ្មែរចំនួន០៧ នាក់ កំពុងជាប់ឃុំក្នុងពន្ធនាគារណងប៉ាឡៃ ស្ថិតក្នុងស្រុកបាងឡាម៉ុង ខេត្តឈុនបុរី ជាប់ពីបទរួមគ្នាប្រើប្រាសឧបករណ៍នេសាទត្រីនៅលើតំបន់ហាមឃាត់កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩កន្លងទៅ ។ លទ្ធផលចុះសួរសុខទុក្ខ៖

1-ជំរុញឲ្យនិយោជកចូលដោះស្រាយថ្លៃផាកពិន័យតាមផ្លូវច្បាប់

2-ត្រូវអោយនិយោជកបើកប្រាក់ខែដែលនៅសេសសល់ជូនពលករទាំងតាមការកំណត់។

3-តាមដាននិតិវិធី ឃុំខ្លួន ។

4-ជំរុញឲ្យអោយដោះលែងពលករទាំងអស់អោយនៅក្រៅឃុំ។

## ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩

### FBI និងប៉ូលិសកម្ពុជាចុះកិច្ចព្រមព្រៀងសហការបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន

https://khmer.voanews.com/ 11 មេសា 2019 ម៉ែន គឹមសេង

ដោយមានកិច្ចសហប្រតិបត្តិការនិងការផ្តល់ព័ត៌មានពី FBI ក្នុងពេលកន្លងមកប៉ូលិសកម្ពុជាបានចាប់ខ្លួនជនល្មើស ដែលរត់គេចចេញពីសហរដ្ឋអាមេរិកទៅពួននៅកម្ពុជា និងបានសហការបង្ក្រាបករណីឧក្រិដ្ឋជាច្រើន ដូចជាទេសចរអាមេរិកទៅស្វែងរកសេវាផ្លូវភេទជាមួយនឹងអនីតិជននៅកម្ពុជាជាដើម។

វ៉ាស៊ីនតោន៖ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) របស់សហរដ្ឋអាមេរិកបានបោះជំហានមួយទៀត ក្នុងការពង្រឹងប្រតិបត្តិការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនតាមរយៈការចុះកិច្ចព្រមព្រៀងមួយជាមួយនឹងអាជ្ញាធរប៉ូលិសកម្ពុជា។ ការចុះហត្ថលេខាលើអនុស្សារណៈស្តីពីកិច្ចសហប្រតិបត្តិការបានធ្វើឡើងរវាងលោក Christopher Wray នាយកការិយាល័យ FBI លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិកម្ពុជា និងលោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍ ក្រសួង មហាផ្ទៃ នៅរដ្ឋធានីវ៉ាស៊ីនតោន កាលពីថ្ងៃសុក្រសប្តាហ៍មុន។ នេះបើតាមការបញ្ជាក់របស់មន្ត្រីប៉ូលិសកម្ពុជា និង FBI។

លោកស្រី Kelsey Pietranton អ្នកនាំពាក្យ FBI បានបញ្ជាក់ប្រាប់ VOA តាមសារអេឡិកត្រូនិក កាលពីថ្ងៃអង្គារថា FBI មានមោទនភាពដែលបានធ្វើទំនាក់ទំនងការងារជាមួយនឹងអាជ្ញាធរប៉ូលិសកម្ពុជា។ លោកស្រី Pietranton បានបន្ថែមថា៖ «អនុស្សារណៈស្តីពីការយោគយល់គ្នារវាង FBI ប៉ូលិសជាតិកម្ពុជា និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ចងក្រងបាននូវកិច្ចសហប្រតិបត្តិការ ដែលមានស្រាប់របស់យើងលើបញ្ហាជាច្រើន ក្នុងនោះមានឧក្រិដ្ឋកម្មប្រឆាំងនឹងកុមារ បទល្មើសបច្ចេកវិទ្យា ឧក្រិដ្ឋកម្មហិរញ្ញវត្ថុ និងការចាប់ខ្លួនជនរត់គេចពីសំណាញ់ច្បាប់ ហើយអនុស្សារណៈនេះក៏ពង្រឹងបន្ថែមការប្តេជ្ញាចិត្តរបស់ FBI ក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារសិទ្ធិមនុស្ស»។

លោក គៀត ច័ន្ទថារិទ្ធ អគ្គនាយកអន្តោប្រវេសន៍កម្ពុជា បានបញ្ជាក់ប្រាប់ VOA ថា៖ «ការចុះហត្ថលេខានេះបង្ហាញថា កិច្ចសហប្រតិបត្តិការរវាងសហរដ្ឋអាមេរិកនិងកម្ពុជាគឺនៅតែបន្ត ហើយថែមទាំងមានការស្អិតរមួត ឬក៏ខិតជិតគ្នាកាន់តែខ្លាំងថែមទៀត ជាពិសេសនៅក្នុងវិស័យអនុវត្តច្បាប់របស់ប្រទេសទាំងពីរហ្នឹងហើយដែលយើងនិយាយថា តាមរយៈនៃការចុះហត្ថលេខាលើអនុស្សារណៈហ្នឹង វានឹងនាំឱ្យយើងសហប្រតិបត្តិការដើម្បីបង្ការទប់ស្កាត់

សកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ដើម្បីសន្តិសុខសុវត្ថិភាពប្រទេសយើងទាំងពីរ ហើយវានឹងការពារផលប្រយោជន៍របស់ប្រជាជន ក៏ដូចជាប្រទេសទាំងពីរដែរ»។

លោកឧត្តមសេនីយ៍ឯក ពៅ សាលីដេត ជំនួយការលោក នេត សាវឿន និងជាអនុប្រធានសេនាធិការប៉ូលិសកម្ពុជា ដែលបានចូលរួមក្នុងពិធីចុះហត្ថលេខាបានបញ្ជាក់ប្រាប់ VOA ថា នេះគឺជាអនុស្សារណៈទី១ ដែលសហរដ្ឋអាមេរិកបានចុះជាមួយនឹងប្រទេសនានា ដោយចាប់ផ្តើមពីប្រទេសកម្ពុជាមុនគេ ដើម្បីបង្កើតក្រុមការងារសម្រាប់ធ្វើប្រតិបត្តិការ ព្រោះក្នុងពេលកន្លងមកគឺមានត្រឹមតែអនុស្សារណៈនៃការយោគយល់ស្តីពីការជួយគ្នាទៅវិញទៅមក ដែលមានជាលក្ខណៈមួយទូលំទូលាយគឺអត់មានលក្ខណៈពិស្តារជាប្រតិបត្តិការទេ។ លោកបានបន្ថែមថា៖ «តាមប្រសាសន៍របស់ការិយាល័យរបស់ឯកឧត្តមប្រធាន FBI គាត់បានបញ្ជាក់ថាMOU នេះគឺជា MOU លើកទី១ ដែល FBI ចុះជាមួយប្រទេសបរទេសដើម្បីបង្កើតក្រុមការងារប្រតិបត្តិការការងារតែម្តង។ អីចឹងគឺគេយកប្រទេសកម្ពុជាយើងជាប្រទេសមួយគំរូសម្រាប់ដល់ប្រទេសដទៃទៀត ដើម្បីអនុវត្តនាពេលខាងមុខផងដែរ»។

បច្ចុប្បន្នការិយាល័យអនុព័ន្ធផ្នែកច្បាប់របស់ FBI នៅទីក្រុងភ្នំពេញ ធ្វើសកម្មភាពខាងផ្នែកសម្របសម្រួលការស៊ើបអង្កេតជាអន្តរជាតិជាមួយសហការី តាមដានរកមើលមុខសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតក្នុងសហរដ្ឋអាមេរិក។ នេះបើតាមការបញ្ជាក់នៅក្នុងគេហទំព័រស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅរាជធានីភ្នំពេញ។ ការិយាល័យអនុព័ន្ធនេះក៏ធ្វើការភ្ជាប់គ្នារវាងលើផ្នែកភេរវកម្ម និងឧក្រិដ្ឋកម្មសំខាន់ៗ ដើម្បីធានាសុវត្ថិភាពដល់សាធារណៈជនអាមេរិកាំងនៅទីនោះ និងនៅបរទេសដោយធ្វើសកម្មភាពរួមគ្នា និងការចែករំលែកព័ត៌មានគ្នា ក៏ដូចជាសម្របសម្រួលវគ្គបណ្តុះបណ្តាល របស់ FBI ចំពោះនគរបាលនៅតាមតំបន់ ដែលមានរាប់តាំងពីការប្រឆាំងភេរវកម្ម និងបទឧក្រិដ្ឋតាមប្រព័ន្ធអ៊ិនធឺណិត រហូតដល់បច្ចេកទេសធ្វើកោសល្យវិច័យ ការជួញដូរមនុស្សនិងសិទ្ធិមនុស្សជាដើម។

ដោយមានកិច្ចសហប្រតិបត្តិការនិងការផ្តល់ព័ត៌មានពី FBI ក្នុងពេលកន្លងមកប៉ូលិសកម្ពុជាបានចាប់ខ្លួនជនល្មើស ដែលរត់គេចចេញពីសហរដ្ឋអាមេរិកទៅពួននៅកម្ពុជា និងបានសហការបង្ក្រាបករណីឧក្រិដ្ឋជាច្រើន ដូចជាទេសចរអាមេរិកទៅស្វែងរកសេវាផ្លូវភេទជាមួយនឹងអនីតិជននៅកម្ពុជាជាដើម។ នេះបើតាមសេចក្តីរាយការណ៍នានារបស់ FBI។

សហរដ្ឋអាមេរិកក៏បានវាយតម្លៃដែរថា ប្រទេសកម្ពុជាគឺជាប្រភព ជាកន្លែងឆ្លងកាត់និងជាប្រទេសគោលដៅនៃថ្នាំញៀនខុសច្បាប់ផងដែរ។ មានជនបរទេសជាច្រើនក្នុងនោះមានពលរដ្ឋអាមេរិកាំងកំពុងជាប់ពន្ធនាគារនៅកម្ពុជាពាក់ព័ន្ធនឹងគ្រឿងញៀន។

លោកគៀត ច័ន្ទថារិទ្ធ បានបញ្ជាក់បន្ថែមទៀតថា កិច្ចសហប្រតិបត្តិការកន្លងមកលើផ្នែកអន្តោប្រវេសន៍បានបានល្អផងដែរ៖ «ពីមុនមកទល់ពេលនេះទាំងអគ្គស្នងការនគរបាលជាតិ ទាំងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ គឺយើងបានសហការគ្នាល្អជាមួយស្ថាប័នមានសមត្ថកិច្ចអនុវត្តច្បាប់របស់ប្រទេសអាមេរិក ជាពិសេសតំណាងប្រចាំនៅស្ថានទូត។ យើងបានធ្វើកិច្ចការច្រើនសហការគ្នាទៅវិញទៅមក ហើយផ្តើមបានពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការកន្លងមកហ្នឹង ហើយនាំឱ្យសហរដ្ឋអាមេរិកមើលឃើញថា ការបង្កើតឡើងនូវអនុស្សារណៈហ្នឹង វានឹងកាន់តែធ្វើឱ្យកិច្ចសហប្រតិបត្តិការវាមានប្រសិទ្ធភាពថែមទៀត អីចឹងហើយបានជាគាត់ផ្តើមស្នើឱ្យមានការចុះហត្ថលេខាលើអនុស្សារណៈហ្នឹង»។ ប្រតិភូប៉ូលិសកម្ពុជាក៏បានជួបគ្នាពិភាក្សាការងារជាមួយនឹងនាយកដ្ឋានប្រតិបត្តិការអន្តរជាតិរបស់ FBI និងនាយកដ្ឋានព្រហ្មទណ្ឌ ដើម្បីពិភាក្សាពីបទល្មើសផ្លូវភេទលើកុមារនិងក្រុមជនពាល ដែលជាការរៀនសូត្រនិងផ្លាស់ប្តូរយោបល់គ្នាពីស្ថានភាពប្រទេសរៀងៗខ្លួន។

លោក ពៅ សាលីដេត បានបន្ថែមទៀតថា៖ «ឯកឧត្តមអគ្គស្នងការក៏គាត់គិតថា ដំណើរទស្សនកិច្ចនេះល្អដោយសារទាំងស្ថាប័ន FBI គាត់បានបដិសណ្ឋាកិច្ចយ៉ាងល្អផងដែរ។ យើងក៏បានជួបមិនត្រឹមតែនាយក FBI ទេគឺ

យើងបានធ្វើការជាមួយខាងព្រហ្មទណ្ឌ ខាងប្រតិបត្តិការអន្តរជាតិផងដែរ។ អីចឹងជាសរុបរួមមក គាត់បានពេញចិត្តជាមួយនឹងដំណើរទស្សនកិច្ចនេះ»។

កិច្ចព្រមព្រៀងថ្មីនេះក៏នឹងបញ្ចូលការហ្វឹកហ្វឺនជំនាញបន្ថែម និងការគាំទ្រផ្នែកបច្ចេកទេសដល់ភាគីកម្ពុជាផងដែរ។ នេះបើតាមការបញ្ជាក់របស់លោកគៀត ច័ន្ទថារិទ្ធ៕

## ពលករខ្មែរធ្វើការនៅថៃសម្រុកត្រឡប់ទៅលេងបុណ្យចូលឆ្នាំ ខណៈសមត្ថកិច្ចច្រកព្រំដែនបន្តយកលុយក្រៅផ្លូវការ

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2019-04-10

ពលករខ្មែរធ្វើការនៅប្រទេសថៃរាប់ពាន់នាក់បន្តដណ្ដើមគ្នាសម្រុកឆ្លងដែននៅតាមច្រកព្រំដែនអន្តរជាតិ ក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីត្រឡប់ទៅឱ្យទាន់លេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ ទន្ទឹមគ្នានេះពលករត្អូញត្អែរថា ប៉ូលិសខ្មែរនិងថៃប្រចាំច្រកព្រំដែននៅតែបន្តយកលុយក្រៅផ្លូវការពីពួកគាត់ ដើម្បីជាថ្នូរបើកឱ្យឆ្លងដែនទៅលេងស្រុកកំណើត។

ពលករខ្មែររស់នៅខេត្តព្រៃវែង លោក ព្រឹល ចាន្នី ថ្លែងប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី១០ មេសាថា លោកធ្វើការរោងចក្រកាត់ដេរនៅខេត្តសាមុត្រប្រាកាន (Samut Prakan) ជាប់ទៅក្រុងបាងកក ដោយបានធ្វើដំណើរចេញពីកន្លែងធ្វើការនៅម៉ោង១២ យប់ ហើយមកដល់ព្រំដែនម៉ោង ៧ព្រឹកថ្ងៃទី១០ មេសា។ ពលកររូបនេះបន្តថា នៅពេលដល់ច្រកព្រំដែនអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង គឺមានពលករខ្មែររាប់ពាន់នាក់ ដែលសមត្ថកិច្ចថៃឱ្យឈរតម្រង់ជួរយ៉ាងណែនណាន់តាន់តាប់នៅខាងទឹកដីថៃ ដើម្បីរង់ចាំឆ្លងដែន។ លោកអះអាងថា នៅពេលឆ្លងដែនសមត្ថកិច្ចថៃតម្រូវពួកគាត់បង់ប្រាក់ម្នាក់ ២០០បាត ឬស្មើជាងជាង ៦ដុល្លារអាមេរិក ដើម្បីជាថ្នូរបានឆ្លងដែនទៅកម្ពុជា ចំណែកឯប៉ូលិសខ្មែរវិញនៅព្រឹកថ្ងៃដដែលនេះ ពុំតម្រូវឱ្យពួកគាត់បង់ប្រាក់ដូចថ្ងៃមុននោះទេ៖ «ពេលយើងតម្រង់ជួរ ហើយគេឱ្យត្រៀមលុយម្នាក់ ២០០បាតសម្រាប់ឱ្យសមត្ថកិច្ចថៃ។ ខ្ញុំចង់អោយសមត្ថកិច្ចព្រំដែនទាំងខ្មែរ និងថៃសុំឱ្យធ្វើបានសេចក្ដីប្រកាសរបស់ក្រសួងការងារថៃ ដល់ពេលមកដល់ គេយកលុយអ៊ីចឹង គឺធ្វើឱ្យពលករមិនសប្បាយចិត្តទេ ព្រោះយើងធ្វើការមួយថ្ងៃបានតែ ៣០០បាត ដល់ពេលយកអស់ ២០០នៅសល់តែ ១០០បាត អស់បាត់ហើយ ណាមួយមកលេងស្រុកមួយឆ្នាំម្ដង មិនសូវមានលុយផង វាកាន់តែខើចលុយថែមទៀត»។ លោកបន្តថា ពលករបានត្អូញត្អែរស្ទើរគ្រប់គ្នាអំពីការយកបង់ប្រាក់ដោយប៉ូលិសថៃនោះ ព្រោះជាការអនុវត្តផ្ទុយពីសេចក្ដីប្រកាសរបស់ក្រសួងការងារថៃ ហើយពួកគាត់ទទូចអោយសមត្ថកិច្ចខ្មែរធ្វើយ៉ាងណាទំនាក់ទំនងខាងភាគីថៃជួយសម្រួលអោយពួកគាត់បានឆ្លងដែនដោយមិនបាច់បង់ប្រាក់ដូចសព្វថ្ងៃទៀត។ ចំណែកច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យឯណោះវិញ ក៏មានពលកររាប់ពាន់នាក់ប្រជ្រៀតគ្នាឆ្លងដែនទៅលេងស្រុកកំណើតបែបនេះដែរ។

ពលករម្នាក់រស់នៅស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ លោក ឈិត ស៊ីណាល់ រៀបរាប់ឱ្យដឹងថា ពលករខ្មែររាប់ពាន់នាក់រង់ចាំប្រថាប់ត្រាលិខិតឆ្លងដែននៅខាងទឹកដីថៃច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត។ លោកអះអាងថានៅច្រកមួយនេះ ប៉ូលិសថៃមិនយកលុយទេ។ ក៏ប៉ុន្តែបានដាក់ជម្រើស ២ ឱ្យពលករ ដោយអ្នកតម្រង់ជួរធម្មតាឆ្លងដែនដោយមិនបាច់បង់ប្រាក់តែត្រូវចំណាយពេលយូរ និងជម្រើសទី២ គឺសេវាឆាប់រហ័ស ត្រូវបង់ប្រាក់ ម្នាក់ ៣០០បាត ឬប្រហែល ១០ដុល្លារអាមេរិក។ ទោះជាយ៉ាងណាពលកររូបនេះបញ្ជាក់ថា សេវាទាំង២ នេះ គឺគ្រាន់តែល្បិចយកប្រាក់ស្របច្បាប់ ក៏ប៉ុន្តែទម្រាំតែបានឆ្លងដែនត្រូវរង់ចាំរយៈពេលមិនខុសគ្នានោះទេ៖ «ឈរចាំយូរបង ដូចថាមានទាំងលិខិតឆ្លងដែននិងអ្នកមានឯកសារធ្វើការរយៈពេលខ្លី ហើយជនជាតិថៃក៏ចូលមកលែងកាស៊ីណូនៅប៉ោយប៉ែតច្រើនដែរ តែចំពោះជនជាតិថៃគេសម្រួលផ្លូវអោយចូលស្រួលជាងពលករខ្មែរ។ហើយព្រឹកមិញមានកើតខ្យល់បួនដប់ម្ភៃនាក់ដែរ ដោយសារមនុស្សច្រើនឈរប្រជ្រៀតគ្នាហើយអាកាសធាតុក្ដៅហប់»។

ចំណែកពលករម្នាក់ទៀតរស់នៅខេត្តកំពង់ចាម លោក កែវ សុវាចា ថ្លែងថាលោកឆ្លងដែនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតនៅព្រឹកថ្ងៃទី១០ មេសា គឺចំណាយអស់ថវិកា ៤០០បាត ឬប្រហែល ១៣ដុល្លារអាមេរិក ក្នុងនោះបង់ឱ្យខាងប៉ូលិសថៃ ៣០០បាត និងប៉ូលិសខ្មែរ ១០០បាត ដើម្បីជាថ្នូរប្រថាប់ត្រាលើលិខិតឆ្លងដែនបានត្រឡប់ទៅលេងស្រុកកំណើតៈ ៖ «ខ្ញុំគិតថា គ្រាន់តែចំណាយឈរយៈពេល១ម៉ោងវាមិនមានបញ្ហាអីទេ ហើយដោយហេតុតែចង់លឿនសុខចិត្តចំណាយលុយ៣០០បាត គឺប្រហែលតែអ្នកចូលធម្មតាដែរ។តែបើថាដូចអ្នកណាមានខ្សែនៅច្រកព្រំដែនអីទៅគេបានរហ័ស ហើយខ្លះដើរប្រជ្រៀតគេឯងមិនខ្លាចនរណាទេ»។

ឆ្លើយតបនឹងបញ្ហានេះ អនុប្រធានប៉ុស្តិ៍ប៉ូលិសអន្តោប្រវេសន្តច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត លោក ជុំ សារ៉េត មានប្រសាសន៍ប្រាប់អាស៊ីសេរីយ៉ាងខ្លីថា លោកមិនបានដឹងជុំវិញបញ្ហាការយកប្រាក់ក្រៅផ្លូវការពីពលករម្នាក់ ១០០បាតនេះទេ៖ «ខ្ញុំមិនដឹងទេរឿងកិច្ចការនឹងខ្ញុំដូចជាមិនយល់ពីការងារនឹងទេ។ ខ្ញុំកំពុងរវល់តិចបងសុំទោស»។ ទោះជាយ៉ាងណា ពលករទាំង ៣នាក់អះអាងថា នៅពេលធ្វើដំណើរតាមឡានឈ្នួល គឺពលករត្អូញត្អែរខឹងសម្បានឹងសមត្ថកិច្ចច្រកព្រំដែនយកប្រាក់ក្រៅផ្លូវពីពួកគាត់ ខុសពីការណែនាំរបស់ស្ថានទូតខ្មែរនៅទីក្រុងបាងកក ដែលប្រកាសមិនយកប្រាក់ធ្វើទិដ្ឋាការពីពលករចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ មេសានោះ។

មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុក នៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារនិងសិទ្ធិមនុស្ស (CENTRAL) លោក ឌី ថេហូយ៉ា ថ្លែងថា នៅតាមច្រកព្រំដែន ជាពិសេស ច្រកធំៗ ដូចជា ច្រកដូង ប៉ោយប៉ែត ច្រកភ្នំដី ក្នុងស្រុកសំពៅលូន និងច្រកអន្តរជាតិព្រំខេត្តប៉ៃលិនជាដើម ជាកន្លែងដែលពលករខ្មែរឆ្លងដែនមកលេងស្រុកកំណើតរាប់ពាន់នាក់ក្នុងមួយថ្ងៃ។ លោកចាត់ទុកការយកប្រាក់ក្រៅផ្លូវការនេះថា ជាឱកាសនិយមរបស់សមត្ថកិច្ច និងការប្រព្រឹត្តអំពើពុករលួយកេងចំណេញពីពលករដោយខុសច្បាប់៖ «ហើយលុយនឹងសួរថា ជាលុយផ្លូវការសម្រាប់យកមកដើម្បីជាចំណូលថវិកាជាតិ ឬវាយ៉ាងម៉េច? បើសិនជាលុយនោះជាចំណូលជាតិ ហើយមានតម្លាភាពក្នុងការចាត់ចែងថវិកា ខ្ញុំគិតថា វាមិនច្រើនទេសម្រាប់លុយ៣០០បាត។ ប៉ុន្តែយកទៅមិនមែនជាការបង់ពន្ធចូលរដ្ឋអីទេ ខ្ញុំគិតថា វាជាអំពើពុករលួយមួយខ្លាំងណាស់ក្នុងការគាបសង្កត់យកលុយពីប្រជាពលរដ្ឋនោះ»។

អាស៊ីសេរីមិនអាចទាក់ទងប្រធានអង្គការភាពប្រឆាំងអំពើពុករលួយលោក ឱម យិនទៀង និងអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ ដើម្បីសុំអត្ថាធិប្បាយជុំវិញពីការយកលុយពលករនេះបានទេ នៅរសៀលថ្ងៃទី១០ មេសា ដោយទូរស័ព្ទចូលជាច្រើនដងតែពុំមានអ្នកទទួល។

ប៉ុន្តែកន្លែងមក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង បានបញ្ជាទៅច្រកព្រំដែនទាំងអស់ត្រូវលុបបំបាត់អំពើពុករលួយអស់បានជាដាច់ខាត ហើយបានព្រមានចាត់វិធានការមន្ត្រីទាំងនោះតាមផ្លូវច្បាប់ទៀតផង។ ក៏ប៉ុន្តែអំពើពុករលួយនៅតែកើតមានតាមច្រកព្រំដែនដដែល ដោយពុំមានអាជ្ញាធរមានវិធានការទៅលើមន្ត្រីទាំងនោះឡើយទេ។ គេរំពឹងថា ពលករខ្មែរនឹងបន្តឆ្លងដែនយ៉ាងច្រើនកកកុញនៅតាមព្រំដែនសំខាន់ៗ រហូតដល់ថ្ងៃទី១៣ មេសា។ ពលករឱ្យដឹងថា នៅច្រកព្រំដែនប៉ោយប៉ែត មានពលករក្នុងមួយថ្ងៃរាប់ពាន់នាក់ឆ្លងដែនទៅលេងបុណ្យចូលឆ្នាំខ្មែរ។ ចំណែកនៅច្រកព្រំដែនអន្តរជាតិដូង ស្រុកកំរៀងវិញ ប៉ូលិសច្រកមួយនេះអះអាងថា ពលករសម្រុកឆ្លងដែនចាប់ពីថ្ងៃទី៧ មេសាមក មានប្រមាណពី ៥ពាន់ទៅ ៦ពាន់នាក់ក្នុងមួយថ្ងៃ ហើយពលករនឹងត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញយ៉ាងណែនណាន់តាន់តាប់ បន្ទាប់ពីបុណ្យចូលឆ្នាំរួច ចាប់ពីថ្ងៃទី១៦ រហូតដល់ថ្ងៃទី២០ មេសា៕

## ពលករខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ត្រូវបានភាគីថៃបញ្ជូនត្រឡប់មកវិញ

https://www.facebook.com/ General Department of Immigration - GDI 10-04-2019

ឧត្តរមានជ័យ៖ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០៤នាក់ ពីភាគីថៃ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកតាស៊ីម ខេត្តព្រះវិហារ៕

## ថៃបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ០៨នាក់ ឲ្យមកកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 10-04-2019

កោះកុងៈ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង១៩នាទី ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ០៨នាក់ ពីភាគីថៃ។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## មានការលើកឡើងពីការបង់សេវា VIP ដើម្បីឆ្លងច្រកព្រំដែនបានលឿន

https://www.postkhmer.com/ ខន សាវិ | Publication date 11 April 2019 | 08:47 ICT

**បន្ទាយមានជ័យៈ** ពលករខ្មែរមួយចំនួនដែលបានចាកចេញពីប្រទេសថៃ មកស្រុកកំណើតក្នុងពិធីបុណ្យចូលឆ្នាំថ្មីត្រូវចំណាយប្រាក់ ៣៥០ បាត ប្រមាណ ៤ ម៉ឺនរៀលទិញសេវា VIP ដើម្បីទទួលបានសិទ្ធិអាទិភាពលឿនបំពេញឯកសារលើលិខិតឆ្លងដែនចូលមកស្រុកខ្មែរតាមច្រកអន្តរជាតិប៉ោយប៉ែត ដែលអ្នកវិភាគបានចាត់ទុកថា ជាអំពើពុករលួយ។

លោក រឿន សារ៉េត អាយុ ២៦ ឆ្នាំពលករខ្មែរធ្វើការសំណង់អស់ពេល ៧ ឆ្នាំម្នាក់នៅក្នុងប្រទេស ថៃ ហើយបានឆ្លងកាត់ច្រកទ្វារប៉ោយប៉ែតចូលមកកម្ពុជាកាលពីថ្ងៃទី ៣ ខែ មេសា បានអះអាងកាលពីម្សិលមិញថា ពលករជាច្រើនបានតម្រង់ជួររង់ចាំបំពេញឯកសារឆ្លងកាត់ច្រក។ ទន្ទឹមគ្នានោះដែរក៏មានភ្នាក់ងារប្រចាំច្រកដើរសួរ បើពលករណាចង់បានឆ្លងចូលស្រុកឆាប់ត្រូវទិញសេវា VIP។ លោក សារ៉េត ថ្លែងថាៈ «ខ្ញុំនិងពលករជាច្រើនទៀត បានចំណាយលុយអស់ចំនួន ៣៥០ បាត ជាថ្នូរទទួលបានសេវាវីអាយភីក្នុងការបញ្ជាក់និងប្រថាប់ត្រាលើឯកសារនិងលិខិតឆ្លងដែនឱ្យបានលឿន ពីមន្ត្រីប្រចាំច្រកទ្វារអន្តរជាតិព្រំដែនប៉ោយប៉ែត ហើយបើមិនទទួលសេវានេះទេ គឺត្រូវចំណាយពេលពី ២ ទៅ ៣ ថ្ងៃឯណោះ »។ លោក សារ៉េត ថ្លែងថាៈ «កាលណាយើងមានលិខិតវីអាយភីហ្នឹង គឺគេអូសដៃយើងទៅវ៉ៃលិខិតឆ្លងដែនមុនអ្នកដែលអត់មានសេវា VIP គេមានភ្នាក់ងារគេច្រើនណាស់ហើយកូនក្រដាស VIP ហ្នឹងមួយសន្លឹក ៣៥០ បាត»។

នារីដែលជាអ្នកលក់ដូរម្នាក់ឈ្មោះ ផេង សុភ័ក្រ ដែលបានធ្វើដំណើរត្រឡប់ពីទិញអីវ៉ាន់នៅក្នុងប្រទេសថៃវិញកាលពីប៉ុន្មានថ្ងៃមុននេះបានអះអាងស្រដៀងគ្នានិងលោក សារ៉េត ថា មានអ្នកស្លៀកពាក់មិនមែនឯក សណ្ឋានប៉ូលិសអង្គុយរង់ចាំនៅច្រកផ្លូវដើរចូលដោយបានស្រែកអំពាវនាវលក់ក្រដាសវីអាយភីដល់ពលករដែលចង់ឆ្លងព្រំដែនលឿន។ នារីលក់ដូររូបនេះ ថ្លែងថាៈ «ពួកគេខ្លះនៅតែតម្រូវឱ្យតម្រង់ជួរជាមួយអ្នកដែលមិនបានទិញក្រដាស VIP ដដែល ហើយត្រូវរង់ចាំជាងកន្លះថ្ងៃទម្រាំតែបានឱ្យមន្ត្រីព្រំដែនខ្មែរបញ្ជាក់លិខិតនិងបោះត្រាលើលិខិតឆ្លងដែន»។

ទោះជាយ៉ាងណា កាលពីថ្ងៃទី ៩ ខែ មីនា នៅលើហ្វេសប៊ុករបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍បានអំពាវនាវនិងបានណែនាំទៅកាន់នាយប៉ុស្តិ៍ច្រកទ្វារព្រំដែន ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទី ភារកិច្ច និងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋដូចជាការផ្តល់សេវាបម្រើប្រជាពលរដ្ឋដោយគ្មានការបង់ប្រាក់ជាដើម។ ហ្វេសប៊ុកដដែលនេះបានឲ្យដឹងថាៈ «មន្ត្រីនគរបាលគ្រប់ច្រកទ្វារព្រំដែនទាំងអស់ (រួមទាំងក្រៅពីច្រកទ្វារអន្តរជាតិប៉ោយប៉ែត) ត្រូវយកចិត្តទុកដាក់និងបង្កលក្ខណៈងាយស្រួលជាប្រចាំដល់ពលរដ្ឋខ្មែរនិងបរទេស ដែលធ្វើដំណើរឆ្លងកាត់ព្រំដែន ជាពិសេសពលករដែលធ្វើការនៅប្រទេសថៃក្នុងរដូវចូលឆ្នាំខ្មែរខាងមុខឆាប់ៗនេះ ដោយមិនត្រូវទទួលប្រាក់កាសឡើយ»។

ទោះជាយ៉ាងណាក៏ដោយ លោក ហ៊ាន គឹមសឿន អ្នកវិភាគនយោបាយនិងជាអ្នកឃ្លាំមើលព្រឹត្តិការណ៍សង្គមកាលពីថ្ងៃម្សិលមិញបានដាក់ពាក្យបណ្តឹងមួយទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីសុំឱ្យមានការបើកការស៊ើបអង្កេតពាក់ព័ន្ធករណីយកលុយពីពលករខ្មែរឆ្លងដែនចេញពីប្រទេសថៃ របស់ក្រុមមន្ត្រីនគរបាលប្រចាំច្រកទ្វារ

អន្តរជាតិប៉ោយប៉ែត។ លោក ហ៊ាន គឹមសឿន បានប្រាប់ភ្នំពេញប៉ុស្ដិ៍ម្សិលមិញថា៖ «ខ្ញុំទទួលបានភ័ស្ដុតាងជាខ្សែវីដេអូនិងឯកសារមួយចំនួន ដែលបង្ហាញថា មន្ត្រីនគរបាលប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានយកលុយពីពលករដែលវិលត្រឡប់មកលេងស្រុកកំណើតសម្រាប់ពិធីបុណ្យចូលឆ្នាំ ក្នុងម្នាក់ចំនួន ៣៥០ បាត ឬស្មើប្រហែល ៤ ម៉ឺនរៀល ដើម្បីចំណាយលើថ្លៃការរត់ការនិងប្រថាប់ត្រាលើឯកសារនិងលិខិតឆ្លងដែនឱ្យបានលឿន។ ខ្ញុំប្រមែប្រមូលព័ត៌មាន មិនត្រឹមមន្ត្រីទ្វារហ្នឹងទេ មន្ត្រីណាក៏ខ្ញុំប្ដឹងដែរ»។

លោក ខឹម ចិត្រា ប្រធាននគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃម្សិលមិញមិនអាចទាក់ទងសុំអត្ថាធិប្បាយបានទេ ព្រោះមិនលើកសារទូរស័ព្ទ។

លោក កែវ វណ្ណថន អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក៏មិនអាចសុំការបកស្រាយបានដែរ ដោយសារមន្ត្រីឆ្លើយទូរស័ព្ទអះអាងថាជាប់រវល់ប្រជុំ។

លោក ឱម យិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយក៏មិនអាចសុំការបកស្រាយបានដែរ ព្រោះលោកមិនលើកទូរស័ព្ទ។ ទោះយ៉ាងណាក៏ដោយ មន្ត្រី ACU ម្នាក់ ដែលសុំមិនបង្ហាញអត្តសញ្ញាណបានថ្លែងបញ្ជាក់ថា៖ «ខ្ញុំមិនអាចបញ្ជាក់ជុំវិញបណ្ដឹងរបស់លោក ហ៊ាង គឹមសឿន ឡើយ ដោយសារជារឿងសម្ងាត់»។

លោក ស៊ុំ ច័ន្ទគា មន្ត្រីសម្របសម្រួលផ្នែកសិទ្ធិមនុស្សនៃសមាគមអាដហុក ADHOC ប្រចាំខេត្តបន្ទាយមានជ័យបានអះអាងថា ការណែនាំមិនឱ្យយកលុយពីពលករនេះ គឺពុំមានប្រសិទ្ធភាពឡើយ ព្រោះពលករដែលធ្វើដំណើរចេញពីប្រទេសថៃតាមច្រកទ្វារព្រំដែនដទៃទៀតបានអះអាងដូចៗគ្នាថាមានការយកលុយស្រដៀងគ្នាទៅនឹងច្រកទ្វារអន្តរជាតិប៉ោយប៉ែតនេះដែរ។ លោក ច័ន្ទគា បានថ្លែងថា៖ «ខ្ញុំបានបើកវគ្គបណ្ដុះបណ្ដាលអំពីសិទ្ធិអំណាចរបស់ពលរដ្ឋ ហើយខ្ញុំសួរសិក្ខាកាមចូលរួមគាត់ថា យកមែនឆ្លើយព្រមគ្នាទាំង ៤០ នាក់។ គាត់ថាកុំទៅជឿថាអត់យក ព្រោះយកមែនអាខ្លះគេយក ៣០០ (បាត) អាខ្លះយក ១ រយ អីទៅ»៕

## ពលករត្រលប់មកលេងស្រុកកំណើតនាឱកាសបុណ្យចូលឆ្នាំថ្មី ទទួលបានសំបុត្ររថយន្តក្រុងដោយឥតគិតថ្លៃចំនួន៣ថ្ងៃ

https://www.chnchannel.com/article/ អត្ថបទដោយ Kongkea Leuk កាលបរិច្ឆេទ ថ្ងៃទី 10 ខែ មេសា ឆ្នាំ 2019

**បន្ទាយមានជ័យ៖** ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីយ៍ខ្មែរឆ្នាំ ២០១៩ ពលករធ្វើការនៅប្រទេសថៃត្រលប់កមលេងស្រុកកំណើត តាមច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែតទទួលបានសំបុត្ររថយន្តក្រុងដោយគិតថ្លៃចំនួន៣ថ្ងៃពីក្រុមហ៊ុនMetfone ដោយចែកចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១២ខែមេសា ឆ្នាំ ២០១៩ ចែកសំបុត្រនៅ មាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងចំណតរថយន្តក្រុងប៉ោយប៉ែត ។

លោក រួន សីហា ក្រុមការងារMetfoneដែលចែកសំបុត្ររថយន្តក្រុងដោយគិតថ្លៃនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ប្រាប់ថា ពលករដែលត្រលប់មកស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំ ប្រពៃណីយ៍ខ្មែរ និងទទួលបានសំបុត្ររថយន្តក្រុងដោយឥតថ្លៃពីក្រុមហ៊ុន។ លោកបញ្ជាក់ថា ការចែកសំបុត្ររថយន្តក្រុងគឺមានរយះពេលបីថ្ងៃដោយគិតចាប់ពីថ្ងៃទី១០,១១ ,១២ ខែមេសា នេះ។

បុគ្គលិកក្រុមហ៊ុន Metfone បានបញ្ជាក់ថា ការចែកសំបុត្ររថយន្តក្រុងដល់ពលករដែលត្រលប់មកលេងស្រុកកំណើត ដោយកំណត់ក្នុងមួយថ្ងៃចំនួន៣គ្រឿង ដែលអាចដឹកពលករក្នុង១ថ្ងៃជាង១០០នាក់ ហើយគោលដៅរត់ឆ្ពោះទៅកាន់រាជធានីភ្នំពេញ រត់តាមផ្លូវជាតិលេខ៥ចំនួន២គ្រឿង និងផ្លូវជាតិលេខ៦ចំនួន១គ្រឿង។

ក្នុងឱកាសចូលរួមចែកសំបុត្រដោយឥតគិតថ្លៃដល់ពលករ លោកសាន ស៊ានហូ អភិបាលក្រុងប៉ោយប៉ែត ក៏បានថ្លែងអំណរគុណចំពោះក្រុមហ៊ុនMetfone ដែលបានចំណាយថវិកាជួយដល់ពលករ ក្នុងធ្វើដំណើរត្រលប់ទៅ

លេងស្រុកកំណើតស្របពេលដែលរាជរដ្ឋាភិបាលប្រើប្រាស់រថយន្តក្រុងរាប់រយគ្រឿង ដឹកកម្មករកម្មការនីរោងចក្រធ្វើដំណើរទៅស្រុកកំណើតទៅតាមបណ្តាខេត្តនានា ដោយឥតគិតថ្លៃផងដែរ។ដោយ៖ SN

## ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩

### បង្រ្កាបកន្លែងជួញដូរផ្លូវភេទ ៖ ឃាត់ខ្លួនស្ត្រីវៀតណាម ១០ នាក់ នៅប៉ៃលិន

http://www.rasmeinews.com/ April 11, 2019, 6:15 PM ដោយៈ គ្រញូង

ប៉ៃលិនៈ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល ខេត្តប៉ៃលិន បានចុះបង្ក្រាបករណីជួញដូរផ្លូវភេទមួយ កន្លែង ឃាត់ខ្លួនមនុស្ស ប្រុសស្រីជាច្រើននាក់ ក្នុងនោះមាននារីម្នាក់ជាអនីតិជន (អាយុក្រោម ១៥ ឆ្នាំ)។ ហេតុការណ៍នេះ បានកើតឡើង នៅយប់ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ នៅទីតាំងរកស៊ី ជួញដូរផ្លូវភេទ មួយកន្លែង ស្ថិតនៅក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន។

លោក អេង ភាវ នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត បានឱ្យដឹងថា បន្ទាប់ពីទទួលបញ្ជា របស់លោក គួច សុភក្តិ ព្រះរាជអាជ្ញា អមសាលាដំបូងខេត្ត រួចមកកម្លាំងរបស់លោក ក៏បានចុះបង្ក្រាបភ្លាមៗ ហើយឃាត់ខ្លួនបានជនជាតិវៀតណាម ចំនួន ៩ នាក់ និងខ្មែរម្នាក់ ជា ម្ចាស់ផ្ទះ ក្នុងនោះ សមត្ថកិច្ច ក៏បានរកឃើញ ក្មេងស្រីម្នាក់ ដែលជាអនីតិជន ផងដែរ ។ លោកនាយការិយាល័យ បានបន្តថា ក្នុងប្រតិបត្តិការនេះ កម្លាំងសមត្ថកិច្ចនគរបាល បានរកឃើញ នូវវត្ថុតាង ស្រោមអនាម័យប្រើប្រាស់រួច មួយចំនួន និងមិនទាន់ប្រើប្រាស់ មួយចំនួន។ លោកបានបញ្ជាក់ថា ក្នុងចំណោមមនុស្ស ១០ នាក់ ដែលត្រូវឃាត់ខ្លួន ខាងលើ មានថៅកែ ជាជនជាតិវៀតណាម ចំនួន២នាក់ អ្នកមើលការខុសត្រូវ ចំនួន ២ នាក់ អ្នកបម្រើសេវាផ្លូវភេទ ចំនួន ៦ នាក់ ( ម្នាក់ជាអនីតិជន មិនគ្រប់អាយុ ) ហើយសម្រាប់ក្មេងស្រី ដែលមិនទាន់គ្រប់អាយុ គឺថៅកែ បម្រុងនឹងនាំនាង ទៅលក់ព្រហ្មចារី នៅឯខេត្តព្រះសីហនុ ។ លោកបានបញ្ជាក់ទៀតថា បច្ចុប្បន្ន ជនសង្ស័យ ទាំង ១០ នាក់ ត្រូវបានកម្លាំងជំនាញ រៀបចំកសាងសំណុំរឿង បញ្ជូនទៅកាន់សាលាដំបូង ខេត្តប៉ៃលិន ដើម្បីចាត់ការ តាមនីតិវិធី៕v

### អ្នកនាំពាក្យថា ពលករខ្មែរមកពីថៃ បានបង់ប្រាក់នៅទ្វារព្រំដែន ព្រោះមិនចង់ចាំយូរ

https://thmeythmey.com/ 11, Apr 2019 , 5:50 pm ដោយ: អ៊ុ សុខមាន

ភ្នំពេញ៖ លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានអះអាងថា ករណីដែលមានពលករខ្មែរមកពីប្រទេសថៃ ហើយបានឱ្យប្រាក់ទៅមន្រ្តីអន្តោប្រវេសន៍ នៅតាមព្រំដែនប៉ោយប៉ែត និងបាត់ដំបង ដោយសារតែពួកគេមិនចង់រង់ចាំតម្រង់ជួរយូរ។ លោក បកស្រាយថា ការឱ្យប្រាក់១០០ឬ២០០បាតដល់មន្ត្រីអន្តោប្រវេសន៍ខ្មែរនោះ ជាលក្ខណៈបុគ្គលតែប៉ុណ្ណោះ ដើម្បីបានចេញលឿន។

ក្នុងបទសម្ភាសតាមទូរសព្ទជាមួយសារព័ត៌មានថ្មីៗ នាថ្ងៃទី១១មេសា លោក ខៀវ សុភ័គ លើកឡើងថា ពេលជិតបុណ្យចូលឆ្នាំខ្មែរ ពលករដែលធ្វើការនៅប្រទេសថៃជាច្រើន បាននាំគ្នាសម្រុកមកស្រុកកំណើតវិញ ដែលបណ្តាឱ្យមានភាពកកស្ទះពេញតាមច្រកព្រំដែន និងមានអ្នកខ្យល់គរជាច្រើននាពេលកំពុងតម្រង់ជួរប្រថាប់ត្រា ដោយសារតែក្តៅនិងហាប់ពេក។ លោក បន្តថា ករណីមន្ត្រីអន្តោប្រវេសន៍ខ្មែរ បានទារប្រាក់ពីពលករនោះ គឺមិនមានឡើយ។ អ្នកនាំពាក្យរូបនេះ បកស្រាយថា «ការយកលុយពីប្រជាពលរដ្ឋឆ្លងដែនគឺមិនមានទេ។ មានតែជួយណែនាំនិងសម្រួលពីសំណាក់មន្ត្រីតាមព្រំដែនក្នុងការជួយដល់កម្មករ-កម្មការនីយើង។ យើងគ្មានគោលការណ៍ ឬច្បាប់ណាមួយដែលតម្រូវឱ្យមន្ត្រីយកប្រាក់ ឬទារប្រាក់ ពីពលករទាំងនោះដែរ»។ លោក ខៀវ សុភ័គ បានបញ្ជាក់ថា បើរកឃើញមន្ត្រីអន្តោប្រវេសន៍នៅតាមព្រំដែនណាមួយ បានទារឬគំរាមយកប្រាក់ពីពលករ នឹងទទួលទោសច្បាប់៕

## អាជ្ញាធរថៃដោះលែងពលរដ្ឋខ្មែរចំនួន៤នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៩ ម៉ោង ១៤:៤៨ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ ក្រុមអាជ្ញាធរថៃបានធ្វើការដោះលេងអ្នកទោសខ្មែរចំនួន៤នាក់ឱ្យមានសេរីភាពវិញ និងនាំខ្លួនយកមកប្រគល់ឱ្យអាជ្ញាធរកម្ពុជានៅមាត់ច្រកទ្វារអន្តរជាតិជាំ សាងាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីវេលាម៉ោង១១និង១០នាទីព្រឹកថ្ងៃទី១០ មេសា២០១៩។

អ្នកទោសខ្មែរចំនួន៤នាក់ដែលក្រុមអាជ្ញាធរថៃធ្វើការដោះលេង ក្នុងនោះរួមមាន ១-ឈ្មោះសៀប ទិន ភេទប្រុស អាយុ៣៥ឆ្នាំ ២-ឈ្មោះ ឈិត ធី ភេទប្រុ សអាយុ២៦ឆ្នាំ ៣-ឈ្មោះភ័ក្រ ម៉ង ភេទប្រុស អាយុ២៣ឆ្នាំ និង៤-ឈ្មោះជិន ជោន ភេទប្រុស អាយុ២៣ឆ្នាំ ។ អ្នកទាំង៤នាក់រស់នៅភូមិកន្ទួត ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ហើយត្រូវបានក្រុមទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី១៦ តុលា ២០១៧ ពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ចូលតាមច្រកតាសឹម ហើយត្រូវអាជ្ញាធរថៃចាប់ដាក់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំ សាងាំបានឱ្យដឹងថា ក្រុមអាជ្ញាធរ និង មន្ត្រីតុលាការអមសាលាដំបូងខេត្តស៊ីសាកេត ប្រទេសថៃ បានសម្រេចដោះលែងពលរដ្ឋខ្មែរចំនួន៤នាក់ខាងលើ ហើយបាននាំខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាវិញកាលពីព្រឹកថ្ងៃទី១០ មេសា ២០១៩ ក្រោយពីបានទទួលអ្នកទោសខ្មែរក្រុមអាជ្ញាធរកម្ពុជាបានធ្វើការណែនាំ និងធ្វើកិច្ចសន្យារួចឱ្យវិលត្រឡប់ទៅលំនៅឋានជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល៕

## ប៉ូលិសប៉ុស្តិ៍ទ្វារព្រំដែនឃាត់ខ្លួនមេខ្យល់កៀបស៊ីលុយពីពលករខ្មែរ

http://www.rasmeinews.com/ April 12, 2019, 7:54 AM

ដោយ:ប.ជ័យ/បន្ទាយមានជ័យ:ប៉ូលិសប៉ុស្តិ៍ទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតបានឃាត់ខ្លួនមេខ្យល់ម្នាក់កៀបស៊ីលុយពីពលករខ្មែរត្រឡប់ពីធ្វើការនៅថៃ ។ នាយរងប៉ុស្តិ៍ម្នាក់នៃអង្គភាពនគរបាលនេះ បានឱ្យកាសែតរស្មីកម្ពុជាដឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ថា : ជនសង្ស័យជាមេខ្យល់នោះមានឈ្មោះ ខៀវ សារុធ ភេទប្រុស អាយុ៣៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអ្វូសរទេះ បច្ចុប្បន្នស្នាក់នៅផ្ទះជួល ក្រោយនាគមាសចាស់ភូមិ-សង្កាត់-ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ លោកបានបន្តថា: ការឃាត់ខ្លួននោះធ្វើឡើងកាលពីថ្ងៃទី៩ មេសា ឆ្នាំ២០១៩ ខណ:គេបាននាំពលករខ្មែរធ្វើការស៊ីឈ្នួលចេញពីប្រទេសថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត មកប្រទេសកម្ពុជាចំនួន៣នាក់ ក្នុងតម្លៃម្នាក់៦០០បាត។ ចំពោះមុខមន្ត្រីនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ជនសង្ស័យ ខៀវ សារុធ បានសារភាពទទួលកំហុស និងបានធ្វើកិច្ចសន្យាបញ្ឈប់បង្កល្មើសដូច្នេះទៀតហើយ ប្រគល់លុយឱ្យពលករវិញ ហើយសុំទោសពលករផងដែរ។ទS/

## បុរសម្នាក់ត្រូវឃាត់ខ្លួន ពីបទទារលុយពលករមកពីថៃនៅច្រកទ្វារប៉ោយប៉ែត

https://www.postkhmer.com/ ខន សាវិ | Publication date 12 April 2019 | 10:50 ICT

**បន្ទាយមានជ័យៈ** មន្ត្រីប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតម្សិលមិញបានឃាត់ខ្លួនបុរសម្នាក់ដោយចោទពីបទជំរិតទារប្រាក់ពីពលករ ដែលការឃាត់នេះធ្វើឡើងស្របពេលមានការចោទប្រកាន់ថា មន្ត្រីប៉ូលិសព្រំដែនខ្មែរនៅប៉ោយប៉ែត បានឆក់ឱកាសឱ្យមានសេវាក្រៅផ្លូវការរីអោយគី ដើម្បីយកប្រាក់ពីពលករឆ្លងដែនពីថៃចូលមកលេងស្រុកកំណើតសម្រាប់ពិធីបុណ្យចូលឆ្នាំ។

ទំព័រហ្វេសប៊ុករបស់ប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែតពីម្សិលមិញ បានបង្ហាញមុខបុរសម្នាក់ និងរៀបរាប់យ៉ាងខ្លីថា គឺជាអ្នកជំរិតទារប្រាក់ពីពលករ «ការឃាត់ខ្លួនមេខ្យល់ជំរិតទារប្រាក់ពីបងប្អូនពលករ នៅតែបន្តដូចភ្លៀងរលឹម។ សូមបងប្អូនមកទាក់ទងមន្ត្រីដោយផ្ទាល់ ចៀសវាងការចាញ់បោក និងខាតបង់ប្រាក់កាស»។

ភ្នំពេញប៉ុស្តិ៍បានផ្ញើសារតាមរយៈទំព័រហ្វេសប៊ុករបស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ដើម្បីសុំការបកស្រាយបន្ថែមពីលោក ខឹម ចិត្រា ប្រធានប៉ុស្តិ៍នគរបាលច្រកទ្វារនេះ ប៉ុន្តែអ្នកកាន់ទំព័រហ្វេសប៊ុកនោះបានឆ្លើយតបថា មន្ត្រីកំពុងរៀបចំឯកសារជុំវិញការឃាត់ខ្លួនបុរសម្នាក់នេះ ហើយនឹងផ្ញើឯកសារនោះមកភ្នំពេញប៉ុស្តិ៍តាមក្រោយ។

លោក សេម មករា នាយផ្នែកសេនាធិការនគរបាលប៉ុស្តិ៍អន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក៏មិនលើកទូរស័ព្ទនោះទេពីម្សិលមិញ។ ឯលោក អ៊ុំ សុផល អធិការនគរបាលក្រុងប៉ោយប៉ែតបានបញ្ជាក់ថា លោកមិនបានដឹងករណីឃាត់ខ្លួនអ្នកជំរិតទារប្រាក់ពីពលករនេះទេ។

ការឃាត់ខ្លួនមេខ្យល់ប្រមូលប្រាក់ពីពលករនេះ កើតឡើងស្របពេលមានការលើកឡើងថា ក្នុងឱកាសបុណ្យចូលឆ្នាំដែលពលករខ្មែរនៅថៃកំពុងនាំគ្នាសម្រុកមកលេងស្រុកកំណើត គឺប៉ូលិសច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានឃុបឃិតជាមួយភ្នាក់ងារអ្នករត់ការដើម្បីលក់សំបុត្រអែាយភីតម្លៃ ៣៥០ បាតឬស្មើប្រហែល៤ម៉ឺនរៀល ចំពោះពលករណាដែលចង់ឆាប់ឆ្លងដែនបានរហ័ស ហើយមិនចាំបាច់ទៅតម្រង់ជួរ។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍បញ្ជាក់ថា៖ «មន្ត្រីនគរបាលគ្រប់ច្រកទ្វារព្រំដែនទាំងអស់ត្រូវយកចិត្តទុកដាក់និងបង្កលក្ខណៈងាយស្រួលជាប្រចាំដល់ពលរដ្ឋខ្មែរនិងបរទេសដែលធ្វើដំណើរឆ្លងកាត់ព្រំដែនជាពិសេសពលករដែលធ្វើការនៅប្រទេស ថៃ ក្នុងរដូវចូលឆ្នាំខ្មែរខាងមុខឆាប់ៗនេះ ដោយមិនត្រូវទទួលប្រាក់កាសឡើយ»។

លោក ស៊ុំ ច័ន្ទគា មន្ត្រីសម្របសម្រួលផ្នែកសិទ្ធិមនុស្សនៃសមាគមអាដហុកប្រចាំខេត្តបន្ទាយមានជ័យប្រាប់ភ្នំពេញប៉ុស្តិ៍ ពីម្សិលមិញថា អ្នកដែលរត់ការចាំលក់សំបុត្រវីអាយភីទៅពលករនៅតាមច្រកទ្វារឆ្លងដែន ប្រាកដជាពួកគេបានផ្តល់ផលប្រយោជន៍ទៅអាជ្ញាធរប្រចាំការនៅទីនោះ បើមិនដូច្នោះទេ ពួកគេក៏មិនហ៊ានធ្វើសកម្មភាពបែបនេះដែរ៕

## ស្ថានទូតបានចុះដោះស្រាយបញ្ហាជូនបងប្អូនពលករខ្មែរចំនួន២៥នាក់

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ 11-04-2019

នាថ្ងៃទី១០ មេសា ឆ្នាំ២០១៩ ស្ថានទូតបានចុះមកស្រុកសាន់កាំផែង ខេត្តឈៀងម៉ៃ ដើម្បីដោះស្រាយបញ្ហាជូនបងប្អូនពលករខ្មែរចំនួន២៥នាក់ធ្វើការនៅក្រុមហ៊ុន Natural Thai Location Co.,Ltd ដែលត្រូវបានក្រុមហ៊ុនមិនបើកប្រាក់ឈ្នួលជាង២ខែមកហើយ។ បន្ទាប់ពីបានជួបជាមួយពលករសួរនាំព័ត៌មានលម្អិត ស្ថានទូតក៏បាននាំពលករទាំងអស់ទៅដាក់ពាក្យបណ្តឹងនៅមន្ទីរការងារ និងការិយាល័យសុខមាលភាពនិងគាំពារពលករខេត្តឈៀងម៉ៃ ដើម្បីទាមទារប្រាក់ឈ្នួលជូនពួកគាត់។ ក្រោយពីស្ថានទូត និងអាជ្ញាធរថៃ បានដោះស្រាយបញ្ហាជាមួយពលករ និងក្រុមហ៊ុនអស់រយៈពេលជាច្រើនម៉ោងមក ភាគីពលករ និងក្រុមហ៊ុនបានឯកភាពគ្នា ដូចខាងក្រោម៖

១-ដោយមានការអន្តរាគមន៍ពីស្ថានទូត នាវេលាម៉ោង ៤ល្ងាចថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៩ ក្រុមហ៊ុនបានបើកប្រាក់ឈ្នួលចំនួន 3សប្តាហ៍ជាបឋមសិន អោយពលករទាំង២៥នាក់ តាមរយៈការផ្ទេរលុយចូលបញ្ជីធនាគាររបស់ពលករតែម្តង។

២-ក្រុមហ៊ុននឹងបើកប្រាក់ឈ្នួលចំនួន ១សប្តាហ៍ទៀត នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៩។

៣-ក្រុមហ៊ុនបានសន្យាថានឹងបើកប្រាក់ឈ្នួលដែលនៅសល់ទាំងអស់ អោយពលករនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៤-ប្រសិនបើក្រុមហ៊ុន មិនអនុវត្តតាមកិច្ចសន្យា ការិយាល័យសុខមាលភាពនិងគាំពារពលករនោះទេ នឹងដាក់ពាក្យបណ្តឹងទៅតុលាការ ហើយក្រុមហ៊ុនត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ ព្រមទាំងត្រូវបង់ផាកពិន័យផងដែរ។

៥- ពលករទាំងអស់គ្នា បានឯកភាពតាមដោះស្រាយខាងលើ។

ជាមួយគ្នានោះដែរ ពលករបានថ្លែងអំណរគុណដល់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដែលតែងតែយកចិត្តទុកដាក់ដោះស្រាយបញ្ហាជូនពួកគាត់ មិនទុកពួកគាត់ចោលនោះទេ។

## អាជ្ញាធរថៃបានដោះលែងពលរដ្ឋខ្មែរទាំង១២នាក់ ត្រឡប់ទៅប្រទេសកម្ពុជាវិញ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 12-04-2019

នៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៩ មន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងបាងកក បានចុះទៅសម្របសម្រួលជាមួយអាជ្ញាធរថៃ ស្នើសុំអាជ្ញាធរថៃដោះលែងពលរដ្ឋខ្មែរចំនួន១២នាក់ ពីបទឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ នៅខេត្តនគររាជសីម៉ាប្រទេសថៃ។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ អាជ្ញាធរថៃបានដោះលែងពលរដ្ឋខ្មែរទាំង១២នាក់ ត្រឡប់ទៅប្រទេសកម្ពុជាវិញ តាមច្រកព្រំដែន ឆងចម (ខេត្តសុរិន)- អូរស្មាច់ (ខេត្តឧត្តមានជ័យ)។

## តំណាងស្ថានទូតបានចុះមកច្រកព្រំដែនអន្តរជាតិ បានឡែម-ដូង ដើម្បីពិនិត្យមើលការធ្វើដំណើរឆ្លងកាត់ច្រកព្រំដែនរបស់បងប្អូនពលករត្រឡប់ទៅលេងស្រុកកំណើត

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 12-04-2019

នាថ្ងៃទី១១ មេសា ឆ្នាំ២០១៩ តំណាងស្ថានទូតបានចុះមកច្រកព្រំដែនអន្តរជាតិ បានឡែម-ដូង ស្ថិតក្នុងខេត្តចាន់ថាក់បុរី ប្រទេសថៃ ដើម្បីពិនិត្យមើលការធ្វើដំណើរឆ្លងកាត់ច្រកព្រំដែនរបស់បងប្អូនពលករត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ។

1-លោក Namchai Luanpiyakul ប្រធានផ្នែកប្រចាំច្រកបានឡែម បានបញ្ជាក់ថា ពលករដែលធ្វើដំណើរតាមច្រកនេះមានចំនួនច្រើន ដោយចាប់ពីថ្ងៃទី៩-១១ ខែមេសា មានសរុបប្រហែល ៦ម៉ឺននាក់ (ក្នុងមួយថ្ងៃប្រហែលជាង១ម៉ឺននាក់)។

2-ក្រុមការងាររបស់លោកបានរៀបចំកន្លែងឲពលកររងចាំ និងជួយសម្រួលឲពលករបានចេញទៅកម្ពុជា ទោះជាពលករនោះពុំមានឯកសារអ្វីក៏ដោយ ។

3-បើអនុវត្តតាមនិតិវិធី គឺមិនអាចអនុវត្តទាន់ពេលវេលាឡើយ ដោយពលករត្រូវរងចាំយូររហូតដល់២-៣ថ្ងៃ ដោយសារតែចំនួនមនុស្សច្រើន ម្យ៉ាងទៀតពលករដែលមិនមានឯកសារគឺត្រូវឃាត់ខ្លួនសិនមុននឹងដំណើការនិតិវិធីបញ្ជូនចេញ ដោយប្រើពេលប្រហែល២សប្តាហ៍។

4-តំណាងស្ថានទូតក៏សូមថ្លែងអំណរគុណ ចំពោះលោក Nanchai និងក្រុមការងារដែលបានយកចិត្តទុកដាក់ និងជួយសម្រួលដល់បងប្អូនពលករ និងសូមអោយក្រុមការងារបន្តតាមដាន និងចាត់ការចំពោះជនឆ្លៀតឱកាសដែលយកលុយពីពលករ។

## ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៩

## រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៖លំហូរនៃពលករចំណាកស្រុក គឺវាស្របទៅនឹងគោលការណ៍សកលនៃលក្ខណៈសេដ្ឋកិច្ច

http://www.rasmeinews.com/ April 15, 2019, 4:23 PM

ដោយៈតារាឫទ្ធ(កំចាយមារ)៖ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលោក ស្តើង សុខុម ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយស្រុកកំចាយមារបានមានប្រសាសន៍ថា៖ លំហូរនៃពលករចំណាកស្រុកគឺវាស្របទៅនឹងគោលការណ៍សកលនៃលក្ខណៈសេដ្ឋកិច្ច ព្រោះថាការបញ្ជូនពលករទៅក្រៅប្រទេសនឹងជួយលើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុកជាពិសេសការ ទាញយកជំនាញពីប្រទេសសេដ្ឋកិច្ចជឿនលឿនមកអភិវឌ្ឍន៍ប្រទេសផងដែរ ។

លោករដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានមានប្រសាសន៍បែបនេះនៅក្នុងពីធីអញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនកម្មករ កម្មការិនីប្រមាណជាង ៥០០ នាក់នៅក្នុងស្រុកកំចាយមារនាព្រឹកថ្ងៃទី១៥ ខែ មេសា ដែលជាថ្ងៃចូលឆ្នាំថ្មីប្រពៃណិជាតិថ្ងៃទី ២ ។កម្មករ កម្មការិនីជាង ៥០០ នាក់នេះមានមកពីប្រទេសថៃ ប្រទេសផ្សេងៗមួយចំ នួន និង ពលករចំណាកស្រុកដែលធ្វើការនៅក្នុងប្រទេសនិងមួយចំនួនធ្វើការនៅក្នុងស្រុកកំចាយមារ ។ នៅក្នុងពិធីនោះលោករដ្ឋលេខាធិការ ស្តើង សុខុម បានសំដែងការរីករាយដែលបានជួបជាមួយបងប្អូនពលករចំណាកស្រុកទាំងអស់ នៅក្នុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណិជាតិ ។ ក្នុងនាមជាតំណាងមួយរូបរបស់រាជរដ្ឋាភិបាល និងរបស់គណបក្សប្រជាជនកម្ពុជាលោកបានពាំនាំមកនូវសេចក្តីនឹករលឹកការផ្តាំផ្ញើសាកសួរសុខទុក្ខនិងពរសព្ទសាធុការក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិពីសំណាក់ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ជាពិសេសពីសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែនជូនដល់បងប្អូនពលករចំណាកស្រុកទាំងអស់សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយនិងសូមឆ្នាំថ្មីនាំមកនូវជោគជ័យសេរីសួស្តីគ្រប់ប្រការដល់បងប្អូនខ្មែរទាំងអស់។ លោក ស្តើង សុខុម ក៏បានកោតសរសើរចំពោះបងប្អូនទាំងអស់ដែលបានធ្វើចំណាកស្រុកទៅធ្វើការនៅក្នុងប្រទេសនិងក្រៅប្រទេសដែលជាការ រួយមចំណែកមួយដ៏សំខាន់មិនត្រឹមតែជួយលើកកំពស់ជីវភាពរស់នៅរបស់គ្រួសារប៉ុណ្ណោះទេតែវាក៏បានរួមចំណែកធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសមានការរីកចំរើនផងដែរ ។ លោកបានបន្តថាលំហូរចំណាកស្រុករបស់ពលករខ្មែរគឺវាស្របទៅនឹងគោលការណ៍សកលនៃលក្ខណៈសេដ្ឋកិច្ច។ត្រង់ចំណុចនេះលោកពន្យល់ថាការបញ្ជូនពលករទៅក្រៅប្រទេសនឹងជួយលើកកម្ពស់សេដ្ឋកិច្ចក្នុងស្រុកជាពិសេសការទាញយកជំនាញពីប្រទេ សសេដ្ឋកិច្ចជឿនលឿនមកអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជានាពេលអនាគត ។

លោករដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបន្តថា៖រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភាបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណជំណាក់កាលទី ៤ ពិសេសការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគីដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស និងទប់ស្កាត់ទេសសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនង ជាមួយគ្រួសារនិងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តតាមរយៈការទទួលស្គាល់ជំនាញ,ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស,ការផ្តល់ប្រឹក្សាការងារធ្វើនិងការបង្កើតមុខរបរដោយខ្លួនឯង ។

នៅចំពោះមុខបងប្អូនពលករចំណាកស្រុកទាំងអស់ លោក ស្តើង សុខុម ក៏បានលើកឡើងមកពន្យល់បងប្អូនអំពីកិច្ចខិតខំរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនដែលក្រៅពីការខិតខំប្រឹងប្រែងស្វែងរកសន្តិភាព និង ការបង្រួបបង្រួមជាតិហើយនោះគឺរាជរដ្ឋាភិបាលបានខិតខំស្តារនិងអភិវឌ្ឍន៍ប្រទេសឡើងវិញតាមរយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ស្ពាន ដើម្បីធ្វើសមាហរណកម្មផ្ទៃក្នុងប្រទេសទាំងមូលធ្វើគម្លា តរវាងជនបទនិងទីក្រុងកាន់តែខិតជិតគ្នា។រាជរដ្ឋាភិបាលបានដាក់ចេញនូវចំណុចអា ទិភាព ៤ ក្នុងគោលដៅអភិវឌ្ឍន៍ប្រទេសដែលក្នុង នោះរួម មាន មនុស្ស ទឹក ផ្លូវ និង ភ្លើង ។ លោក ស្តើង សុខុម បន្តថាជាមួយកត្តាសន្តិភាព និង ចំណុចអាទិភាពទាំង ៤ បានបង្កនូវទំនុកចិត្តចំពោះវិនិយោគិនបរទេស ដែលបានចូលមកបណ្តាក់ទុនវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលបច្ចុប្បន្នគ្រាន់វិស័យឧស្សាហកម្ម និងសិប្បកម្មយើងមានរោងចក្សសរុបចំនួនជាង១.៥០០ រោងចក្រដែលភាគច្រើនជារោងចក្រកាត់ដេរសំលៀកបំពាក់ ស្បែកជើង និង មានឧស្សាហកម្មមធ្យម និង សិប្បកម្មជាង ១៥៦,៨៩០ មូលដ្ឋានហើយដែលបានស្រូបកម្លាំងពលករសរុបប្រមាណជាង ១ លាននាក់ ។ ស្របនិងការរីកចម្រើនវិស័យឧស្សាហកម្មនិងសិប្បកម្មរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើជីវភាពរស់នៅចំ ពោះកម្មករនិយោជិតដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងកើនឡើងដល់១៨២ ដុល្លារអាមេរិកហើយបើកពីរដងក្នុងមួយខែនៅឆ្នាំ២០១៩ដែលមិនទាន់គិតដល់ការទទួលបាននូវអត្ថប្រយោជន៍បន្ថែមផ្សេងទៀតពី

ការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ។ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បាននិងកំពុងជួយពលករកម្ពុជាដែលធ្វើការនៅបរទេសមានប្រមា ណជាង ១,២លាននាក់មានជាអាទិ៍ប្រទេសថៃ សាធារណរដ្ឋកូរ៉េប្រទេសម៉ាឡេស៊ី ជប៉ុន សិង្ហបុរីនិង ហុងកុង ក្នុងការធានានូវផលប្រយោជន៍ស្របច្បាប់និងមុខជំនាញបច្ចេក ទេស ។

លោក ស្តើង សុខុម បានធ្វើការពន្យល់ចំពោះបងប្អូនកម្មករទាំងអស់ថា ការធ្វើចំណាកស្រុកស្វែងរកការងារធ្វើវាគឺជាចរន្តសេដ្ឋកិច្ចមួយដែលមានលក្ខណៈជាសាកល គឺគេមកធ្វើការនៅក្នុងប្រទេសយើង យើងទៅធ្វើការនៅក្នុងប្រទេសគេបានសេចក្តីថា យើងស្វែងរកការងារដែលមានប្រាក់ខែខ្ពស់ ចំណែកគេក៏មកធ្វើការនៅក្នុងប្រទេសយើងទៅតាមជំនាញ និងសមត្ថភាពរបស់គេ ។ លោកបន្តថា រាជរដ្ឋាភិបាលបានខិតខំអូសទាញវិនិយោគទុនបរទេសមកបង្កើតរោងចក្របង្កើតការងារជូនពលរដ្ឋធ្វើ និងបានពង្រាយរោងចក្រមកតាមបណ្តាខេត្ត ដើម្បីកាត់បន្ថយនូវចំណាកស្រុក ។ លោកបានលើកឡើងថា សូម្បីនៅស្រុកកំចាយមារក៏មានរោងចក្រផងដែរក៏ប៉ុន្តែសួរថាហេតុអ្វីបងប្អូននៅតែធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស និងនៅក្រុងភ្នំពេញ និងនៅខេត្តផ្សេងៗ ? នេះជាសេរីភាពរបស់បងប្អូនក្នុងការជ្រើសរើសធម្មតាពលករតែងតែចង់បានការងារ ណាដែលមានប្រាក់ខែខ្ពស់ ហើយសក្តិសមជាមួយជំនាញនិងសមត្ថភាពរបស់ខ្លួនម្នាក់ ៗ ។ បងប្អូនទៅធ្វើការនៅប្រទេសថៃ កូរ៉េ ជប៉ុន ម៉ាឡេស៊ី ហុងកុង សិង្ហបុរី គឺក្រៅពីទទួលបានប្រាក់ខែខ្ពស់ហើយ បងប្អូននៅបានត្រឡប់មកវិញនាំមកនូវជំនាញនិងបទពិសោធន៍ការងារល្អៗមកជាមួយទៀត។

ជាមួយគ្នានេះលោក ស្តើង សុខុម ក៏បានធ្វើការរិះគន់ចំពោះអ្នកនយោបាយប្រឆាំងមួយចំនួនដែលតែងគេងចំណេញខាងនយោបាយហើយចោទរាជរដ្ឋាភិបាលថាដឹកនាំប្រទេសយូរៗទៅឲ្យពលករទៅធ្វើខ្ញុំគេ ។ លោក ស្តើង សុខុម បានលើកជាសំណួរថា ? តើពួកអ្នកនិយាយបែបនេះមាន មើលខ្លួនឯងទេថាកំពុងធ្វើអ្វីនៅក្រៅប្រទេស តើខ្លួនធ្វើការងារអី? អតីតកាលរបស់ខ្លួនទៅដល់បរទេសដំបូងធ្វើអី? អ្នកខ្លះបើកឡានតាក់ស៊ីអ្នកខ្លះលាង ចានគុយទាវនេះជាងរឿងពិត ហើយត្រូវហានទទួលស្គាល់ការពិត ។ លោកបន្តទៀតថា បងប្អូនអាចទៅភ្នំពេញ ទៅសៀមរាបមើល តើមានឃើញពួកបរទេសធ្វើការនៅភ្នំពេញទេ ពិសេសពួកប្រមុះស្រួច គឺមានគេមកធ្វើការនៅសណ្ឋាគារ នៅភោជនីយដ្ឋានឬរោងចក្រ ក្រុមហ៊ុន គឺគេមកធ្វើការនៅកម្ពុជាដោយសារនៅកម្ពុជាខ្វះអ្នកជំនាញ ដូចនេះគេមកកម្ពុជាបានប្រាក់ខែច្រើនគេមកធ្វើ ។ដំណាក់កាលតំបន់ភាវូបនីយកម្ម និង ដំណាក់កាលសកលភាវូបនីយកម្មគឺជាដំណាក់កាលនៃការពង្រីកទីផ្សារការងាររបស់យើងដែលក្នុង មួយឆ្នាំៗ កម្មករ/ការិនី របស់យើបានបញ្ជូនប្រាក់ចូលមកក្នុងប្រទេសប្រមាណជា ២.០០០ លានដុល្លារសម្រាប់ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ។កម្មករ/ការិនី ដែលធ្វើការនៅក្រៅប្រទេសក៏ដូចក្នុងប្រទេសសុទ្ធតែបានផ្ញើប្រាក់មកឲ្យឪពុកម្តាយនៅឯស្រុកកំណើត ។ នេះជារឿងធម្មតាខ្លាំងណាស់គេមិនត្រូវ ចោទរាជរដ្ឋាភិបាលថាដឹកនាំប្រទេសឲ្យប្រជាពលរដ្ឋទៅធ្វើខ្ញុំគេនោះទេ អ្នកត្រូវយល់ អ្នកត្រូវដឹងរឿងនេះ គឺមិនមែនមានតែកម្ពុជានោះទេនៅក្នុង តំបន់មានប្រទេ សជាច្រើនដូចជា ហ្វីលីពីន ថៃ ឡាវ ភូមា វៀត ណាម សុទ្ធតែមានពលករទៅធ្វើការនៅក្រៅប្រទេស ព្រោះនេះវាជាចរន្តនៃសេដ្ឋកិច្ច សា កល ។

នៅក្នុងឪកាសនោះលោករដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចក៏បានលើកឡើងផងដែរពាក់ព័ន្ធការឃោសនាអំពីការដកEBA ពីកម្ពុជាដោយលោកបាន ស្នើឲ្យពលករទាំងអស់កុំខ្វល់អ្វីទាំងអស់ សំខាន់គ្រាន់តែដឹងថាបងប្អូនមានការងារធ្វើ មានប្រាក់ចំណូលចិញ្ចឹមគ្រួសារគឺជាការស្រេច ទោះបីអ្នក ណាចង់និយាយអ្វីក៏និយាយទៅ បញ្ហាសំខាន់បំផុតគឺត្រូវខិតខំធ្វើការងាររក្សាឲ្យបាននូវសុខដុមបនីយកម្មក្នុងរោងចក្ររបស់យើង ដែលជាឆ្នាំងបាយរបស់យើង ។ ជាមួយនេះលោករដ្ឋលេខាធិការក៏បានអំពាវនាវទៅបងប្អូនពលករចំណាកស្រុកធ្វើការនៅក្រៅប្រទេសថាក្រៅពីចង់បានប្រាក់ខែខ្ពស់ហើយនោះ បងប្អូនក៏ត្រូវខិតខំរៀនសូត្រនូវចំណេះជំនាញដែលបានធ្វើនៅក្នុងប្រទេសរបស់គេមកជួយអភិវឌ្ឍន៍ប្រទេសយើងផងដែរ ។បងប្អូនក៏អាចយកចំណេះដឹងនិងបទពិសោធន៍ទាំងនោះមកបើកធ្វើអាជីវ កម្មដោយខ្លួនឯងក៏បាន ព្រោះនេះវាជាឪកាសសម្រាប់បងប្អូនអាចក្លាយខ្លួនជាម្ចាស់អាជីវ កម្មខ្នាតតូច ឬ ខ្នាតធំទៅតាមសមត្ថភាព និង

លទ្ធភាពដែលខ្លួនមាន ។ បើធ្វើបានដូចនេះបងប្អូនពិតជាបានអភិវឌ្ឍន៍ខ្លួនឯងពីអ្នកធ្វើការឲ្យគេ មកជាម្ចាស់របស់គេ ដែលចំណុចមួយដ៏សំខាន់ដែលរាជរដ្ឋាភិបាលចង់បានបំផុត ។

ជាចុងក្រោយលោក ស្តើង សុខុម បានស្នើឲ្យពលករចំណាកស្រុក និងមិនចំណាកស្រុកនៅក្នុងស្រុកកំចាយ មារទាំងអស់ត្រូវខិតខំថែរក្សាឲ្យបាន នូវអ្វីដែលកំពុងមាននៅក្នុងដៃ នោះគឺសុខសន្តិភាពមានសុខសន្តិភាពគឺមានអ្វី ទាំងអស់ទាំងការងារទាំងប្រាក់ចំណូល ទាំងសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ។ ដូចនេះត្រូវចង់ចាំថាអ្វីដែលបងប្អូនមាន មកដល់ថ្ងៃនេះគឺគណបក្សប្រជាជនកម្ពុជាជាអ្នកផ្តល់ឲ្យបងប្អូនយើងត្រូវជឿជាក់លើរាជ រដ្ឋាភិបាលកម្ពុជាដែលដឹកនាំ ដោយគណបក្សប្រជាជនកម្ពុជាដើម្បីបន្តរក្សានូវសុខសន្តិភាពនិងការ អភិវឌ្ឍប្រទេសកម្ពុជាឆ្ពោះទៅកាន់ចក្ខុវិស័យឆ្នាំ ២០៣០ជាប្រទេសដែលមានចំណូលមធ្យ មកម្រិតខ្ពស់ឈានទៅឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលខ្ពស់ ។ ជា ចុងក្រោយលោក ស្តើង សុខុម ក៏បានផ្តល់ជាថវិកាជូនបងប្អូនកម្មករ កម្មការិនី ទាំងអស់ម្នាក់ ១០.០០០ រៀលជាការ កំដរដៃ ៕

## កម្ពុជា-ថៃ នឹងចុះហត្ថលេខារួមគ្នា លើការពង្រឹង និងគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-04-18

**(ភ្នំពេញ)៖** កម្ពុជា-ថៃ នឹងចុះហត្ថលេខារួមគ្នា លើការពង្រឹង និងគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០១៩ នាទីក្រុងបាងកក ប្រទេសថៃ។ ការចុះហត្ថលេខារវាងកម្ពុជា-ថៃ នាពេលខាងមុខនេះ នឹងមានការចូលរួមពីតំណាងភាគីកម្ពុជាពីក្រសួង ចំនួន៥ បន្ថែមទៀត រួមមាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសុខាភិបាល និងក្រសួងការ បរទេស និងប្រតិបត្តិការអន្តរជាតិ។ នេះបើតាមការបញ្ជាក់ឲ្យដឹងពីលោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងសង្គម កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន ដែលជាតំណាងរប ស់ លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធ ជន និងយុវនីតិសម្បទា។

លោក ញ៉ឹក វណ្ណារ៉ា បា នលើកឡើងបែបនេះ នៅក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាង របៀបវារៈលើកទី២ ការត្រៀមប្រជុំពិនិត្យ និងចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណីសេចក្តីព្រាងផែនការ សកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តិពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជ នរង គ្រោះ ដោយអំពើជួញដូរមនុស្សរវាងកម្ពុជា- ថៃ នៅថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០១៩ នាទីក្រុងបាងកក ប្រទេស ថៃ។ កិច្ចប្រជុំនេះ រៀបចំធ្វើនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារ កាំប៉ូឌីយ៉ាណា រាជធានីភ្នំពេញ។ ថ្លែង នៅក្នុងកិច្ចប្រជុំនោះ លោក ញ៉ឹក វណ្ណារ៉ា បានលើកឡើងថា គោលបំណងនៃការបង្កើតនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពី ការគ្រប់គ្រងករណីសេចក្តីព្រាងផែនការសកម្មភាពនៃនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តិពីការគ្រប់គ្រងករណីនៃការធ្វើ មាតុភូមិនិវត្តន៍ និងសមាហរណកម្មជ នរងគ្រោះ ដោយអំពើជួញដូរមនុស្សរវាងកម្ពុជា- ថៃ គឺដើម្បី បង្កើតគោល ការណ៍ណែនាំរួម ស្តីពីការធ្វើមាតុ ភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោល បំណងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោមទៅតាមការអនុវត្តជាលក្ខណៈ អន្តរជាតិ, កំណត់តួនាទី និងការទទួលខុស ត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារ យោងពាក់ព័ន្ធនិងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរ មនុស្ស។

លោក ញឹក វណ្ណារ៉ា បានបន្ថែមថា រដ្ឋភាគីត្រូវ ផ្ដល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានានូវ ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជាប្រព័ន្ធប្រកបទៅដោយសុវត្ថិភាព និងនិរន្តរភាព ក្រោមវិសាលភាព នៃកិច្ចសហប្រតិបត្តិការរួមមាន៖

១៖ ការផ្លាស់ប្ដូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

២៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម

៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្ដល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម

គួរបញ្ជាក់ថា វិស័យសង្គមកិច្ច មានច្បាប់គោលនយោបាយ បទដ្ឋានគតិយុទ្ធជាច្រើនសម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះ ដូចជា ច្បាប់ស្ដីពីការសុំកូនអន្តរប្រទេស ច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន និងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្ដីពីការថែទាំជំនួស ចំពោះកុមារ និងបទដ្ឋានការថែទាំ ជនរងគ្រោះដោយអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅមណ្ឌល និងមានឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ៕

## ពលករខ្មែរឆ្លងដែនខុសច្បាប់ម្នាក់ ត្រូវបានភាគីថៃបញ្ជូនត្រឡប់មកវិញ

https://www.facebook.com/ General Department of Immigration - GDI April 12 at 4:47 PM

ឧត្តរមានជ័យ៖ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ម្នាក់ ពីភាគីថៃ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអានសេះខេត្តព្រះវិហារ៕

# ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩

## ឃាត់ខ្លួនមេខ្យល់នាំមនុស្សឆ្លងដែនម្នាក់ និងពលករឆ្លងដែន៥នាក់

http://www.rasmeinews.com/ April 21, 2019, 4:14 PM

*ដោយ: គ្រញូង / បាត់ដំបង:* លោកវរសេនីយ៍ឯក ពេជ្រ សារ៉ែន អធិការនគរបាលស្រុកសំពៅលូន បានដឹកនាំកម្លាំងមួយចំនួន ធ្វើការទប់ស្កាត់បទល្មើសឆ្លងដែនពិសេសពលករចំណាកស្រុកខុសច្បាប់ កាលពីថ្ងៃទី២០ខែមេសា ឆ្នាំ ២០១៩ វេលាម៉ោង ១១ និង ៣០នាទី កម្លាំងជំនាញ នៃអធិការស្រុកសំពៅលូន បានចុះបង្ក្រាប ករណីនាំមនុស្សឆ្លងដែន នៅចំណុចភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយធ្វើការឃាត់ខ្លួនមេខ្យល់បានម្នាក់ និងពលករឆ្លងដែនចំនួន៥នាក់។

លោកវរសេនីយ៍ឯកពេជ្រ ដារ៉ែនអធិការនគរបាលស្រុកសំពៅលូន បានបញ្ជាក់ថា ចំពោះមេខ្យល់ឈ្មោះ មិនទន់ ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ត្រូវបានកម្លាំងជំនាញកសាងសំណុំរឿងបញ្ជូនទៅស្នងការខេត្តដើម្បីចាត់ការបន្ត នៅរសៀលថ្ងៃទី២១ ខែមេសា។

ដោយឡែកពលករឆ្លងដែនខុសច្បាប់អធិការដ្ឋាន បានធ្វើការអប់រំ និងឱ្យធ្វើកិច្ចសន្យាឈប់ចូលទៅធ្វើការខុសច្បាប់ ត្រូវទៅធ្វើឯកសារស្របច្បាប់ ទើបមិនមានការចាប់ចង ឬឃាត់ខ្លួនពីសន្តិសុខថៃរួចដោះលែងឱ្យត្រឡប់ទៅធ្វើលិខិតឱ្យបានត្រឹមត្រូវ៕ *ល*

# ពលករខ្មែរត្អូញត្អែរថា សមត្ថកិច្ចខ្មែរ និងថៃនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ យកលុយពីពួកគាត់ ដើម្បីឱ្យបានឆ្លងដែន ទៅធ្វើការងារនៅថៃឲ្យឆាប់រហ័ស

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2019-04-19

ពលករខ្មែរត្អូញត្អែរថា សមត្ថកិច្ចខ្មែរ និងថៃនៅច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ បានបង្ខំយកលុយពីពួកគាត់ម្នាក់ពី ៤ ទៅ ៦ម៉ឺនរៀល ដើម្បីជាថ្នូរបានឆ្លងដែន ទៅធ្វើការងារនៅថៃឲ្យឆាប់រហ័ស ក្នុងពលករខ្មែររាប់ពាន់នាក់ កំពុងសម្រុកចូលថៃ។ មន្ត្រីអង្គការសង្គមស៊ីវិលនៅបន្ទាយមានជ័យចាត់ទុកបញ្ហានេះថា ជាការប្រព្រឹត្តអំពើពុករលួយ ដើម្បីបានប្រាក់ពីពលករដោយខុសច្បាប់។

ពលករ លោក ជឹង វណ្ណា ថ្លែងប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី១៩មេសាថា លោកនៅលេងបុណ្យចូលឆ្នាំខ្មែរឯស្រុកកំណើតបាន៦ថ្ងៃប៉ុណ្ណោះ ហើយក៏ប្រញាប់ត្រឡប់ទៅធ្វើការនៅលើទូកនេសាទរបស់ថៃនៅខេត្តសមុទ្រសាខន (Samut Sakhon) វិញភ្លាម ព្រោះប្រសិនបើនៅយូរនាំឱ្យខាតការងារនិងគ្មានបាត់បង់ប្រាក់ចំណូល ព្រោះនៅផ្ទះគ្មានការងារធ្វើនោះទេ។ ពលកររូបនេះអះអាងទៀតថា ទម្រាំតែឆ្លងផុតច្រកព្រំដែនត្រូវចំណាយពេលអស់មួយថ្ងៃ និងត្រូវស្នាក់នៅព្រំដែនខាងដីថៃមួយយប់ ដោយសារពលករសម្រុកឆ្លងដែនច្រើនរាប់ពាន់នាក់ រហូតដល់អស់រថយន្តឈ្នួលធ្វើឱ្យមិនអាចបន្តដំណើរទៅទីក្រុងបាងកកបានទេ។ លោកបន្តថា ប៉ូលិសអន្តោប្រវេសន្តខ្មែរនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានយកប្រាក់ពីលោកចំនួន ១០០បាត ឬស្មើ ១២.៧០០រៀល ដើម្បីជាថ្នូរប្រថាប់ត្រាលើលិខិតឆ្លងដែន។ លោកថា ពេលទៅដល់ដីថៃ ត្រូវតម្រង់ជួររង់ចាំឱ្យប៉ូលិសថៃប្រថាប់ត្រាលើលិខិតឆ្លងដែនអស់ជាង ៤ម៉ោងទៀត ហើយទម្រាំរួចរាល់ គឺម៉ោង ៦ល្ងាច៖ «ខាងខ្មែរ គឺជាទម្លាប់គេ ហើយត្រូវបង់លុយឱ្យប៉ូលិស ១០០បាត គឺពេលយើងប្រថាប់ត្រាចូលថៃ គឺអស់ ១០០បាត គឺយើងតែឱ្យគេ ព្រោះពេលគេប្រថាប់ត្រាលិខិតឆ្លងដែនហើយ គេមិនទាន់ឱ្យយើងវិញទេ គឺទារលុយពីយើង ១០០បាតសិន បានគេហុចលិខិតឆ្លងដែន។ ខ្ញុំអន់ចិត្តណាស់ ព្រោះអីអ្នកធ្វើការមានប្រាក់រដ្ឋហើយយកលុយពីខ្ញុំទៀត»។

ចំណែកប្រជាពលរដ្ឋម្នាក់ទៀតរស់នៅក្រុងប៉ោយប៉ែត លោក ឆាំ បារាំង ដែលបានទៅពិនិត្យនៅព្រំដែនប៉ោយប៉ែត ថ្លែងថា ចាប់តាំងពីបុណ្យចូលឆ្នាំខ្មែររួចមក គឺនៅច្រកព្រំដែនមួយនេះ មានពលករខ្មែរឆ្លងដែនយ៉ាងណែនណាន់តាន់តាប់តាំងពីព្រឹកដល់យប់។ លោកបន្តថា ការឆ្លងដែននេះពលករមានជម្រើស ២យ៉ាង គឺឆ្លងដែនដោយឆាប់ ត្រូវបង់ប្រាក់ប៉ូលិសខ្មែរ ២៥.០០០រៀលក្នុងម្នាក់ ហើយខាងប៉ូលិសថៃពី ៤ម៉ឺនទៅ ៦ម៉ឺន ៥ពាន់រៀល ក្នុងម្នាក់ និងជម្រើសទី២ គឺឆ្លងដែនតាមធម្មតា ត្រូវរង់ចាំយូរតាមលេខរៀងដោយមិនមានការបង់ប្រាក់នោះទេ តែត្រូវរង់ចាំរយៈពេលជាច្រើនម៉ោង៖ «ពលករនៅហៀកន្លែងប៉ូលិសខ្មែរនៅច្រកព្រំដែន ខាងថៃកន្លែងគេធំផងនៅមានមនុស្សរាប់រយនាក់។ ខាងខ្មែរអ្នកខ្លះចេញទៅមិនកើតនៅដេកផ្ទះសំណាក់ខ្លះនៅចិញ្ចើមផ្លូវខ្លះ។ អ្នកខ្លះបើគ្រាន់តែសរសេរអស់តែ ៤០បាតទេ ដូចអ្នកដែលចូលបានមុខគេរង់ចាំតាំងពីយប់។ អ្នកខ្លះអង្គុយផ្ដុំគ្នារាប់លុយក៏មាន ហើយខ្ញុំឈរថតពួកគាត់ តែខាងថៃគេមកដេញខ្ញុំមិនឱ្យថត ហើយគេយកទូរស័ព្ទពីខ្ញុំលុបរូបថតអស់ នៅទីនោះមានខ្មែរធ្វើការឱ្យថៃជិត ១០នាក់។ ពួកគេជាអ្នកដើរយកលុយពីពលករខ្មែរ»។

ឆ្លើយតបនឹងបញ្ហានេះនាយរងប៉ូលិសអន្តោប្រវេសន្តប្រចាំច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត លោក នឹម វុត្ថា មានប្រសាសន៍ប្រាប់អាស៊ីសេរីថា ចាប់ពីរួចបុណ្យចូលឆ្នាំខ្មែរមក គឺមានពលករឆ្លងដែនទៅធ្វើនៅប្រទេសថៃតាមច្រកព្រំដែន ដែលលោកប្រចាំការយ៉ាងច្រើនកុះករ។ ក៏ប៉ុន្តែលោកអះអាងថា ប៉ូលិសខ្មែរមិនបានយកលុយពីពលករដូចការចោទប្រកាន់នោះទេ៖ «បានដឹងថាច្រើន ក៏ប៉ុន្តែការដំណើរជូនពលរដ្ឋ គឺបានទាន់ពេល ជាពិសេស គឺខ្ញុំបានជួយផ្នែកស្ត្រី និងផ្នែកចាស់ជរា គឺជួយសម្រួលប្រថាប់ត្រាជូនពួកគាត់មុន។ ខាងខ្ញុំប្រមូលកម្លាំងទៅទាំងអស់ ដើម្បីជួយសម្រួលពលករបានឆ្លងដែនឆាប់» ។

កន្លងមន្ត្រីប៉ូលិសទទួលស្គាល់ថា ពួកគេបានយកលុយពីពលករខ្មែរ ប៉ុន្តែមិនមែនជាលុយពុករលួយនោះទេ។ លុយនោះជាលុយទឹកតែតែប៉ុណ្ណោះ ទោះបីជាយ៉ាងណា សង្គមស៊ីវិលថា លុយទឹកតែនេះ ជាលុយពុករលួយ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្ស អាដហុក (Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ច័ន្ទគា មន្ត្រីប៉ូលិសតាមច្រកព្រំដែនមិនត្រឹមតែយកលុយក្រៅផ្លូវការពីពលករប៉ុណ្ណោះទេ គឺបានហាមឃាត់ពលករមិនឱ្យពួកគេថតរូបនៅពេលឆ្លងដែននោះទៀតផង។ លោកចាត់ទុកការយកលុយក្រៅផ្លូវការនេះថា ជាក្រុមសមត្ថកិច្ចឱកាសនិយមក្នុងការកេងចំណេញប្រាក់ពីពលករ និងការរួមគ្នាប្រព្រឹត្តអំពើពុករលួយដោយខុសច្បាប់៖ «ការនិយាយរបស់ប្រមុខរដ្ឋាភិបាល ដែលថា ការអនុវត្តតាមច្បាប់ ហាក់ដូចមន្ត្រីដែលគិតគូពីលុយដាក់ក្នុងហោប៉ៅរបស់ខ្លួន លែងគិតអំពីច្បាប់ហើយ។រឿងនេះខ្ញុំគិតថា គួរតែដកមន្ត្រីប្រចាំការតាមច្រកព្រំដែនទាំងនោះចេញឱ្យអស់ទៅ ហើយរកអ្នកណា ដែលឈាមថ្មីរបស់ពលរដ្ឋ ស្រលាញ់ពលរដ្ឋខ្មែរចេះជួយចេះដឹងអំពីទុក្ខធុរៈរបស់ពលរដ្ឋខ្មែរគួរតែដាក់គាត់ជំនួសវិញ ព្រោះតួនាទីរបស់គាត់ការពារបំពេញបន្ថែមធ្វើឱ្យជីវភាពពលរដ្ឋប្រសើរឡើង អ៊ីចឹងតើមន្ត្រីទាំងនោះបានបំពេញ ឬបានបន្ថែមធ្វើបាបដល់ពលរដ្ឋ»។ លោកបន្តថា ប្រធានអង្គភាពប្រឆាំងអំពើពុករលួយត្រូវចាត់វិធានទៅលើមន្ត្រីខិលខូចទាំងនេះតាមផ្លូវច្បាប់ជាបន្ទាន់ និងមិនត្រូវលើកលែងឱ្យរួចខ្លួនជាដាច់ខាត ព្រោះមន្ត្រីទាំងនេះគាបសង្កត់ធ្វើបាបដើម្បីយកលុយពីពលករខ្មែរ។

អាស៊ីសេរីមិនអាចទាក់ទងប្រធានអង្គភាពប្រឆាំងអំពើពុករលួយលោក ឱម យ៉ិនទៀង និងអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេនៅថ្ងៃទី១៩ មេសា ដោយទូរស័ព្ទចូលជាច្រើនលើកតែពុំមានអ្នកទទួល។

ប៉ុន្តែថ្មីៗ នេះ លោក ខៀវ សុភ័ក្រ ផ្តល់សម្ភាសន៍ដល់សារព័ត៌មានក្នុងស្រុកថា ប៉ូលិសមិនមានទោសទេ ព្រោះរឿងនេះជាកំហុសរបស់ពលករ ដោយសារពួកគាត់ចង់បានឆ្លងដែនឆាប់រហ័ស។

ប៉ុន្តែលោក ស៊ុំ ច័ន្ទគា លើកឡើងថា បញ្ហានេះគ្រាន់តែការឆ្លើយដោះសាយករួចខ្លួនប៉ុណ្ណោះ ព្រោះព្រោះសមត្ថកិច្ចបានអនុវត្តផ្ទុយពីច្បាប់មន្ត្រីរាជការ ដែលហាមឃាត់មិនឱ្យមន្ត្រីរបស់រដ្ឋប្រព្រឹត្តអំពើពុករលួយនោះ ហើយសមត្ថកិច្ចត្រូវសម្រួលធ្វើយ៉ាងឱ្យពលករឆ្លងដែនបានឆាប់រហ័សទៀតផង គឺមិនមែនឆ្លៀតឱកាសមានពលករឆ្លងដែនច្រើន ហើយនាំយកលុយពីពលករ ដោយយកលេសរត់ការឱ្យឆាប់រហ័សនោះទេ៕

## ពលករខ្មែរដែលសម្រុកចូលទៅធ្វើការនៅថៃវិញត្រូវអាជ្ញាធរព្រំដែនច្រកដូងទារលុយ

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2019-04-19

តំណាងពលករខ្មែរនៅប្រទេសថៃ លោក ស៊ុន សីហា បញ្ជាក់ថា ចាប់ពីថ្ងៃទី១៧ មេសាមក ពលករខ្មែរ នាំគ្នាចេញពីស្រុកកំណើតរៀងៗខ្លួន សម្រុកចូលទឹកដីថៃវិញរាប់ពាន់នាក់ក្នុងមួយថ្ងៃៗ ក្រោយពីពិធីចូលឆ្នាំថ្មីបានបញ្ចប់ភ្លាមៗ កាលពីថ្ងៃទី១៦ មេសា មក តាមច្រកព្រំដែនដូង ឬច្រកបានទ្បែម ក្នុងខេត្តបាត់ដំបង និងច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ លោក សីហា បញ្ជាក់ថា ការវិលត្រលប់មកថៃវិញនេះ មន្ត្រីនគរបាលច្រកដូង តម្រូវឱ្យពលករទិញសំបុត្រចូលម្នាក់តម្លៃ ១ពាន់រៀលទេ ប៉ុន្តែពេលដូរចូលទឹកដីខ្មែរមានមនុស្សជួយរៀបចំសណ្តាប់ធ្នាប់ពេលដើរចូលទឹកដីថៃ តម្រូវឱ្យបង់លុយម្នាក់៦០បាត ឬស្មើ៦ពាន់រៀលទៀត។ លោកបន្ថែមថា បុគ្គលដែលតម្រូវឱ្យពលករបង់លុយនោះនិយាយភាសាខ្មែរ និងស្លៀកស៊ីវិល៖ «មកដល់ច្រកដូងហ្នឹង គឺទិញពីមន្ត្រីអន្តោប្រវេសន៍ខ្មែរ មកដល់ទឹកដីថៃ មានមន្ត្រីខ្មែរផង ថៃមកប្រាប់ពលករឱ្យបង់លុយម្នាក់៦០បាត មិនដឹងជាថ្លៃអ្វី ហើយមិនឱ្យពលករប្រើទូរសព្ទដៃ ឬថតរូបអ្វីនោះទេ»។

អាស៊ីសេរី មិនអាចទាក់ទងមន្ត្រីច្រកដូង ដើម្បីសុំការឆ្លើយបំភ្លឺ ជុំវិញការចោទប្រកាន់នេះ បាននៅឡើយទេ កាលពីថ្ងៃទី១៨ មេសា។

កាលពីមុនចូលឆ្នាំថ្មី ពលករខ្មែរធ្វើការនៅប្រទេសថៃរាប់ពាន់នាក់ ដណ្ដើមគ្នាសម្រុកឆ្លងដែននៅតាមច្រកព្រំដែនអន្តរជាតិដូងក្នុងខេត្តបាត់ដំបង និងច្រកព្រំដែនអន្តរជាតិ ខេត្តបន្ទាយមានជ័យ ដើម្បីត្រឡប់ទៅឱ្យទាន់លេងបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ ប៉ុន្តែពេលនោះ ពលករត្អូញត្អែរថា ប៉ូលិសខ្មែរយកលុយពួកគាត់ម្នាក់១០០បាត ឬស្មើ១ម៉ឺនរៀល និងប៉ូលិសថៃប្រចាំច្រកព្រំដែន យកលុយក្រៅផ្លូវការពីពួកគាត់ម្នាក់ ២០០បាត ឬស្មើ២ម៉ឺនរៀលទៀត ដើម្បីជាថ្នូរបើកឱ្យឆ្លងដែនទៅលេងស្រុកកំណើត ទោះបីជារដ្ឋាភិបាលកម្ពុជា និងថៃ បានប្រកាសមិនអនុញ្ញាតិឱ្យយកលុយក្រៅផ្លូវការបែបនេះក្ដី។

ពលការិនីម្នាក់មានស្រុកកំណើតនៅខែត្របាត់ដំបង អ្នកស្រី អ៊ួ វាសនា បញ្ជាក់ថា អ្នកស្រី វិលត្រលប់ទៅធ្វើការនៅប្រទេសថៃវិញភ្លាមៗ កាលថ្ងៃទី១៨ មេសា ក្រោយពីបានជួបជុំក្រុមគ្រួសារ បងប្អូន នៅឯស្រុកកំណើត ក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ អ្នកស្រីបញ្ជាក់ថា អ្នកស្រី មិនអាចបង្អង់យូរនៅស្រុកកំណើតទេ ត្រូវទៅធ្វើការវិញដោយសារតែកត្តាជីវភាពគ្រួសារប្រចាំថ្ងៃ ហើយនៅស្រុកកំណើតគ្មានការងារធ្វើ៕

## ពលករខ្មែរមួយក្រុមនៅកណ្ដាលសមុទ្រលើទូកនេសាទថៃ បំពេញការងារក្នុងថ្ងៃចូលឆ្នាំ

https://www.rfa.org/khmer/news/ ដោយ យន់ សាមៀន 2019-04-13

ពលករខ្មែរមួយក្រុមធ្វើការនៅលើទូកនេសាទរបស់ថៃ នៅថ្ងៃទី១៣ មេសា នាំគ្នាទៅបំពេញការងារនៅកណ្ដាលសមុទ្រក្នុងប្រទេសម៉ាឡេស៊ី ដោយមិនបានទៅលេងបុណ្យចូលឆ្នាំប្រពៃណីជាតិនៅឯស្រុកកំណើតនោះទេ។ ពួកគាត់សោកស្ដាយដែលមិនបានទៅចូលរួមបុណ្យចូលឆ្នាំជួបជុំក្រុមគ្រួសារ និងនឹកសាច់ញាតិនៅឯស្រុកខ្មែរ។ ស្របពេលដែលបុណ្យសង្ក្រាន្តឆ្នាំថ្មីកំពុងចាប់ផ្ដើមនៅប្រទេសថៃនោះ។ មន្ត្រីអង្គការសង្គមស៊ីវិល ចាត់ទុកបញ្ហានេះថា ជាការរំលោភច្បាប់ការងាររបស់ថៃ។

ពលករខ្មែរធ្វើការនៅលើទូកនេសាទថៃទាំងនោះ ថ្លែងទាំងចង់ស្រក់ទឹកភ្នែកថា ដោយសារតែ រវល់ចុះទូកទៅនេសាទត្រីនៅកណ្ដាលសមុទ្រទើបមិនអាចចូលរួមពិធីឆ្នាំថ្មីនឹងគេ។ ពលករម្នាក់រស់នៅខេត្តកំពង់ធំ លោក ហឿន សរៀបរាប់ប្រាប់ឱ្យដឹងអាស៊ីសេរី នៅថ្ងៃទី១៣មេសាថា ដោយសារជីវភាពក្រីក្រ ជំរុញឱ្យលោកចាកចេញពីផ្ទះទៅធ្វើការងារជាពលករនៅប្រទេសថៃ ហើយបានធ្វើការនៅលើទូកនេសាទក្នុងខេត្តសមុទ្រសាខន ជិតទីក្រុងបាងកកជាង១០ឆ្នាំហើយ។លោកបន្តថា នៅក្នុងទូកនេសាទរបស់ពួកគាត់មានពលករខ្មែរចំនួន៦នាក់ ដោយបានធ្វើដំណើរចេញពីដីគោកជាប់ទីក្រុងបាងកក តាំងពីថ្ងៃទី៩ មេសាមក ហើយពេលនេះទូកនេសាទរបស់ពួកគាត់ចតនៅដែនសមុទ្រប្រទេសម៉ាឡេស៊ីៈ «ល្ងាចឡើងនាំគ្នាអង្គុយគិតហើយថា ពេលនេះគេលេងចូលឆ្នាំហើយ តែចំពោះយើងវិញមានអីទៅលេងនឹងគេ អង្គុយមើលតែផ្កាយនឹងឯង។ មុនដំបូងគាត់ថាកូនហើយម៉េចមិនមកសម្រាកបានមួយខែសិន បើមកដើម្បីលេងចូលឆ្នាំនឹងគេ ខ្ញុំថាម៉ែខ្ញុំក៏ទើបនឹងសម្រាកដែរ ខ្ញុំក៏ទ្រាំនៅធ្វើការនៅទីនោះធ្វើម៉េចបើខ្ញុំមិនមានពេល ខ្ញុំបានត្រឹមតែផ្ញើលុយឱ្យម៉ែធ្វើបុណ្យធ្វើទានប៉ុណ្ណឹងឯង មិនបានទៅទេ គាត់ថាកូនហើយ!កូន ម៉ែខំចាំមើលតែផ្លូវឃើញតែកូនគេមក អាកូនឯងមិនបានមកអង្គុយគិតទៅដូចវាអួលដើមកព្រោះម្ដាយគេម្ដាយយើងចង់ឱ្យកូនមកលេងចូលឆ្នាំ»។ ពលកររូបនេះបន្តថា ពួកគាត់មិនចង់ធ្វើការថ្ងៃបុណ្យជាតិនោះទេ ក៏ប៉ុន្តែដោយសារគ្មានជម្រើស ព្រោះជីវភាពក្រីក្រ ហើយបើឈប់សម្រាកនាំឱ្យប៉ះពាល់ដល់ការងារ ហើយម្យ៉ាងទៀតក៏មិនមានប្រាក់គ្រប់គ្រាន់សម្រាប់ចាយវាយក្នុងឱកាសបុណ្យចូលឆ្នាំដែរ។

ចំណែកពលករម្នាក់ទៀតរស់នៅខេត្តកំពង់ធំ លោក ជា ខន ថ្លែងថា បុណ្យចូលឆ្នាំខ្មែរឆ្នាំនេះលោកខុសបំណងធំ២យ៉ាង គឺទីមួយធ្វើការនៅកណ្ដាលសមុទ្រឃ្លាតឆ្ងាយពីប្រពន្ធពោះធំ ជិតគ្រប់ខែដែលកំពុងធ្វើការនៅលើដីគោកក្បែរទីក្រុងបាងកក និងទី២ មិនបានទៅចូលរួមបុណ្យចូលឆ្នាំប្រពៃណីជាតិជាមួយក្រុមគ្រួសារៈ «ខ្ញុំគិតថា ចង់ទៅលេងជុំម៉ែជុំឪដែរ តែធ្វើម៉េចបើទូកចេញមកខុសពេលទៅវិញមិនទាន់ គឺខ្ញុំចុះទូកមួយជើងនេះហើយទើបដើង

ក្រោយបានខ្ញុំសម្រាកនៅចាំប្រពន្ធពោះធំផង ប្រពន្ធបានសម្រាលកូនហើយបានសម្រាកចុះទូក ដល់ពេលខ្ញុំសម្រាកជើងនេះទៅលេងចូលឆ្នាំវាខូចពេលវេលាកាន់តែច្រើន ទៅអានៅទីនោះក៏មិនបានធ្វើការអីហើយលុយក៏អស់ទៀត ក៏ខាតពេលរកលុយផងដោយគិតឃើញដូច្នេះក៏ចុះទូកមួយជើងទៀតតែម្តងទៅ»។ លោកបន្តថា ថៅកែជនជាតិថៃមិនបានបង្ខំពួកគាត់ឱ្យធ្វើការនោះទេ ក៏ប៉ុន្តែដោយសារត្រូវវេនចុះទូកចំថ្ងៃបុណ្យចូលឆ្នាំ ហើយប្រសិនបើពួកគាត់ឈប់សម្រាកក៏មិនបានប្រាក់ខែដែរ ព្រោះពុំមានអ្នកធ្វើការជំនួស។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ទទួលបន្ទុកផ្នែកពលករ លោក លោក ចិន សំណាង ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ នៅថ្ងៃទី១៣ មេសា ដោយទូរស័ព្ទពុំមានអ្នកទទួល។

ទោះជាយ៉ាងណានាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅថាសង់ត្រាល់ (CENTRAL)លោក មឿន តុលា មានប្រសាសន៍ថា ការបង្ខំឱ្យពលករធ្វើការនៅថ្ងៃបុណ្យជាតិ គឺជាការរំលោភច្បាប់ការងាររបស់ប្រទេសថៃ ព្រោះច្បាប់ថៃ បានកំណត់ឱ្យកម្មករ ឬពលករ ឈប់សម្រាកនៅថ្ងៃបុណ្យជាតិ បើទោះបីជាពួកគេត្រឡប់ទៅលេងស្រុកកំណើត ឬមិនទៅក៏ដោយ ក៏ពួកគេត្រូវបានឈប់សម្រាកដែរ៖ «ទោះជាយ៉ាងណាក៏ដោយនេះជាភស្តុតាងមួយថ្មីទៀត ដែលបង្ហាញថារដ្ឋាភិបាលថៃមិនទាន់បានអនុវត្តអ្វីដែលខ្លួនបានសន្យាជាមួយសហគមន៍អឺរ៉ុប ពាក់ព័ន្ធការកែសម្រួលលក្ខខ័ណ្ឌការងាររបស់ពលករនៅលើទូកនេសាទបានពេញលេញនៅឡើយទេ កន្លងមកយើងតែងតែបានលើកឡើងពីបញ្ហានេះ ហើយយើងឃើញមានការប្រែប្រួលចំនួន ដូចថៃបានផ្តល់សច្ចាប័នទៅលើអនុសញ្ញា ស្តីពីការពារសិទ្ធិពលករនៅលើទូក នេសាទក៏ដោយ ក៏ប៉ុន្តែការអនុវត្តជាក់ស្តែងនៅមានរឿងច្រើនទៀត តាំងពីលក្ខខ័ណ្ឌការងារ លក្ខខ័ណ្ឌសុខភាពសុវត្ថិភាពនិងអនាម័យនៅលើទូកជាដើម»។

កន្លងមកធនាគារពិភពលោករាយការណ៍ថា ប្រទេសថៃមានចំនួនកម្មករចំណាកស្រុកខ្ពស់ជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជិត ៤ លាននាក់ (៣.៧៦) នៅក្នុងឆ្នាំ២០១៥ ក្នុងនោះ មានពលករ២១ ភាគរយមកពីកម្ពុជា។ ចំណែកទិន្នន័យរបស់រដ្ឋាភិបាលថៃវិញ បង្ហាញថា ពលករចំណាកស្រុកកម្ពុជា ឡាវ និងភូមាដែលបានចុះឈ្មោះរួចរាល់គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួនជិត ២លាននាក់ (១,៧២៦,៤១៥) ក្នុងនោះជិត ៥ម៉ឺននាក់ ចុះឈ្មោះធ្វើការក្នុងឧស្សាហកម្មនេសាទ។

ពលករខ្មែរឱ្យដឹងថា ពួកគាត់ទាំង៦នាក់នឹងត្រឡប់ទៅដល់ដីគោកក្នុងទឹកដីថៃវិញនៅចុងខែមេសានេះ។ ពួកគេជូនពរឱ្យពលរដ្ឋខ្មែរទាំងអស់បានដើរលេងកម្សាន្តសប្បាយក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ ឱ្យបានគ្រប់ៗគ្នា និងសុំឱ្យទេវតាឆ្នាំថ្មីនេះ ជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យសិរីសួស្តីដល់ពលរដ្ឋខ្មែរទាំងអស់មានសេចក្តីសុខចំរើនរុងរឿងនៅក្នុងក្រុមគ្រួសារ៕

## ជប៉ុនបើកការប្រលងវាស់ស្ទង់សមត្ថភាពកម្មករជំនាញដែលចង់ធ្វើការក្នុងប្រទេសខ្លួន

https://thmeythmey.com/ 21, Apr 2019 , 9:29 pm ដោយ: ឌី ណារី

រដ្ឋាភិបាលជប៉ុន នៅចុងសប្តាហ៍មុនបានបើកឲ្យមានការប្រលងសមត្ថភាព សម្រាប់បេក្ខជនជាពលករបរទេសនៃប្រទេសដៃគូមួយចំនួន ដែលមានបំណងធ្វើការនៅក្នុងប្រទេសជប៉ុនលើវិស័យជាច្រើន។ នេះ គឺជាការអនុវត្តផែនការសកម្មភាពលើកដំបូងហើយរបស់រដ្ឋាភិបាលជប៉ុន បន្ទាប់ពីគោលនយោបាយថ្មីក្នុងការទទួលពលករបរទេសបានចូលជាធរមាននៅដើមខែមេសាកន្លងមកនោះ។

តាមរយៈកម្មវិធីប្រលងសមត្ថភាពដើម្បីពិនិត្យមើលកម្រិតនៃការប្រើប្រាស់ភាសាជប៉ុន ចំណេះដឹង និងជំនាញមានបេក្ខជនដែលជាពលរដ្ឋបរទេសប្រមាណជិត៤០០នាក់ បានចូលរួមប្រលងប្រជែងសម្រាប់ការងារលើវិស័យបដិសណ្ឋារកិច្ចនៅក្នុងទីតាំងចំនួនប្រាំពីរនៅក្នុងក្រុងតូក្យូ, ណាហ្គូយ៉ា និងអូសាកា។ បេក្ខជនដែលចូលរួមនេះមួយចំនួនត្រូវបានគេជឿជាក់ថា ជានិស្សិតបរទេសដែលសិក្សានៅទីនោះស្រាប់។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មានជប៉ុន Japan Times។ តាមប្រភពព័ត៌មានដដែលនោះ ក្រៅពីការបើកឲ្យមានការប្រលងធ្វើតេស្តសមត្ថភាព

នៅក្នុងប្រទេស រដ្ឋាភិបាលជប៉ុន នៅក្នុងថ្ងៃដដែលនោះ ក៏បានចាប់ផ្ដើមបើកឲ្យបេក្ខជនប្រលងប្រជែងនៅក្រៅប្រទេស សម្រាប់ការងារលើវិស័យថែទាំនៅរដ្ឋធានីម៉ានីលរបស់ហ្វីលីពីន ដែលជាប្រទេសដៃគូផងដែរ។

គួរជម្រាបផងដែរថា ដោយសារតែបញ្ហាអត្រាប្រជាជនដែលជាមនុស្សចាស់កាន់តែកើនឡើង ខណៈអត្រាប្រជាជនកើតថ្មី កាន់តែទាប ជប៉ុនត្រូវប្រឈមនឹងកង្វះកម្លាំងពលកម្មការងារ។ ហើយដើម្បីជាដំណោះស្រាយទាន់ពេល រដ្ឋាភិបាលជប៉ុន បានសម្រេចអនុវត្តគោលនយោបាយថ្មីក្នុងការទទួលកម្លាំងពលកម្មបរទេសពីប្រទេសប្រទេសដៃគូចំនួនប្រាំបី ដែលចាប់អនុវត្តពីថ្ងៃទី១ ខែមេសានេះតទៅ។ ប្រទេសទាំងប្រាំបីនេះរួមមាន វៀតណាម ចិន ហ្វីលីពីន ឥណ្ឌូណេស៊ី ថៃ មីយ៉ាន់ម៉ា កម្ពុជា និងនេប៉ាល់។ ប្រទេសទាំងបីនេះ ត្រូវមានកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹងជប៉ុនពាក់ព័ន្ធនឹងការបញ្ជូនពលរដ្ឋខ្លួនឲ្យទៅបម្រើការនៅជប៉ុនដាច់ដោយឡែកពីគ្នា។

តាមផែនការថ្មីនេះ ក្នុងរយៈពេលប្រាំឆ្នាំទៅមុខ រដ្ឋាភិបាលជប៉ុន រំពឹងថា នឹងអាចទទួលបានពលករបរទេសជាង ៣០ ម៉ឺននាក់ ដើម្បីបំពេញការងារលើវិស័យពាក់ព័ន្ធចំនួន១៤ រួមមាន បដិសណ្ឋារកិច្ច, ថែទាំ, សំណង់ និងកសិដ្ឋានជាដើម។ ពលករទាំងនោះ នឹងទទួលបានទិដ្ឋាការការងាររហូតដល់ប្រាំឆ្នាំ ឬលើសពីនេះ អាស្រ័យលើប្រភេទនៃជំនាញដែលគេមាន៕

## ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩

### ព្រឹកនេះ សម្ដេចក្រឡាហោម ស ខេង ដឹកនាំកិច្ចប្រជុំការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ និងទិសដៅបន្តឆ្នាំ២០១៩

http://www.freshnewsasia.com/ 2019-04-23

**(ភ្នំពេញ)៖** សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩នេះ ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ជាតិ ស្ដីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងលើកទិសដៅបន្ត ឆ្នាំ២០១៩។ កិច្ចប្រជុំដែលបានធ្វើនៅទីស្ដីការក្រសួងមហាផ្ទៃនេះ ក៏មានការចូលរួមពីតំណាងក្រសួង ស្ថាប័ន អភិបាលរាជធានី-ខេត្ត ស្នងការនគរបាលរាជធានី-ខេត្ត និងអ្នកពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ។

យោងតាមរបាយការណ៍របស់ គ.ជ.ប.ជ បានបង្ហាញថា ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ៖ នៅឆ្នាំ២០១៨កន្លងទៅ ក្រុមការងារអនុវត្តច្បាប់ បានបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៣៤/១៥៩ករណី បើប្រៀបធៀបនឹងឆ្នាំ២០១៧ មានការថយចុះចំនួន២៥ករណី ស្មើនឹង១៥,៧២%។ សរុបជនសង្ស័យ ដែលត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅសាលាដំបូងចំនួន២២៤/២០៣នាក់ ធៀបនឹងឆ្នាំ២០១៧ កើនឡើងចំនួន២១នាក់ (ស្រី៩៨នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន១៧នាក់ និងជនបរទេសចំនួន ៣១/២០នាក់ មាន០៩សញ្ជាតិ គឺចិន១៥នាក់, អង់គ្លេស០៦នាក់, វៀតណាម០៣នាក់, កាណាដា០២នាក់, អូស្ត្រាលីម្នាក់, ន័រវេសម្នាក់, ហុល្លង់ (Netherland) ម្នាក់, នូវែលហ្សេឡង់ម្នាក់ និងហ្វីលីពីនម្នាក់។

ក្នុងប្រតិបត្តិការបង្ក្រាប សមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ ករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទសរុបចំនួន ២៣០/៣៤៥នាក់ (ធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន១១៥នាក់) ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ៩២នាក់ អាយុពី១៥ឆ្នាំ-១៧ឆ្នាំ ចំនួន២៣នាក់ និងអាយុ១៨ឆ្នាំឡើង ១១៥នាក់ (បានបញ្ជូនទៅមន្ទីរសង្គមកិច្ច៩២នាក់ ទៅអង្គការដៃគូ០២នាក់ និងបញ្ជូនទៅគ្រួសារ ចំនួន១៦នាក់)។ ករណីអំពើជួញដូរមនុស្ស៖ បង្ក្រាបបាន ៣៩/៤៨ករណី (ប្រៀបធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន០៩ករណី) ឃាត់ខ្លួនជនសង្ស័យ ចំនួន១០៥នាក់ (ស្រី៧៨នាក់) ក្នុងនោះមានអនីតិជនម្នាក់ និងជនបរទេស០៥នាក់ សញ្ជាតិចិន។ សង្គ្រោះជនរងគ្រោះ ចំនួន៦៤នាក់ អាយុក្រោម១៥

ឆ្នាំ ០៩នាក់ អាយុពី១៥-១៧ឆ្នាំ ១០នាក់ និងអាយុ១៨ឆ្នាំឡើង ៤៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ចំនួន២០នាក់ អង្គការដៃគូចំនួន០២នាក់ និងទៅគ្រួសារចំនួន៤២នាក់)៕

## សម្តេច ស ខេង បញ្ជាឲ្យរកមុខ អ្នកនៅពីក្រោយ នៃអំពើជួញដូរមនុស្ស ទោះមានបុណ្យស័ក្តិធំ ប៉ុនណាក៏ដោយ

https://www.dap-news.com/ ByID:115 Posted on 23 April 2019 | 10:30

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងកិច្ចប្រជុំ ផ្សព្វផ្សាយរបាយការណ៍ ជាតិស្តីពីការងារប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សឆ្នាំ២០១៨ នៅព្រឹកថ្ងៃ ទី២៣ ខែមេសា ឆ្នាំ២០១៩ នេះ បានបញ្ជាឲ្យ គ្រប់ភាគីពាក់ព័ន្ធរួមគ្នា ស្វែងរកអ្នកនៅពីក្រោយខ្នង នៃអំពើជួញដូរមនុស្សឲ្យបាន ទោះបីជាពួកគេមានបុណ្យស័ក្តធំប៉ុនណា ក៏ដោយ ត្រូវតែរកឲ្យឃើញដើម្បីយកមក ផ្តន្ទាទោសតាមផ្លូវច្បាប់។

ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ របាយការណ៍ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩ នាស្ទីការក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម បានថ្លែងថា អំពើជួញដូរមនុស្សនៅតែមាន ដូច្នេះប្រជាពលរដ្ឋដែលត្រូវបានគេយកធ្វើជាកម្មវត្ថុនៃការជួញដូរនៅមិនទាន់ភ្ញាក់រលឹក ដោយមិនទាន់យល់ និងសហការជាមួយសមត្ថកិច្ច ។ សម្តេចបន្តថា អាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តរិះរកវិធានការថ្មីៗឲ្យសមស្រប និងមានប្រសិទ្ធភាពថែមទៀត ដើម្បីបង្ការ ទប់ស្កាត់ ផ្សព្វផ្សាយអប់រំ អំពើជួយដូរមនុស្សបន្ថែមទៀត ។ សម្តេចមានប្រសាសន៍បន្តទៀតថា "ខ្ញុំគិតថា បញ្ហាគន្លឹះ គឺការរកឲ្យឃើញនូវមេខ្លោង ជួញដូរមនុស្ស ។ ការពិតហើយបញ្ហានេះ ខ្ញុំគិតថា ពិតជាមានការឃុបឃិតពីមេក្លោងនៅក្នុងប្រទេស និងមេក្លោងនៅបរទេសជាជនជាតិបរទេស។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ការទទួលបានព័ត៌មានពិត អំពីមុខសញ្ញាជួញដូរមនុស្សនេះ ជារឿងសំខាន់ណាស់ដើម្បីឈានទៅបង្ក្រាបមានប្រសិទ្ធភាព ហើយដើម្បីឈានទៅលើកវិធានការ សហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធមានប្រសិទ្ធិភាព" ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឲ្យដឹងទៀតថា ជាពិសេសត្រូវយកចិត្តទុកដាក់នៅតាមច្រកព្រំដែនកម្ពុជា-ថៃ ក្នុងនោះខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងដែលជាគោលដៅសំខាន់ជាងគេ ។ សម្តេចសង្កត់ធ្ងន់ថា ជនល្មើសមិនប្រើប្រាស់ច្រកព្រំដែនអន្តរជាតិ ឬច្រកទ្វេភាគីដើម្បីនាំចេញពលករខុសច្បាប់ឡើយ។ តែជនល្មើសអាចប្រើរបៀបលួចលាក់ ដើម្បីធ្វើការជួញដូរនាំពលករចេញដោយខុសច្បាប់ចេញទៅក្រៅប្រទេស។ សម្តេចក៏បានបញ្ជា អាជ្ញាធរច្រកព្រំដែន ជាពិសេសខេត្តបន្ទាយមានជ័យ និងបាត់ដំបងត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យឲ្យបានខ្ពស់ ចំពោះអ្នកដែលមិនមានឯកសារគ្រប់គ្រាន់ ដើម្បីទប់ស្កាត់បង្ការអ្នកឆ្លងដែនខុសច្បាប់។ សម្តេចរដ្ឋមន្ត្រីបន្តទៀតថា សម្រាប់ឆ្នាំ២០១៨ បានបង្ក្រាបចាប់ឃាត់ខ្លួននិងបញ្ជូនជនល្មើស ចំនួន២២៤នាក់ ទៅតុលាកាដើម្បីផ្តន្ទាទោសក្នុងបេសកកម្មបង្ក្រាបបទល្មើសជួញដូរមនុស្សនិងអំពើអាជីវកម្មផ្លូវភេទ សរុបចំនួន១៣៤ករណី និងសង្គ្រោះជនរងគ្រោះចំនួន២៣០នាក់។ ក្នុងនោះមានក្មេងអាយុក្រោម១៥ឆ្នាំនិងអាយុពី១៥ឆ្នាំដល់១៨ឆ្នាំផងដែរ៕ ដោយ ជី លីថូ

## សម្តេចក្រឡាហោម ដាក់ផែនការ ក្នុងការងារប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស

http://www.cen.com.kh/archives/ April 23, 2019

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការងារប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩។ សម្តេចក្រឡាហោម ស ខេង បានថ្លែងថា ត្រូវស្វែងរកមេក្លោងទាំងនៅក្នុងប្រទេស និងក្រៅប្រទេសឱ្យបាន ដើម្បីយកមកកាត់ទោសតាមផ្លូវច្បាប់ ក្នុងគោលបំណងបង្ហាញទៅមតិសហគមន៍អន្តជាតិថារាជរដ្ឋាភិបាលពិតជាមានឆន្ទៈក្នុងការបង្ក្រាបការជួញដូរមនុស្ស។ នៅខេត្តបាត់ដំបង និងបន្ទាយមានជ័យត្រូវរឹតបន្តឹងច្រករបៀង ដែលជនល្មើសភាគ

ច្រើននាំពលករចេញទៅក្រៅខុសច្បាប់។ ត្រូវលើកទឹកចិត្តពលរដ្ឋដែលធ្វើចំណាកស្រុក ចេញចូលតាមច្រកអន្តរជាតិ។ ត្រូវសិក្សាស្រាវជ្រាវមូលហេតុដែលពលករធ្វើចំណាកស្រុកខុសច្បាប់ ហើយពេលបញ្ជូនមកវិញ ពិការ ឬមានបញ្ហាផ្សេងៗ។

សូមជម្រាបថា នៅក្នុងឆ្នាំ២០១៨ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរកឃើញបទល្មើសថ្មី និងបានបង្ក្រាបករណីជួលពោះជំនួស ដើម្បីនាំទារកឆ្លងដែន បានចំនួន២លើក ដោយលើកទី១ ចាប់ខ្លួនជនសង្ស័យ៥នាក់ មានស្ត្រីពពោះជំនួស៣២នាក់ និងលើកទី២ ចាប់ជនសង្ស័យបាន៣នាក់ ស្ត្រីពពោះជំនួស១១នាក់។ យោងតាមរបាយការណ៍របស់ គ.ជ.ប.ជ បានបង្ហាញថា ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ នៅឆ្នាំ២០១៨កន្លងទៅ ក្រុមការងារអនុវត្តច្បាប់ បានបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៣៤/១៥៩ករណី បើប្រៀបធៀបនឹងឆ្នាំ២០១៧ មានការថយចុះចំនួន២៥ករណី ស្មើនឹង១៥,៧២%។ សរុបជនសង្ស័យ ដែលត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅសាលាដំបូងចំនួន២២៤/២០៣នាក់ ធៀបនឹងឆ្នាំ២០១៧ កើន ឡើងចំនួន២១នាក់ (ស្រី៩៨នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន១៧នាក់ និងជនបរទេសចំនួន ៣១/២០នាក់ មាន៩សញ្ជាតិ គឺចិន១៥នាក់ អង់គ្លេស៦នាក់ វៀតណាម៣នាក់ កាណាដា០២នាក់ អូស្ត្រាលីម្នាក់ ន័រវេសម្នាក់ ហូល្លង់ម្នាក់ នូវែលហ្សេឡង់ម្នាក់ និងហ្វីលីពីនម្នាក់។

ក្នុងប្រតិបត្តិការបង្ក្រាប សមត្ថកិច្ចបានសង្គ្រោះជនរងគ្រោះ ករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទសរុបចំនួន ២៣០/៣៤៥នាក់ (ធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន១១៥នាក់) ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ៩២នាក់ អាយុពី១៥ឆ្នាំ-១៧ឆ្នាំ ចំនួន២៣នាក់ និងអាយុ១៨ឆ្នាំឡើង ១១៥នាក់ (បានបញ្ជូនទៅមន្ទីរសង្គមកិច្ច៩២នាក់ ទៅអង្គការដៃគូ០២នាក់ និងបញ្ជូនទៅគ្រួសារ ចំនួន១៦នាក់)។ ករណីអំពើជួញដូរមនុស្ស៖ បង្ក្រាបបាន ៣៩/៤៨ករណី (ប្រៀបធៀបនឹងឆ្នាំ២០១៧ ថយចុះចំនួន៩ករណី) ឃាត់ខ្លួនជនសង្ស័យ ចំនួន១០៥នាក់ (ស្រី៧៨នាក់) ក្នុងនោះមានអនីតិជនម្នាក់ និងជនបរទេស០៥នាក់ សញ្ជាតិចិន។ សង្គ្រោះជនរងគ្រោះ ចំនួន៦៤នាក់ អាយុក្រោម១៥ឆ្នាំ ៩នាក់ អាយុពី១៥-១៧ឆ្នាំ ១០នាក់ និងអាយុ១៨ឆ្នាំឡើង ៤៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ចំនួន២០នាក់ អង្គការដៃគូចំនួន០២នាក់ និងទៅគ្រួសារចំនួន៤២នាក់)៕ ដោយ ៖ កូឡាប

## សម្តេចក្រឡាហោម ស ខេង ដាក់ចេញវិធានការ ៥ចំណុច សំខាន់ៗ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់

http://freshnewsasia.com/ 2019-04-23

**(ភ្នំពេញ)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩នេះ បានដាក់ចេញវិធានការសំខាន់ៗ ចំនួន៥ចំណុច ដើម្បីឲ្យមន្ត្រីអ្នកអនុវត្ត និងសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្សនៅកម្ពុជា ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។ **វិធានការសំខាន់ៗ ដែលសម្តេចក្រឡាហោម ស ខេង ដាក់ចេញនូវក្នុងកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ជាតិ ស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ និងលើកទិសដៅបន្ត ឆ្នាំ២០១៩ រួមមាន៖**

*ទី១៖ បន្តយកចិត្តទុកដាក់ទប់ស្កាត់ឲ្យកាន់តែច្រើនបន្ថែមទៀត៖ ក្នុងន័យនេះ ឲ្យបង្កើនអប់រំផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិក វិទ្យុ ទូរទស្សន៍ និងតាមបណ្តាញផ្សព្វផ្សាយសង្គម ក៏ដូចជាការបិតផ្សាយសារ ការសម្តែងសិល្បៈ ភាពយន្តខ្នាតខ្លី និងការចែកខិតប័ណ្ណ ក៏ត្រូវបានធ្វើជាញឹកញាប់ទៅដល់ជនងាយរងគ្រោះ។

*ទី២៖ បន្តការខិតខំដើម្បីបង្ក្រាបបទល្មើសជួញដូរមនុស្ស៖ ចំណុចនេះសម្តេចបានបង្ហើមថា បញ្ហាគន្លឹះ គឺការរកឲ្យឃើញនូវមេក្លោងនៃការជួញដូរមនុស្ស។ សម្តេចជឿថា បញ្ហានេះពិតជាមានការឃុបឃិតពីមេក្លោង នៅក្នុងប្រទេស និងនៅក្រៅប្រទេស ប៉ុន្តែទោះបីជាយ៉ាងណា ការទទួលបានព័ត៌មានពិត អំពីការជួញដូរមនុស្សនេះ ជារឿង

សំខាន់ណាស់ ដើម្បីឈានទៅបង្ក្រាបមានប្រសិទ្ធភាព ហើយដើម្បីឈានទៅលើកវិធានការសហប្រតិបត្តិការ ជាមួយដៃគូរពាក់ព័ន្ធ ពិសេសនៅតាមច្រកព្រំដែនកម្ពុជា-ថៃ ដែលខេត្តបន្ទាយមានជ័យ និងបាត់ដំបងជាគោលដៅសំខាន់។

*ទី៣៖ បន្តការបើកសវនាការកាត់ទោស ផ្តន្ទាទោសដល់អ្នកដែលប្រព្រឹត្ត ល្មើស ដែលនៅសេសសល់ដើម្បីបង្ហាញមតិជាតិ និងអន្តរជាតិមើលឃើញថា កម្ពុជាមានឆន្ទៈពិតប្រាកដ ដើម្បីប្រយុទ្ធប្រឆាំងការងារជួញដូរមនុស្ស។

*ទី៤៖ បន្តយកចិត្តទុកដាក់ ដើម្បីជួយដល់ជនរងគ្រោះ ដែលត្រូវរៀបចំកន្លែងសំចតមួយបណ្តោះអាសន្នដល់ជនរងគ្រោះ មុនបញ្ជូនទៅលំនៅឋាន ហើយកន្លែងនេះក៏ជាកន្លែងមួយដែលសម្រាប់ស្រាវជ្រាវ និងសួរនាំដល់ជនរងគ្រោះ ដើម្បីស្រាវជ្រាវរកមេក្លោងផងដែរ។

*ទី៥៖ បន្តខិតខំដើម្បីស្វែងរកការគាំទ្រ និងការចូលរួមប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលចំណុចនេះសម្តេចបញ្ជាក់ថា ការងារនេះបើពឹងផ្អែកទៅលើ សមត្ថកិច្ចណាមួយមិនគ្រប់គ្រាន់នោះទេ ពោលទាល់តែមានការសហការរវាងសមត្ថកិច្ច និងសមត្ថកិច្ច ហើយសមត្ថកិច្ច និងពលរដ្ឋ ព្រមទាំងជនទាំងឡាយដែលជាកម្មវត្ថុនៃការជួញដូរ។

ជាមួយគ្នានេះ សម្តេចក្រឡាហោម ស ខេង ក៏អំពាវនាវដល់សមាជិកទាំងអស់ ក្រសួងស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរជំនាញនានាក្នុងរដ្ឋបាលខេត្ត ដែលជាខ្សែបណ្តោយរបស់ក្រសួង ដៃគូរប្រជាពលរដ្ឋ សមត្ថកិច្ចអនុវត្តច្បាប់ បន្តសហប្រតិបត្តិការជាមួយគ្នាដើម្បីទទួលបានជោគជ័យកាន់តែច្រើនបន្ថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

សូមបញ្ជាក់ ថា ក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាល ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសេនាធិការ បានបង្ក្រាប ចាប់ឃាត់ខ្លួន និងបញ្ជូនជនប្រព្រឹត្តបទល្មើស២២៤នាក់ ទៅតុលាការដើម្បីផ្តន្ទាទោស ក្នុងបេសកកម្មបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុប ១៣៤ករណី និងសង្គ្រោះជនរងគ្រោះ សរុបចំនួន ២៣០នាក់ ក្នុងនោះមានទាំងក្មេងអាយុក្រោម១៥ឆ្នាំ ៩២នាក់ អាយុពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ២៣នាក់ និងអាយុ១៨ឆ្នាំឡើង ១១៥នាក់។

ដោយឡែកស្ថាប័នតុលាការ បានអនុវត្តតួនាទីរបស់ខ្លួនរហូតដល់តំណាក់កាលជំនុំជម្រះ ករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅទូទាំងរាជធានី-ខេត្ត សរុបបានចំនួន ២១៤ករណី ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ បាន ២៧៣នាក់ (ស្រី២៥២នាក់) អនិតិជន១១៤នាក់ (ស្រី១០៧នាក់) និងបានរកឃើញជនជាប់ចោទសរុប ២៥៣នាក់ (ស្រី៤៣នាក់) ក្នុងនោះ (ចាត់ការរួច៧២ករណី ផ្តន្ទាទោសដាក់ពន្ធនាគារ ១២៥នាក់ និងកំពុងបន្តចាត់ការ ១៤២ករណី )៕

## ក្រសួងមហាផ្ទៃ ណែនាំឲ្យ នគរបាលបង្កើន វិធានការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទ ឧក្រិដ្ឋកម្មឆ្លងដែន

https://www.dap-news.com/ ByID:112 Posted on 23 April 2019 | 08:55

**ភ្នំពេញ៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាឲ្យអគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បង្កើនវិធានការក្នុងការសហការ ស្រាវជ្រាវ បង្ការ ទប់ស្កាត់ និងបង្ក្រាបឲ្យបានម៉ឺងម៉ាត់ រាល់ឧក្រិដ្ឋកម្មឆ្លងដែន ។ តាមរយៈសេចក្តីណែនាំ ស្តីពីការបង្កើនវិធានការបង្ការ ទប់ស្កាត់បង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ចេញថ្ងៃទី២២ មេសា សម្តេច ស ខេង បានថ្លែងថា ថ្មីៗនេះក្រសួងបានទទួលព័ត៌មាន និងបានធ្វើការកត់សម្គាល់ នូវសញ្ញាណទាក់ទង ដល់ការប៉ុនប៉ងលួចលាក់ ធ្វើសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែន នៅភូមិសាស្ត្រមួយចំនួន ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ។ សម្តេចបន្តថា ដើម្បីថែរក្សាពង្រឹងនូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដោយមិនទុកឲ្យមានភាពចន្លោះប្រហោង សម្រាប់ពួកឧក្រិដ្ឋជន ធ្វើសកម្មភាពបំផ្លិចបំផ្លាញ សង្គមជាតិបាន ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដល់កងកម្លាំង នគរលបាលជាតិ និងសមត្ថកិច្ចក្រោមឱវាទ ដែលមានការពាក់ព័ន្ធ ត្រូវលើកកម្ពស់ស្មារតីទទួលខុសត្រូវ ឲ្យបានជាប់ជាប្រចាំ និងចាត់វិធាន

ការ ប្រកបដោយប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ដូចជាអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ការលាងលុយកខ្វក់ ការជួញដូរមនុស្ស ការជួញដូរអាវុធ និងបទល្មើសបច្ចេកវិទ្យា ។ល។

រដ្ឋមន្ត្រីមហាផ្ទៃបញ្ជាក់ថា "ក្រសួងមហាផ្ទៃ សូមដាក់ចេញនូវបទបញ្ជា ដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ត្រូវបង្កើនវិធានការ ក្នុងការសហការស្រាវជ្រាវ បង្ការ ទប់ស្កាត់ និងបង្រ្កាបឲ្យបានម៉ឹងម៉ាត់ នៅតាមច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន កំពង់ផែសមុទ្រ និងតាមខ្សែបន្ទាត់ព្រំដែន ហើយត្រូវរាយការណ៍ស្នើសុំ គោលការណ៍ចង្អុលដឹកនាំ ជាបន្ទាន់ពីក្រសួងមហាផ្ទៃ ក្នុងករណីមានបទល្មើសកើតឡើង" ។ សម្តេច ស ខេង សង្កត់ធ្ងន់ថា អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានរដ្ឋបាល និងអង្គភាពក្រោមឱវាទដែលពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តន៍សេចក្តីណែនាំនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ៕

## ខ្មែរជាង២សែននាក់បានការងារថ្មីធ្វើ និងជិត៧ម៉ឺននៅធ្វើការក្រៅប្រទេស

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៩ ម៉ោង ០៨:០០ ព្រឹក

ឯកសារមួយរបស់រដ្ឋាភិបាលបានបង្ហាញអោយឃើញថា ប្រជាពលរដ្ឋចំនួន២០៨៤០០នាក់បានទទួលការងារថ្មីធ្វើនៅឆ្នាំ២០១៨ ហើយក៏មានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺននាក់ បានទៅធ្វើការងារនៅបរទេស ។ ឯកសារដែលសារព័ត៌មានកោះសន្តិភាពទទួលបាននោះបាននិយាយបន្តទៀតថា ក្នុងចំណោមមនុស្សទាំង២០៨៤០០នាក់ដែលបានទទួលការងារថ្មីធ្វើនោះ គឺមានស្ត្រីចំនួន១១៧៧០០នាក់ ។ ក្នុងចំណោមនោះចំនួន១៤០០០០នាក់បានធ្វើការងារនៅក្នុងប្រទេស ហើយចំនួនជិត៧ម៉ឺននាក់បានទៅធ្វើការងារនៅក្រៅប្រទេស ។ ក្នុងចំណោមទាំងអស់នោះដែរ គឺមានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺនបានទៅធ្វើការងារនៅក្រៅប្រទេស ជាពិសេសប្រទេសថៃ ចំនួន៦ម៉ឺននាក់ ប្រទេសកូរ៉េខាងត្បូង ចំនួនជិត៥០០០នាក់ និងជប៉ុនជាង៣ពាន់នាក់ ៕

## កម្ពុជា-ថៃ ចុះហត្ថលេខារួចហើយ លើករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស, មន្ត្រីកម្ពុជាចាត់ទុកថា ជាលទ្ធផលល្អ សម្រាប់ជួយជនរងគ្រោះ

http://www.freshnewsasia.com/ 2019-04-22

**(បាងកក, ថៃ)៖** មន្ត្រី កម្ពុជា-ថៃ បានចុះហត្ថលេខារួមគ្នារួចរាល់ហើយ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ទៅលើការពង្រឹង និងគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ សម្រាប់កិច្ចករណីនេះ មន្ត្រីរបស់កម្ពុជា បានបង្ហាញការជឿជាក់ថា ជាកិច្ចព្រមព្រៀងដ៏ល្អមួយសម្រាប់ការជួយដល់ជនរងគ្រោះដោយអំពើជួញដូរ។

នេះបើតាមការបញ្ជាក់ឲ្យដឹងពីលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន តំណាងរបស់លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានដឹកនាំ គណៈប្រតិភូកម្ពុជា ជាមួយនឹងតំណាងក្រសួងចំនួន ៥ទៀត រួមមាន៖ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសុខាភិបាល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អញ្ជើញទៅចុះចុះហត្ថលេខាជាមួយភាគីថៃ។ បន្ថែមពីលើនេះ លោក ញឹក វណ្ណារ៉ា ក៏បានលើកឡើងពីគោលបំណង នៃការបង្កើតនីតិវិធីប្រតិបត្តិបទដ្ឋានស្តីពី ការគ្រប់គ្រងករណីសេចក្តីព្រាងផែនការសកម្មភាព នៃនីតិវិធីប្រតិបត្តិបទដ្ឋាន ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្សរវាងកម្ពុជា-ថៃ (SOPs) ផងដែរ។

លោកបានបញ្ជាក់ថា «**កិច្ចព្រមព្រៀង (SOPs) ធ្វើឡើងដើម្បីបង្កើតគោលការណ៍ណែនាំរួម ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងពង្រឹងបទដ្ឋានប្រតិបត្តិ**

អនុលោម ទៅតាមការអនុវត្តជាលក្ខណៈ អន្តរជាតិ, កំណត់តួនាទី និងការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធ និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស»។ លោក ញ៉ឹក វណ្ណារ៉ា បានបន្ថែមថា រដ្ឋភាគីត្រូវ ផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជាប្រព័ន្ធប្រកបទៅដោយសុវត្ថិភាព និងនិរន្តរភាព ក្រោមវិសាលភាព នៃកិច្ចសហប្រតិបត្តិការរួមមាន៖

*ទី១៖ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី២៖ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*ទី៣៖ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

*ទី៤៖ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

គួរបញ្ជាក់ថា វិស័យសង្គមកិច្ច មានច្បាប់គោលនយោបាយ បទដ្ឋានគតិយុទ្ធជាច្រើនសម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះ ដូចជា ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួស ចំពោះកុមារ និងបទដ្ឋានការថែទាំ ជនរងគ្រោះដោយអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅមណ្ឌល និងមានឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ៕

## ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩

## សម្តេច ស ខេង បញ្ជាឲ្យមន្ត្រីរកមូលហេតុ ដែលពលករខ្មែរពិការភាព ពេលត្រឡប់ពីធ្វើការក្រៅប្រទេសវិញ

https://thmeythmey.com/ 24, Apr 2019 , 6:29 am ដោយ: ថ្មីៗ

ភ្នំពេញ៖ ពលករខ្មែរខុសច្បាប់មួយចំនួន ទទួលរងពិការភាព នៅពេលដែលពួកគេ ត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ។ វាជារឿងដែលមន្ត្រីមានសមត្ថកិច្ច ត្រូវសិក្សាស្រាវជ្រាវដោះស្រាយលើបញ្ហានេះ។ សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងបែបនេះ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩ នាថ្ងៃទី២៣ មេសា។

សម្តេច ស ខេង ចាត់ទុកបញ្ហាពលកររងគ្រោះនេះ ជារឿងសំខាន់មួយ ដែលមន្ត្រីពាក់ព័ន្ធទាំងអស់ មិនត្រូវឈរឱបដៃមើលនោះទេ ពោលគឺត្រូវរកវិធីដោះស្រាយបញ្ហានេះ ដើម្បីរកភាពយុត្តិធម៌ដល់ពលករខ្មែរ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ដូច្នេះថា៖«(ពលករ)ពេលដែលទៅ(ចំណាកស្រុក)នោះ ទោះបីជាទៅខុសច្បាប់ ឬមិនដឹងថាទៅរបៀបម៉េច មិនទាន់ជាមនុស្សពិការទេ។ ប៉ុន្តែពេលបញ្ជូនមកវិញ តាមច្រកហ្នឹងវាទៅជាមនុស្សពិការ ។ នេះជាបញ្ហាមួយ ដែលយើងមានការសោកស្តាយ និងឈឺចាប់ណាស់។ ពេលគាត់ទៅ គាត់ជាមនុស្សមានកាយសម្បទាគ្រប់គ្រាន់ ដៃជើង អាចមានកម្លាំងធ្វើការបាន តែពេលត្រឡប់មកវិញ បាក់ដៃម្ខាង បាក់ជើងម្ខាង ខ្វាក់ភ្នែកម្ខាង និងខ្វះភ្នែកទាំងពីរ។ នេះជាសោកនាដកម្មមួយ ដែលយើងមិនអាចឈរមើលបានទេ»។

ដើម្បីដោះស្រាយបញ្ហានេះ សម្តេច ស ខេង បញ្ជាឲ្យមន្ត្រីពាក់ព័ន្ធទាំងអស់ ត្រូវចេញមុខស្រាវជ្រាវរកមូលហេតុ និងដោះស្រាយជាមួយអាជ្ញាធរក្នុងប្រទេសនីមួយៗ ដែលបញ្ជូនពលករខ្មែររងគ្រោះ ដូចការរៀបរាប់ខាងលើឲ្យខាងតែបាន។ បើតាមសម្តេច ស ខេង ការយកចិត្តទុកដាក់ដោះស្រាយលើបញ្ហាពលករខ្មែរ រងគ្រោះដោយពិការភាព

នេះ វាក៏ជារឿងមួយល្អ សម្រាប់រដ្ឋាភិបាល ដើម្បីបញ្ចៀសការចោទប្រកាន់ ឬថ្មបាក់ទម្លាក់មកលើការដឹកនាំរបស់ខ្លួនផងដែរ។

កាលពីឆ្នាំ២០១៨កន្លងមក រដ្ឋាភិបាល បានជួយសង្គ្រោះពលករខ្មែររងគ្រោះជាង៨ពាន់នាក់ ពីបណ្តាប្រទេសនានា ។ក្នុងនោះពួកគេរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលករជាដើម។ នេះបើតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃ៕

## សម្តេច ស ខេង បញ្ជាឲ្យរឹតបន្តឹងច្រកព្រំដែនខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស

https://thmeythmey.com/ 23, Apr 2019 , 9:39 pm ដោយ: ធឿន បញ្ញាឫទ្ធិ

ភ្នំពេញ៖ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្តេច ស ខេង បញ្ជាឲ្យសមត្ថកិច្ចរឹតបន្តឹងច្រកព្រំដែនខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស។ ការបញ្ជារបស់សម្តេច ស ខេង ធ្វើឡើងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៨ និងទិសដៅឆ្នាំ២០១៩ នាថ្ងៃទី២៣ មេសានេះ។ សម្តេច ស ខេង បានកត់សម្គាល់ឃើញថា ច្រកចេញ-ចូលជាប់ព្រំដែនថៃ ទាំងពីរខាងលើនេះ គឺជាមុខសញ្ញាជួញដូរមនុស្ស យកទៅបម្រើការងារខុសច្បាប់ក្នុងប្រទេសថៃយ៉ាងសកម្ម ដែលទាមទារឲ្យអាជ្ញាធរយកចិត្តទុកដាក់ទប់ស្កាត់លើបញ្ហានេះ។ ដោយមិននិយាយពីការជួញដូរមនុស្សទៅប្រទេសឆ្ងាយៗនោះ សម្តេច ស ខេង បានសង្កត់ធ្ងន់ថា តាមរយៈច្រកព្រំដែនទាំងពីរនេះ ភាគច្រើនជនល្មើសធ្វើសកម្មភាពជួញដូរមនុស្សតាមច្រករបៀងតូចៗឆ្លងចូលប្រទេសថៃ។ បន្ថែមពីនេះសម្តេច ស ខេង ក៏បានបញ្ជាឲ្យសមត្ថកិច្ចស្រាវជ្រាវរកមេខ្លោង រួមទាំងអ្នកពាក់ព័ន្ធករណីជួញដូរមនុស្ស ទាំងក្នុងស្រុក និងក្រៅស្រុកទៀតផង។ បើតាមប្រមុខក្រសួងមហាផ្ទៃ ជនល្មើសដែលជួញដូរមនុស្សនោះ ភាគច្រើននាំពលករខុសច្បាប់ យកទៅបម្រើការងារក្នុងប្រទេសថៃ ដោយគ្មានឯកសារត្រឹមត្រូវឡើយ។

## លោក ស ខេង ឲ្យប៉ូលិសតាមរកមេជួញដូរមនុស្សទាំងក្នុង និងក្រៅប្រទេស

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 24 April 2019 | 10:31 ICT

**ភ្នំពេញៈ** លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានអះអាងកាលពីម្សិលមិញថា កម្លាំងនគរបាលត្រូវតែស្វែងរកមេខ្លោងជួញដូរមនុស្សទាំងក្នុង និងក្រៅប្រទេសឲ្យបានមកកាត់ទោសតាមច្បាប់រាល់សកម្មភាពជួញដូរមនុស្ស ដោយគ្មានការលើកលែងជាដាច់ខាត។ លោក ស ខេង បញ្ជាក់ថា៖ «ខ្ញុំគិតថា បញ្ហាគន្លឹះ គឺការរកឱ្យឃើញមេខ្លោងក្នុងការជួញដូរមនុស្ស។ បញ្ហានេះ ខ្ញុំគិតថា ពិតជាមានការឃុបឃិតពីមេខ្លោងនៅក្នុងប្រទេស និងមេខ្លោងនៅបរទេស ជាជនជាតិបរទេស។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ការទទួលបានព័ត៌មានពិត អំពីមុខសញ្ញាជួញដូរនេះ វាជារឿងសំខាន់ណាស់ ដើម្បីឈានទៅបង្ក្រាបមានប្រសិទ្ធភាព ហើយដើម្បីឈានទៅលើកវិធានការសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធមានប្រសិទ្ធភាព»។

ថ្លែងក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីសកម្មភាព និងលទ្ធផលនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាលពីម្សិលមិញនៅទីស្តីការក្រសួងមហាផ្ទៃ លោក ស ខេង បានឲ្យដឹងថានៅឆ្នាំ ២០១៨ ជនល្មើសនៅតែបន្តធ្វើសកម្មភាពយ៉ាងខ្លាំងក្លា តាមគ្រប់រូបភាពក្នុងការកេងប្រវ័ញ្ច ការជួញដូរមនុស្ស ប៉ុន្តែតាមការវាយតម្លៃសកម្មភាព និងលទ្ធផលការងារ បង្ការ ទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស របស់រាជធានី និងបណ្តាខេត្តទាំងអស់ បានរកឃើញ និងបំផ្លាញជាបន្តបន្ទាប់ ដែលអាចឆ្លើយតបទៅនឹងបញ្ហានេះ។ លោក ស ខេង បានថ្លែងថា៖ «បន្តការបើកសវនាការកាត់ទោស ផ្តន្ទាទោសដល់ជនល្មើសបន្ថែមទៀត។ ទោះបីយើងបានធ្វើប៉ុណ្ណឹង ប៉ុន្តែនៅសេសសល់ទៀត។ យើងធ្វើនេះ ដើម្បីបង្ហាញឲ្យមតិជាតិ និងអន្តរជាតិឃើញថា កម្ពុជាមានឆន្ទៈពិតប្រាកដក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ទោះបីនៅមានអំពើជួញដូរមនុស្សខ្លះមែន ប៉ុន្តែរាជរដ្ឋាភិបាលមានឆន្ទៈពិតប្រាកដ។ បើសិនមិនបាន

យកចិត្តទុកដាក់គ្រាន់តែបង្ក្រាប គ្រាន់តែឃុំខ្លួន ហើយមិនបើកសវនាការផ្តន្ទាទោស ហាក់បីដូចជាមិនមានឆន្ទៈពិតប្រាកដទេ»។

លោក ស ខេង បានថ្លែងថា៖ «ខ្ញុំសូមដាស់តឿនដល់បណ្តាខេត្តដែលមិនទាន់មានចំណាត់ការល្អឱ្យបន្តខិតខំប្រឹងប្រែងបន្ថែមទៀត ដោយត្រូវយកចិត្តទុកដាក់ បង្កើតស្នាដៃលេចធ្លោតាមវិស័យនីមួយៗឱ្យបានកាន់តែច្រើន»។ លោកបានលើកឡើងថា ឆ្នាំ ២០១៩ នេះ រាជរដ្ឋាភិបាលកម្ពុជានៅតែមានជំហរដាច់ខាត ក្នុងការពង្រឹងភាពម្ចាស់ការក្នុងការប្រឆាំងអំពើជួញដូរមនុស្ស ដោយបង្កើនការទប់ស្កាត់ និងបង្ក្រាបឱ្យកាន់តែខ្លាំងក្លាថែមទៀត មិនអនុញ្ញាតឱ្យជនល្មើសមានឱកាសពង្រីកសកម្មភាព បង្កការរងគ្រោះដល់ប្រជាពលរដ្ឋ ដោយមិនបានឆ្លើយតបនោះឡើយ ទោះបីជាជនល្មើសមានល្បិចកលកាន់តែខ្ពស់។ លោក ស ខេង ថ្លែងថា៖ «តែកម្លាំងសមត្ថកិច្ចរបស់យើង នៅតែត្រូវស្រាវជ្រាវរកបទល្មើស និងបង្ក្រាបតទៅទៀត ព្រមទាំងស៊ើបអង្កេតរកបទល្មើសថ្មីៗ បន្ថែមទៀតជាបន្តបន្ទាប់ទាំងក្នុងប្រទេស ក៏ដូចជាក្រៅប្រទេស ដោយសហការយ៉ាងជិតស្និទ្ធជាមួយសមត្ថកិច្ចដែលមានការពាក់ព័ន្ធ»។ លោក ស ខេង បានអះអាងផងដែរថា រាជរដ្ឋាភិបាលកម្ពុជា តាមរយៈ គជបជ បានប្តេជ្ញាចិត្ត ពង្រឹងការផ្សព្វផ្សាយ និងអនុវត្តអនុស្សរណៈ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ក៏ដូចជាអនុសញ្ញាអាស៊ាន និងកតិកាសញ្ញាពិភពលោក ដែលកម្ពុជាបានចុះហត្ថលេខា និងចូលរួមអនុម័តដើម្បីរួមចំណែកការពារសុវត្ថិភាព និងភាពស្របច្បាប់នៃជនទេសន្តរប្រវេសន៍និងការពារពួកគេពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព ដូច្នេះត្រូវយកចិត្តទុកដាក់នៅតាមបណ្តាច្រក ព្រំដែនកម្ពុជាថៃ ក្នុងនោះខេត្តបន្ទាយមានជ័យ និងបាត់ដំបងជាខេត្តគោលដៅសំខាន់ជាងគេ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស (គជបជ) បានបង្ហាញ របាយការណ៍ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថា ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ នៅឆ្នាំ២០១៨ក្រុមការងារអនុវត្តច្បាប់ បានបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបាន ១៣៤ ករណី បើប្រៀបធៀប ១៥៩ ករណីនៅឆ្នាំ ២០១៧ មានការថយចុះចំនួន ២៥ ករណី ស្មើនឹង ១៥,៧២%។ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការចំនួន ២២៤ នាក់ក្នុងឆ្នាំ ២០១៨ ក្នុងនោះមានទាំងស្ត្រីនិងអនីតិជន បើធៀបនឹងឆ្នាំ ២០១៧ មានតែ ២០៣ នាក់ រួមទាំងបរទេសសរុប ៥១ នាក់មានច្រើនជាតិសាសន៍។ ក្នុងប្រតិបត្តិការបង្ក្រាប ២ ឆ្នាំនេះសមត្ថកិច្ចបានសង្គ្រោះជនរង គ្រោះសរុបចំនួន ៥៧៥ នាក់ក្នុងនោះមានអាយុក្រោម ១៥ ឆ្នាំនិង ១៧ ឆ្នាំឡើង។ លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងថា៖ «ឆ្នាំ ២០១៨ បទល្មើសជួញដូរមនុស្សត្រូវបានបង្ការ ទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសជាបន្តបន្ទាប់ លទ្ធផលនៃការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសម្រេចរួមមាន ការពង្រឹងច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ បន្តការពង្រឹងការអនុវត្តច្បាប់គោលនយោបាយដែលមានស្រាប់ ការលើកកម្ពស់ការយល់ដឹងដោយមានប្រជាពលរដ្ឋចូលរួមជាង ៥ លាននាក់»។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុកបានថ្លែងដោយនៅតែមានការព្រួយបារម្ភ ចំពោះអ្នកអនុវត្តច្បាប់មិនបានអនុវត្តឱ្យអស់ពីសមត្ថភាពដែលនាំឱ្យមេខ្លោងមានឱកាសរួចខ្លួនបាន។ លោក ស៊ឹង សែនករុណា ថ្លែងថា៖ «យើងឃើញសមត្ថកិច្ចមានការចាប់ខ្លួន មានការអនុវត្តច្បាប់កន្លងមកនេះបានច្រើនហើយ ក៏ប៉ុន្តែវិធីសាស្ត្រដែលត្រូវទៅរកចាប់ខ្លួនមេខ្លោងទាំងអស់នោះ ខ្ញុំគិតថា ដូចជាមិនពិបាកទេ។ អ្នកពាក់ព័ន្ធដែលបានចាប់នោះ យើងគួរតែរកប្រភពព័ត៌មានពីអ្នកទាំងអស់នោះ។ ហេតុអ្វីបានយើងរកមេខ្លោងដែលពាក់ព័ន្ធរឿងនេះមិនបាន»៕

# ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩

## ហួសចិត្ត មុនចូលឆ្នាំក៏យក ក្រោយចូលឆ្នាំក៏យក អាជ្ញាធរឡើងមកគៀបយកលុយពីពលករដល់លើឡាន

http://www.khmershare.news/ ដោយ Khmer Share 23/04/2019

វាពិនជាឆ្អើនពេកហើយ ចំពោះសមត្ថកិច្ចតាមច្រកទ្វារព្រំដែនកម្ពុជាថៃទោះមានប្រតិកម្មពីមហាជនក៏ដូចបងប្អូនពលករផ្ទាល់និងជាពិសេសទៅទៀតសម្តេចប្រមុខរដ្ឋាភិបាលក៏ធ្លាប់ប្រកាសណែនាំកុំឲ្យសមត្ថកិច្ចយកលុយពីក្រុមពលករទាំងនោះអីទោះប៉ុន្មានក៏ដោយ តែមិនដូច្នោះទេសមត្ថកិច្ចហាក់មិនខ្វល់ពីមហាជននិងថ្នាក់ដឹកនាំប្រតិកម្មអ្វីឡើយពោលគឺនៅតែគគ្លើនប្រមូលលុយពីពលករជាដដែលទាំងចូលមកពីស្រុកថៃនិងពេលចេញទៅវិញជាដើម។ ជាក់ស្តែងកាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩នេះខណៈពលករខ្មែរយើងចាកចេញទៅធ្វើការនៅប្រទេសថៃវិញគេសង្កេងឃើញសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនបានឲ្យជនស៊ីវិលដៃជាដៃជើង និងទុកចិត្តឲ្យឡើងមកប្រមូលលុយពីពលករខ្មែរក្នុងម្នាក់ៗ១០០បាតស្មើនឹងជាង១ម៉ឺនរៀល ហើយនៅក្នុងឃ្លីបវីដេអូដែលគេបង្ហោះនោះក្នុងឡានក្រុង១គ្រឿងជិះដល់ទៅជាង៥០នាក់ឯណោះអីចឹងលុយដែលប្រមូលនោះបានប្រហែលនឹងជាង៥ពាន់បាតដែរ ។

ក្រុមពលករដែលនៅក្នុងឡានក្រុងនោះទាំងស្រីទាំងប្រុស ទោះជាត្រូវបង់ឲ្យសមត្ថកិច្ចក៏ពិតមែនតែពួកគេនៅតែរអ៊ូរទាំមិនដាច់ពីមាត់ថាសមត្ថកិច្ចមិនគួធ្វើអីចឹងទេ គ្មានអាណិតអាសូដល់កម្លាំងញើសឈាមពលករសោះ។ មានអ្នកខ្លះក៏បានជេរសមត្ថកិច្ចផងដែរ រីឯអ្នកឡើងមកប្រមូលលុយនោះក៏បាននិយាយបែបឌឺឲ្យពលករទាំងនោះទៀតថា ថតបង្ហោះហ្វេសប៊ុកទៅ ។ តែនៅក្នុងវីដេអូឃ្លីបនេះមិនដឹងថា នៅច្រកព្រំដែនចំណុចណានោះទេ ប៉ុន្តែបើតាមសម្លេងពលករនិយាយគ្នាស្តាប់ទៅដូចជានៅច្រកឡែមនៃខេត្តបាត់ដំបង ។

គួបញ្ជាក់ថា កាលពីមុនពេលចូលឆ្នាំខ្មែរក្រុមពលករដែលសម្រុកចូលមកស្រុកកំណើតវិញក្នុងគោលបំណងចូលរួមអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនិងដើម្បីបានជួបជុំគ្រួសារផងនោះពេលចូលមកក៏ត្រូវសមត្ថកិច្ចតាមបណ្តាច្រកទ្វារទាំងអស់នៅតាមព្រំដែនកម្ពុជាថៃ ទារយកលុយពីពលករទាំងនោះផងដែរ មានច្រកខ្លះយកច្រើនចាប់ពី ១០០បាតដល់ ជាង៣០០បាតឯណោះ តាមការកំណត់របស់មេច្រកព្រោះគ្មានបារ៉ែមអីត្រឹមត្រូវទេគឺយកលុយញាត់ហោប៉ៅខ្លួនឯងផ្ទាល់តែម្តង ។

ដោយសារមានបាតុភាពបែបនេះទើប លោក ហ៊ាង គឹមស្រឿន អ្នកវិភាគនយោបាយនិងតាមដានការអនុវត្តន៍សកម្មភាពសង្គម បានដាក់ពាក្យបណ្តឹងចូលទៅអង្គភាពប្រឆាំងអំពើពុករលួយដើម្បីឲ្យ លោក ឱម យ៉ិនទៀងបើកការស៊ើបអង្កេតស្រាវជ្រាវករណីនេះផងដែរ ប៉ុន្តែមកដល់ពេលនេះគេមិនទាន់ដឹងថាអង្គភាពប្រឆាំងអំពើពុករលួយបើកការស៊ើបអង្កេតដែរឬយ៉ាងណានោះទេ ព្រោះមិនទាន់ឃើញចេញលទ្ធផលស៊ើបអង្កេតឡើយ ។

ជាមួយគ្នានេះដែរមហាជនអ្នកនិយមលេងសង្គមហ្វេសប៊ុកបានសរសេរនៅក្នុងខុមិនរបស់ខ្លួនថា បានតែធ្វើបាបតែខ្មែរគ្នាឯងយកលុយពីគ្នាគ្មានអាណិតអាសូរបន្តិចសោះ អ្នកខ្លះនិយាយធ្ងន់ថា ជាអំពើថោកទាបទៀតផង។ អ្នកខ្លះថា នេះហើយជីវិតពលករខ្មែរ តើពួកយើងនៅទ្រាំ ឲ្យពួកមន្ត្រីចិត្តចោរនេះជាន់ករដល់ពេលណាទៀត ជាដើម ៕

## កម្ពុជា-ថៃ បង្ហាញរួមគ្នា អនុវត្តលើកិច្ចព្រមព្រៀងលុបបំបាត់ និងទប់ស្កាត់អំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-04-24

**(ភ្នំពេញ)៖** ភាគីកម្ពុជា និងភាគីថៃ បានបង្ហាញជំហររួមគ្នាអនុវត្តលើកិច្ចព្រមព្រៀងលុបបំបាត់ និងទប់ស្កាត់អំពើជួញដូរមនុស្ស ឲ្យនៅមានតិចតួចបំផុត ហើយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នឹងត្រូវបានលើកតម្កើង និងឲ្យមានសមភាព កុំឲ្យមានភាពរើសអើង ហើយក៏ដើម្បីជួយឲ្យជីវិតរបស់ជនរងគ្រោះ មានភាពល្អប្រសើរជាងមុន។ ការ

បង្ហាញជំហរពីភាគីកម្ពុជា-ថៃ នាពេលនេះ គឺធ្វើឡើងក្រោយមានការចុះហត្ថលេខារបស់ប្រទេសទាំងពីរ លើការពង្រឹង និងគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) នៅក្នុងប្រទេសថៃ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

ថ្លែងប្រាប់អ្នកសារព័ត៌មាន នៅព្រលានយន្តអន្តរជាតិភ្នំពេញ បន្ទាប់ពីបានដឹកនាំគណៈប្រតិភូ៥ក្រសួងវិលត្រលប់មកកាន់ប្រទេសកម្ពុជា នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាន តំណាងរបស់លោក រដ្ឋមន្ត្រី វង សូត បានលើកឡើងថា «SOP នឹងជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូបភាព។ ជាមួយគ្នានោះ ភាគីទាំងពីរបានឯកភាពគ្នាថា នឹងរៀបចំផែនការសកម្មភាពបន្ថែមមួយទៀត ដើម្បីរៀបចំកិច្ចប្រជុំបន្តទៀត ពិភាក្សាគ្នាយកមតិយោបល់ មកអនុវត្តទៅលើ SOP ដែលបានចុះហត្ថលេខានាពេលថ្មីៗនេះ ជាមួយភាគីថៃ»។ លោកបានបញ្ជាក់ថា ចំពោះការចុះហត្ថលេខា គឺទាំងភាគីកម្ពុជា និងភាគីថៃ បានសម្តែងការស្វាគមន៍ និងរីករាយចំពោះការចុះហត្ថលេខា SOP នាពេលនេះ។

គួរបញ្ជាក់ថា ការធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) គឺធ្វើឡើងដើម្បីបង្កើតគោលការណ៍ណែនាំរួមស្តីពី ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងពង្រឹងបទដ្ឋានប្រតិបត្តិអនុលោម ទៅតាមការអនុវត្តជាលក្ខណៈអន្តរជាតិ, កំណត់តួនាទី និងការទទួលខុសត្រូវ នៃអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋភាគីទាំង២ នៅក្នុងដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម, ប្រើប្រាស់ជាឯកសារយោងពាក់ព័ន្ធ និងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម និងជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

**រដ្ឋភាគីត្រូវ ផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងពេញលេញ ដើម្បីធានានូវការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ជាប្រព័ន្ធប្រកបទៅដោយសុវត្ថិភាព និងនិរន្តរភាព ក្រោមវិសាលភាព នៃកិច្ចសហប្រតិបត្តិការរួមមាន៖**

* **ទី១៖** ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និង សមាហរណកម្ម។

* **ទី២៖** ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

* **ទី៣៖** ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។

* **ទី៤៖** ការតាមដានត្រួតពិនិត្យនិងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

គួរបញ្ជាក់ថា វិស័យសង្គមកិច្ច មានច្បាប់គោលនយោបាយ បទដ្ឋានគតិយុទ្ធជាច្រើនសម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះ ដូចជា ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានការថែទាំជនរងគ្រោះដោយអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅមណ្ឌល និងមានឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ៕

## ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទីមួយឆ្នាំ២០១៩

http://gdlf-kh.com/2019/04/26/ 26/04/2019 Kao sophy ខេត្តព្រះសីហនុ

ខេត្តព្រះសីហនុ៖ នៅសាលាខេត្តព្រះសីហនុព្រឹកថ្ងៃសុក្រ ៧រោច ខែចេត្រ ឆ្នាំកុរឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ បើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំត្រីមាសទីមួយដើមឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកស្រី ហៀក ហ៊ីមុល្លី អភិបាលរង

ខេត្ត និងជាប្រធានលេខាធិការគណៈ កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ មានសមាសភាពចូលរួម ៥៣នាក់ ស្រី២៣នាក់ ។

តាមរបាយការណ៍របស់គណៈ កម្មាធិការប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុបានឲ្យដឹងថា ក្រុមការងារបង្ការទប់ស្កាត់បានចុះអប់រំផ្សព្វផ្សាយដល់សហគមន៍ប្រជាពលរដ្ឋបានចំនួន ៩១លើកដែលមានសមាសភាពចូលរួម ៤.២៤៥នាក់ ក្នុងនោះស្រី២.០១៨នាក់ ។ លទ្ធផលចុះបង្ក្រាបបាន១១ករណីឃាត់ខ្លួន ១៦មុខសញ្ញា ក្នុងនោះបង្ក្រាបជាក់ ស្តែងបានចំនួន ១១ករណី (ជនជាតិចិន ៩ករណី ) មានករណី ប្រទូសកេរ្តិ៍ ២ករណី (ចិន១ករណី) ករណីប៉ុនប៉ង រំលោភសេពសន្ថវៈ ២ករណី ការរំលោភសេពសន្ថវៈ ៤ករណីឃាត់ខ្លួន៤មុខសញ្ញា ។ ករណីសព្វកម្ម ៣ករណី ឃាត់ខ្លួន ៨មុខសញ្ញា(ចិន) ។ កិច្ចសហប្រតិបត្តិការជួយ សង្គ្រោះជនរងគ្រោះ ១១លើក ជនរងគ្រោះ៤៩នាក់ ចិន ២២នាក់ថៃ១៥នាក់ ។ បញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្ត ១១ករណីស្មើនឹង១៦មុខសញ្ញា ។

លោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្ត និងជាប្រធានលេខាធិការគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តព្រះសីហនុ បានជម្រុញក្រុមការងារជំនាញអន្តរមន្ទីរ អង្គភាព ស្ថាប័នមានភារកិច្ចនានា ក្នុងការប្រមូលផ្តុំតាមដានសកម្មភាពការងារ ពិសេសតំបន់ជាច់ស្រយាល នៅតែមានករណីរំលោភបំពានផ្លូវភេទលើកុមារដោយសារប្រើប្រាស់ជាតិស្រវឹង ។ បង្កើនបើកវគ្គអប់រំ ផ្សព្វផ្សាយតាមមូលដ្ឋាន សហគមន៍ ស្តីពីការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ដោយអនុវត្ត និងស្រាវជ្រាវមុខសញ្ញាជនសង្ស័យនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ក្លឹបកំសាន្តរាត្រី កាស៊ីណូ បង្កើតការងារផ្តល់កំលាំងផ្តល់ព័ត៌មានបម្រើឲ្យការងារបង្ការបង្ក្រាបបទ ល្មើសជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីឈានទៅលប់បំបាត់នឹងកាត់ បន្ថយអំពើជួញដូរមនុស្សនៅក្នុងខេត្តព្រះសីហនុ ។

## ទីតាំងម៉ាស្សាបង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន ត្រូវបានសមត្ថកិច្ចចុះបង្ក្រាប ចាប់ខ្លួន៣នាក់

http://www.freshnewsasia.com/ 2019-04-26

**(ភ្នំពេញ)៖** កម្លាំងនគរបាល នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយនគរបាលមូលដ្ឋានខណ្ឌដង្កោ បានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាឃីហោ កោសជប់ម៉ាស្សា ១ម៉ឺនរៀល ដែលមានបង្កប់សេវាផ្លូវភេទ បម្រើដោយអនីតិជន ឃាត់ខ្លួនមនុស្សចំនួន៣នាក់ ក្នុងនោះស្ត្រីម្ចាស់ទីតាំង១ម្នាក់ នារីរងគ្រោះចំនួន២នាក់។ ប្រតិបត្តិការនេះធ្វើឡើងកាលពីវេលាម៉ោង៩៖០០នាទីយប់ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ស្ថិតនៅផ្ទះលេខ៥៨៨ ផ្លូវ៣៧១ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយមានចង្អុលបង្ហាញពី ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការចុះដឹកនាំបញ្ជាផ្ទាល់ពីលោកស្រី កែវ សុគន្ធា ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

សមត្ថកិច្ចបានប្រាប់ភ្នាក់ងារ Fresh News ដឹងថា ស្ត្រីម្ចាស់ទីតាំងមានឈ្មោះ ជីង ថា ហៅអូន ភេទស្រី អាយុ ៣៥ឆ្នាំ ស្នាក់នៅទីតាំងម៉ាស្សាផ្ទះលេខ៥៨៨ ផ្លូវ៣៧១ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថា ទីតាំងម៉ាស្សាកោសជប់ ឃីហោ កោសជប់ម៉ាស្សា ១ម៉ឺនរៀល ចាប់ផ្តើមបើកបម្រើសេវាចាប់ពីម៉ោង ៧យប់រហូតដល់យប់ជ្រៅរំលងអាធ្រាត ដោយមាននារីក្មេងចំនួន២នាក់ រង់ចាំភ្ញៀវ មកម៉ាស្សាធម្មតាតម្លៃ១ម៉ឺនរៀល រយៈពេល១ម៉ោង និងរួមភេទ តម្លៃចាប់ពី ២៥ដុល្លារ ទៅ៣០ដុល្លារក្នុងមួយដង។ ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរ កម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន ៣នាក់ ក្នុងនោះនារីរងគ្រោះចំនួន ២នាក់ អនីតិជនទាំង២នាក់ ស្ត្រីម្ចាស់ទីតាំងម្នាក់ និងដកហូតវត្ថុតាងរួមមានស្រោមអនាម័យប្រើរួច និងមិនទាន់ប្រើប្រាស់មួយចំនួន ថែមទាំងមានលុយដុល្លារក្លែងក្លាយមួយចំនួនផងដែរ។ វត្ថុតាង ទាំងអស់ ត្រូវបាននាំយកមកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនដើម្បីបន្តការសាកសួរ។

សូមបញ្ជាក់ផងដែរ ក្រោយពេលបញ្ចប់ការសាកសួរ ស្រីម្ចាស់ទីតាំងត្រូវបាននគរបាលឃុំខ្លួនបណ្តោះអាសន្ន ដើម្បីបញ្ជូនខ្លួនទៅតុលាការចាត់ការតាមនីតិវិធី។ ចំណែកនារីរងគ្រោះទាំង២នាក់នោះ ត្រូវបាននគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## ឆ្លងដែនទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃត្រូវថៃបាញ់ស្លាប់ម្នាក់របួសម្នាក់

http://www.rasmeinews.com/ April 25, 2019, 2:00 PM

ដោយបាយ័ន/ពោធិសាត់: បុរសមានគ្នាចំនួន៧នាក់ បាននាំគ្នាឆ្លងដែនខុសច្បាប់ដោយចូលតាមច្រករបៀង ស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់ដើម្បីទៅកាប់ឈើគ្រញូងក្នុងទឹកដីថៃ។ ក្រុមនោះត្រូវបានថៃបាញ់ស្លាប់ម្នាក់របួសម្នាក់ និង៥នាក់ទៀតត្រូវនគរបាលការពារព្រំដែនវរសេនាតូច៨២៥ សហការជាមួយកម្លាំងយោធាដែលនៅក្បែរកន្លែងកើតហេតុឃាត់ខ្លួនបានទាំង៥នាក់។ ហេតុការណ៍ទាហានថៃបាញ់ប្រជាពលរដ្ឋខ្មែរបានកើតឡើងស្ថិតនៅឃុំសំរោង ស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់កាលពីវេលាម៉ោង៨ និង៤០នាទីព្រឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩នេះ។

សមត្ថកិច្ចនគរបាលវរសេនាតូច៨២៥បានបញ្ជាក់ថាករណីបង្ក្រាបក្រុមឆ្លងដែនខុសច្បាប់កាប់ឈើក្រញូងក្នុងទឹកដីថៃត្រូវសមត្ថកិច្ចឃាត់ខ្លួនបានចំនួន៥នាក់។ ចំណែក២នាក់ទៀតត្រូវបានស្លាប់និងរបួស ។សមត្ថកិច្ចបន្តថាពលរដ្ឋទាំង៥ដែលត្រូវបានឃាត់ខ្លួនគឺមានទី១ ឈ្មោះ ប៊ិច មេន អាយុ ៤៦ឆ្នាំ. ទី២ឈ្មោះព្រឹងភារិនអាយុ២១ឆ្នាំ,ទី៣. ឈ្មោះស៊ុយស៊ីមអាយុ២៨ឆ្នាំ,ទី៤ឈ្មោះចាន់លីវិចិត្រអាយុ២៣ឆ្នាំ,និងទី៥ឈ្មោះធីគុន្ធាអាយុ២០ឆ្នាំ។

ដោយឡែក២នាក់ទៀតត្រូវបានថៃបាញ់ស្លាប់ និងរបួស បច្ចុប្បន្ននៅថៃនៅឡើយ គឺមានឈ្មោះ ម៉ៅ មុំ ភេទប្រុស (ថៃបាញ់ស្លាប់ក្នុងទឹកដីថៃ) និងម្នាក់ទៀតឈ្មោះ អាន់ រិត ភេទប្រុស ( ថៃបាញ់របួស) ។អ្នកទាំង៧មានទីលំនៅភូមិព្រែក២ឃុំសំរោងស្រុកភ្នំក្រវាញខេត្តពោធិ៍សាត់។ អ្នកទាំង៥នាក់ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនឱ្យប៉ុស្តិ៍រដ្ឋបាលធ្វើតាមនីតិវិធីច្បាប់៕S/

## កម្ពុជា-ថៃ ចូលរួមវេទិកាស្តីពីការការពារកម្មករចំណាកស្រុក

https://www.postkhmer.com/ វី សុចាន់ | Publication date 26 April 2019 | 09:18 ICT

**សៀមរាប:** តំណាងរាជរដ្ឋាភិបាលកម្ពុជា-ថៃ គណៈប្រតិភូសហភាពអឺរ៉ុប ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន បានចូលរួមក្នុងវេទិកាពិភាក្សាអន្តរជាតិលើកទី២ ស្តីពី «កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស» រយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ២៤ ដល់ ២៦ ខែ មេសា ដែលរៀបចំដោយអង្គការ Civil Volunteer Group ( GVC )។

វេទិកាដែលធ្វើឡើងនៅខេត្តសៀមរាបនេះ មានគោលបំណងដើម្បីពង្រឹងការពិភាក្សារវាងអ្នកពាក់ព័ន្ធនានា រវាងកម្ពុជានិងថៃ ដើម្បីកែលម្អការអនុវត្ត គោលនយោបាយ ស្តីពីសិទ្ធិពលករចំណាកស្រុកកម្ពុជា ហើយកិច្ចពិភាក្សានេះដែរ ក៏នឹងពង្រីកទស្សនវិស័យអន្តរជាតិដោយផ្សារភ្ជាប់គោលនយោបាយ និងការអនុវត្តទៅនឹងការប្តេជ្ញាចិត្តរបស់ប្រទេសទាំង ២ ដោយគោរពទៅតាមអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិដែលបានផ្តល់សច្ចាប័ន។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ GVC។ គំនិតផ្តួចផ្តើមនេះធ្វើឡើងដោយអង្គការ GVC ក្នុងក្របខ័ណ្ឌគម្រោងដែលផ្តល់មូលនិធិ ដោយសហភាពអឺរ៉ុបស្តីពី «សិទ្ធិជនចំណាកស្រុក» ដែលផ្តល់ការគាំទ្រ និងធ្វើការតស៊ូមតិលើសិទ្ធិពលករចំណាកស្រុកកម្ពុជា នៅក្នុងប្រទេស ថៃ ដើម្បីទប់ស្កាត់អំពើហិង្សា និងការជួញដូរមនុស្ស និង «សិទ្ធិការងារ» ដែលលើកកម្ពស់ និងការពារសិទ្ធិពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាប។

គម្រោងនេះ អនុវត្តដោយអង្គការ GVC និងដៃគូរបស់ខ្លួន គឺអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LS CW) នៅកម្ពុជា និងមូលនិធិបណ្តាញលើកកម្ពស់សិទ្ធិការងារ (LPN) នៅប្រទេស ថៃ។ ការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងស្ថាប័នកម្ពុជា និងថៃគឺមានសារៈសំខាន់ណាស់ ដោយសារតែប្រជាជនកម្ពុជាជាង ១,២ លាននាក់កំពុងធ្វើការនៅក្រៅប្រទេស។ នេះបើយោងតាមសេចក្តីប្រកាសស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍ ការងារ

និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ ២០១៩-២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលត្រូវបានដកស្រង់នៅក្នុងសេចក្តីប្រកាសព័ត៌មាននេះ។

ប្រទេស ថៃ នៅតែជាប្រទេសគោលដៅសំខាន់សម្រាប់ជនចំណាកស្រុកកម្ពុជា ដែលមានជាង ៩២ ភាគរយ។ ក្នុងនោះមាន ៧៣ ភាគរយនៃជនចំណាកស្រុកបានចូលប្រទេសថៃតាមរយៈមធ្យោបាយមិនទៀងទាត់ដែលត្រូវបានវាស់វែងដោយអង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅអាស៊ីអាគ្នេយ៍ ឆ្នាំ ២០១៧។ នៅក្នុងប្រទេស ថៃ ពលករចំណាកស្រុកកម្ពុជាងាយរងគ្រោះខ្លាំង។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៃប្រទេសទាំង ២ ក៏ដោយក៏ស្ត្រី បុរស និងយុវជនដែលមានចំនួនកើនឡើង នៅតែត្រូវបានរំលោភបំពាន និងកេងប្រវ័ញ្ច។ ពួកគេជាជនរងគ្រោះនៃការ ជួញដូរមនុស្សដែលស្ថិតក្នុងករណីធ្ងន់ធ្ងរបំផុត។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលបានចូលរួមក្នុងកិច្ចពិភាក្សានោះដែរ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ដំណោះស្រាយបញ្ហាចំពោះកម្មករចំណាកស្រុកមិនទាន់អាចចេញបានភ្លាមៗនោះទេ នៅក្នុងកិច្ចប្រជុំនេះ ប៉ុន្តែនេះគឺជាការផ្តួចផ្តើមមួយដែលភាគីពាក់ព័ន្ធចាប់ផ្តើមគិតគូរ ដើម្បីឈានទៅរកការដោះស្រាយបញ្ហាឱ្យប្រសើរឡើង។ លោកស្រីបញ្ជាក់ថា បញ្ហាមានដូចជាការដោះស្រាយបញ្ហាច្បាប់ ដែលនៅសេសសល់ រឿងកេងប្រវ័ញ្ច និងការចូលទៅរកការងារធ្វើរបស់ពលករនៅប្រទេសថៃ នៅតែមានភាពខុសច្បាប់ជាដើម។ លោកស្រីបញ្ជាក់ថា៖ «គេហៅថា ឱ្យជួយគិតគ្នាភាគីសងខាង។ មិនអាចថា ភាគីណាមួយដោះស្រាយតែម្នាក់ឯងបានទេ ហើយព្រឹកមិញហ្នឹងក៏មានពលករគាត់មកនិយាយខ្លួនគាត់ ពីបទពិសោធរបស់គាត់ ពេលគាត់ទៅធ្វើការងារនៅឯស្រុកថៃហ្នឹង។ នាំគ្នាគិតទាំង-អស់គ្នាហ្នឹងទៅ ហើយសំណូមពរគាត់យ៉ាងម៉េចអីយ៉ាងម៉េច យើងស្តាប់គាត់»។ លោកស្រីបន្តថា ភាគីពាក់ព័ន្ធកំពុងពិភាក្សាគ្នាហើយមិនទាន់សម្រេចបានអ្វីនោះទេ ពីព្រោះនៅស្តាប់មតិយោបល់របស់អ្នកធ្វើការងារពាក់ព័ន្ធមកពីក្រសួង ស្ថាប័នអង្គការដៃគូសង្គមស៊ីវិល អង្គការជាតិ-អន្តរជាតិ និងជនទេសន្តរប្រវេសន៍ (ជនចំណាកស្រុក) ហើយប្រមូលសាច់រឿងទាំងអស់ ដែលនៅសេសសល់ ដើម្បីយកទៅគិតសម្រាប់រៀបចំជាគោលនយោបាយ។

លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប ដែលបានចូលរួមក្នុងវេទិកាពិភាក្សានេះបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា កិច្ចពិភាក្សានេះនឹងធ្វើការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងថៃ ដើម្បីធ្វើយ៉ាងណាឱ្យភាគីថៃគោរពសិទ្ធិពលករដោយគោរពទៅតាមក្របខ័ណ្ឌច្បាប់។ លោកស្រីបានបញ្ជាក់ទៀតថា៖ «ប្រទេសយើងជាប្រទេសបញ្ជូនពលករ ហើយគេ (ប្រទេសថៃ) ជាប្រទេសទទួលពលករ។ យើងធ្វើម៉េចដើម្បីឱ្យគេគោរពសិទ្ធិរបស់ពលករ សិទ្ធិរបស់ប្រជាពលរដ្ឋ ដោយគោរពទៅតាមគោលនយោបាយ ទៅតាមលក្ខខណ្ឌ គោរពទៅតាមសន្ធិសញ្ញា និងច្បាប់ការងារ»។

លោក មឿន តុលា ប្រធានអង្គការសង់ត្រាល់ បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ពាក់ព័ន្ធនឹងបញ្ហារបស់កម្មករចំណាកស្រុកនេះ កន្លែងខ្លះមានភាពល្អប្រសើរគ្រាន់បើ ដូចជារោងចក្រស្ពង់ដារ ដែលមានរោងចក្រសាច់មាន់ សាច់ជ្រូកឬអេឡិចត្រូនិក មួយចំនួនដែលនាំចេញទៅលក់នៅអឺរ៉ុប ឃើញមានការកែសម្រួលលក្ខខណ្ឌមួយចំនួន។ ប៉ុន្តែកន្លែងខ្លះនៅមានបញ្ហាខ្លះនៅឡើយទេ ដូចជារឿងប្រាក់ឈ្នួល លក្ខខណ្ឌការងារមួយចំនួន មានថែមម៉ោងការងារ ការរក្សាលិខិតឆ្លងដែន ដែលនៅក្នុងដៃថៅកែ ការកាត់ប្រាក់ឈ្នួល។ល។ លោក មឿន តុលា បញ្ជាក់ថា៖ «មួយទៀត ដែលយើងគួរកត់សម្គាល់ផងដែរនោះ ពលករធ្វើការនៅលើទូកនេសាទ មានខ្មែរយើងធ្វើការច្រើនដែរ។ ពួកគាត់នៅតែធ្វើការក្នុងលក្ខខណ្ឌមួយច្រើនម៉ោង ម៉ោងអត់មានកំណត់ ១៨ ម៉ោងក្នុង ១ ថ្ងៃ ឬក៏ច្រើនបំផុត ១០ ម៉ោងក្នុង ១ ថ្ងៃ»៕

## បង់ក្លាដេស ស្នើកម្ពុជា ជួយគាំពារដល់អ្នកវិនិយោគ និងពលករជំនាញរបស់ខ្លួន

https://www.dap-news.com/ ByID:117 Posted on 25 April 2019 | 18:44

**ភ្នំពេញ៖** ដើម្បីពង្រីកនិងពង្រឹង ទំហំពាណិជ្ជកម្មរវាង កម្ពុជា-បង់ក្លាដេស លោក Nazmul Quaunine ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិត បង់ក្លាដេស ប្រចាំកម្ពុជា បានស្នើលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យជួយជំរុញការគាំពារដល់អ្នកវិនិយោគ និងពលករជំនាញ

របស់ខ្លួននៅកម្ពុជា ។ នេះបើយោងតាមបណ្តាញទំនាក់សសង្គមហ្វេសប៊ុករបស់ក្រសួងការងារ។ ថ្លែងនៅក្នុងជំនួបពិភាក្សាការងារ ជាមួយលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ លោកឯកអគ្គរដ្ឋទូត បានលើកឡើងថា "អ្នកវិនិយោគបង់ក្លាដេស ចង់មកវិនិយោគនៅកម្ពុជា ហើយស្នើឱ្យលោករដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ជួយជំរុញការគាំពារ ដល់អ្នកវិនិយោគ និងពលករជំនាញផង" ។

ជាការឆ្លើយតប លោករដ្ឋមន្ត្រី បានសម្តែងនូវការស្វាគមន៍ យ៉ាងកក់ក្តៅចំពោះ អ្នកវិនិយោគបង់ក្លាដេស នឹងបានលើកឡើងទៀតថា រាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយ គាំពារអ្នកវិនិយោគក្រៅប្រទេស និងជួយសម្រួលគ្រប់មធ្យោបាយដល់ពួកគេ ដើម្បីទាក់ទាញ អ្នកវិនិយោគឱ្យមកវិនិយោគ នៅកម្ពុជាកាន់តែច្រើន ។

នៅក្នុងជំនួបនោះផងដែរភាគីទាំងពីរ ក៏បានសន្យា ផ្លាស់ប្តូរបទពិសោធន៍ ជំនាញលើវិស័យមួយចំនួន ពីគ្នាទៅវិញទៅមកផងដែរ។ ឆ្លៀតក្នុងជំនួបនោះ លោករដ្ឋមន្ត្រី បានលើកឡើង ពីភាពប្រហាក់ប្រហែល គ្នារវាងកម្ពុជា និងបង់ក្លាដេស ទាំងស្ថានភាពភូមិសាស្រ្ត ដែលមានទឹកទន្លេហូរកាត់ដូចគ្នា មានកំណើនសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា មានចំណូល GDP ប្រហាក់ប្រហែលគ្នា ការនាំចេញវិស័យកាត់ដេរសម្លៀកបំពាក់ វាយនភណ្ឌក៏ដូចគ្នា និងបានបញ្ជូនកម្លាំងពលកម្ម ទៅក្រៅប្រទេសដូចគ្នា ផងដែរ។ លោករដ្ឋមន្ត្រី ក៏បានរំឭកពីដំណើរទស្សនកិច្ច របស់លោកស្រី សេក្ខ ហាស៊ីណា នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិត បង់ក្លាដេស នៅព្រះរាជាណាចក្រកម្ពុជា កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៧ កន្លងទៅ។ លោករដ្ឋមន្ត្រីបានបន្តថា នៅក្នុងដំណើរទស្សនកិច្ចនោះ កម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ លើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតាមរយៈកិច្ចប្រតិបត្តិការនេះ កម្ពុជា-បង់ក្លាដេស បានជំរុញឱ្យសហការគ្នារវាងប្រទេសទាំងពីរ កាន់តែមានភាពជិតស្និទ្ធបន្ថែមទៀត។

ជាការឆ្លើយតប នឹងការលើកឡើងរបស់លោក អ៊ិត សំហេង លោកឯកអគ្គរដ្ឋទូតបង់ក្លាដេស បានបង្ហាញការកោតសរសើរះពីភាពរីកចម្រើននេះរបស់ប្រទេសកម្ពុជា ពិសេសគឺវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលលោកពិតជាមានការពេញចិត្ត យ៉ាងខ្លាំងក្នុងការមកបំពេញបេសកកម្ម នៅទឹកដីដ៏បវរមួយនេះ។ លោកឯកអគ្គរដ្ឋទូត បានលើកឡើងពីគោលបំណង ចង់បង្កើតឱ្យមាន កិច្ចសហប្រតិបត្តិការ លើការផ្លាស់ប្តូរជំនាញ និងបទពិសោធន៍ការងារ ទៅដល់កម្លាំងពលកម្ម នៃប្រទេសទាំងពីរ មានន័យថា កម្ពុជាអាចទទួល ការបណ្តុះបណ្តាល ពីអ្នកជំនាញបង់ក្លាដេស ហើយបង់ក្លាដេសក៏អាចមកទទួល បទពិសោធន៍ថ្មីៗពីកម្ពុជាផងដែរ។

ឆ្លើយតបនឹងសំណើទាំងនេះ ភាគីទាំងពីរ បានឯកភាពគ្នា ថានឹងបង្កើតក្រុមការងាររួមគ្នាមួយ ដើម្បីធ្វើកិច្ចការងារនេះឱ្យបានហ្មត់ចត់ និងល្អប្រសើរ សំដៅជំរុញការអភិវឌ្ឍលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាជំរុញឱ្យកិច្ចសហប្រតិបត្តិការ នៃប្រទេសទាំងពីរ មានភាពរលូនល្អប្រសើរទៅមុខ។ មួយវិញទៀត លោករដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ក៏បានជម្រាបប្រាប់ ឯកអគ្គរដ្ឋទូតបង់ក្លាដេស អំពីការគោរពអញ្ជើញ រដ្ឋមន្ត្រីក្រសួងការងារបង់ក្លាដេស ឱ្យមកបំបេញទស្សនកិច្ច នៅកម្ពុជាក្នុងពេលសាកសម ណាមួយផងដែរ ៕ ដោយៈបាន ជារ៉ូ

## កម្ពុជា-បង់ក្លាដេស ឯកភាពនឹងរៀបចំឱ្យមានការផ្លាស់ប្តូរជំនាញ និងបទពិសោធន៍ការងារទៅវិញទៅមក

http://www.freshnewsasia.com/ 2019-04-25

**(ភ្នំពេញ)៖** ក្រសួការងារកម្ពុជា និងបង់ក្លាដេស បានឯកភាពគ្នាថានឹងរៀបចំឱ្យមានការផ្លាស់ប្តូរជំនាញ និងបទពិសោធន៍ការងារពីគ្នាទៅវិញទៅមក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសទាំងពីរ ដែលបានចុះហត្ថលេខាកាលពីអំឡុងដំណើរទស្សនកិច្ចរបស់ នាយករដ្ឋមន្ត្រីបង់ក្លាដេសនៅកម្ពុជា។ ការឯកភាពគ្នានោះ ត្រូវបានធ្វើឡើងនាឱកាសលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Nazmul

Quaunine ឯកអគ្គរដ្ឋទូតបង់ក្លាដេសប្រចាំកម្ពុជា នៅទីស្តីការក្រសួងការងារ នារសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៩។

ក្នុងឱកាសនោះ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានរំឭកពីដំណើរទស្សនកិច្ចរបស់លោកស្រី សេក្ខ ហាស៊ីណា នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេសនៅកម្ពុជា កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៧ កន្លងទៅ។ នៅក្នុងដំណើរទស្សនកិច្ចនោះ កម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ តាមរយៈកិច្ចប្រតិបត្តិការនេះ កម្ពុជា-បង់ក្លាដេស បានជំរុញឱ្យសហការរវាងប្រទេសទាំងពីរ កាន់តែមានភាពជិតស្និទ្ធបន្ថែមទៀត។

តាមរយៈស្មារតីនៃអនុស្សរណៈខាងលើនេះ លោកឯកអគ្គរដ្ឋទូតបង់ក្លាដេស បានលើកឡើងពីគោលបំណងចង់បង្កើតឱ្យមានកិច្ចសហប្រតិបត្តិការលើការផ្លាស់ប្តូរជំនាញ និងបទពិសោធន៍ការងារទៅដល់កម្លាំងពលកម្មនៃប្រទេសទាំងពីរ មានន័យថា កម្ពុជាអាចទទួលការបណ្តុះបណ្តាលពីអ្នកជំនាញបង់ក្លាដេស ហើយបង់ក្លាដេសក៏អាចមកទទួលបទពិសោធន៍ថ្មីៗពីកម្ពុជាផងដែរ។ បង់ក្លាដេសក៏មានរោងចក្រមួយនៅកម្ពុជាផងដែរ ដែលមានឈ្មោះថា «មីលីណា» ហើយក៏មានពលករជំនាញតិចតួចដែរ តែអ្នកវិនិយោគបង់ក្លាដេសក៏មានបំណងចង់វិនិយោគកម្ពុជាបន្ថែម ដូច្នេះនឹងមានការបញ្ជូនពលករជំនាញបន្ថែមមកកម្ពុជាផងដែរ ដែលជាឱកាសដ៏ល្អសម្រាប់ការរៀបចំការផ្លាស់ប្តូរជំនាញ និងបទពិសោធន៍ការងាររវាងប្រទេសទាំងពីរ៕

## ទាហ៊ានថៃចាប់បានពលរដ្ឋខ្មែរ19នាក់ ឆ្លងដែនចូលប្រទេសថៃខុសច្បាប់

https://www.facebook.com/Sharenews24h/ សេីរបន្ទាន់ Sharenews 26-04-2019

កាលនៅថ្ងៃទី23 ខែមេសា ឆ្នាំ2019 ទាហ៊ានថៃចាប់បានពលរដ្ឋខ្មែរ19នាក់ បានឆ្លងដែនចូលប្រទេសថៃខុសច្បាប់ ដើម្បីកាប់ឈើគ្រញូងនៅក្នុងទឹកដីថៃ។

# ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩

## នាយករដ្ឋមន្ត្រីស្តីទី ប្តេជ្ញារក្សាចំណាត់ថ្នាក់លេខ២ ជូនកម្ពុជា ខាងផ្នែកគ្មានការ ជួញដូរមនុស្ស តែលេខ១ មិនអាចបាននោះទេ

https://www.dap-news.com/ ByID:112 Posted on 27 April 2019 | 09:26

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស បានប្តេជ្ញារក្សា ចំណាត់ថ្នាក់លេខ២ ជូនកម្ពុជា ខាងផ្នែកគ្មានការជួញដូរមនុស្ស ខណៈរាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈពិតប្រាកដក្នុង ការទប់ស្កាត់បទល្មើសនេះ ។ ថ្លែងនៅក្នុងពិធីបញ្ចុះខណ្ឌសីមា ក្នុងវត្តសិរីមានជ័យ ស្ថិតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង នៅព្រឹកថ្ងៃទី២៧មេសានេះសម្តេចក្រឡាហោម ស ខេងបានបញ្ជាក់ថា កម្ពុជាមិនអាចទទួលបានចំណាត់ថ្នាក់លេខ១ខាងផ្នែកគ្មានការជួញដូរមនុស្សនោះទេព្រោះក្រសួងការបរទេសមិនឲ្យទេ។

សូមរំលឹកថា ក្នុងវេទិកាអន្តរសាសនា ថ្នាក់ជាតិនៅកម្ពុជាលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស បានថ្លែងថា ក្រសួងការបរទេសរដ្ឋអាមេរិក បានផ្តល់ចំណាត់ ថ្នាក់លេខ២ ជូនកម្ពុជា ខាងផ្នែកគ្មានការជួញដូរមនុស្ស ។

បើយោងតាមរបាយការណ៍ របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថា គ្រាន់តែក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក មានជនរងគ្រោះ ដែលជាបុរស ស្ត្រី យុវវ័យ កុមារ ទារក ប្រមាណជិត១២លាន នាក់ កំពុងតែទទួលរងការរំលោភបំពាន បំបាត់សិទ្ធិជាមនុស្ស និងត្រូវបានកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ ក្នុងរូបភាពជាទាសភាពក្នុង សម័យទំនើប៕

# ភាគីពាក់ព័ន្ធប្រជុំពិភាក្សារកវិធីការពារពលករខ្មែរចំណាកស្រុករកការងារនៅស្រុកថៃ

https://www.rfa.org/khmer/news/ ដោយ វ៉ែន សុមេធ 2019-04-27

តំណាងរដ្ឋាភិបាលប្រទេសកម្ពុជា-ថៃ វិស័យឯកជន និងពលករ បានរៀបចំវេទិកាស្វែងរកវិធីការពារសុវត្ថិភាព និងផលប្រយោជន៍កម្មករចំណាកស្រុក រយៈពេល៣ថ្ងៃ គឺពីថ្ងៃទី ២៤ ដល់ថ្ងៃទី២៦ មេសា នៅខេត្តសៀមរាប។ តំណាងក្រសួងមហាផ្ទៃអះអាងថា កិច្ចពិភាក្សាបានបញ្ចប់តែមិនទាន់សម្រេចលទ្ធផលបែបណា ដោយភាគីពាក់ព័ន្ធនឹងយកសំណើរបស់ពលករទៅពិភាក្សាគ្នាបន្ថែម។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អ្នកស្រី ជូ ប៊ុនអេង ដែលបានចូលរួមក្នុងវេទិកាពិភាក្សា នៅខេត្តសៀមរាប ប្រាប់អាស៊ីសេរីថា កិច្ចពិភាក្សាបានបិទបញ្ចប់ហើយ តែមតិយោបល់ និងកង្វល់ របស់ពលករ នឹងត្រូវភាគីពាក់ព័ន្ធលើកយកទៅពិភាក្សាគ្នា ដើម្បីរកវិធីជួយពលករបន្ថែមទៀត។ អ្នកស្រីអះអាងថា កន្លងមករដ្ឋាភិបាលបានជួយសម្រួលដល់ពលករនៅប្រទេសថៃច្រើន ដូចជា ការចេញឯកសារ ការផ្តល់សេវាផ្នែកច្បាប់ជាដើម ប៉ុន្តែនៅតែមានចន្លោះ និងមិនទាន់ធានាសុវត្ថិភាពពេញលេញជូនកម្មករ ដូច្នេះរដ្ឋាភិបាលនឹងព្យាយាមបន្ថែមទៀត៖ «មិនទាន់ចេញជាការដោះស្រាយទេ ប៉ុន្តែយើងប្រមូលយកជាតុចូល (មតិ) មកពិភាក្សាដើម្បីយកមកគិតថា តើយើងក្នុងនាមរដ្ឋាភិបាលយើងអាចចូលរួមជួយដោះស្រាយយ៉ាងម៉េច? ចំពោះដៃគូរបស់ប្រទេសទាំងពីរនេះយើងអាចជួយអ្វីបានខ្លះចំពោះផ្នែករដ្ឋបាល និងផ្នែកគោលនយោបាយទាំងនឹង»។

អង្គការឃ្លាំមើលសិទ្ធិការងារ ឈ្មោះ ស៊ីវិល វ៉ល់លែនធាគ្រុប (Civil Volunteer Group) ហៅកាត់ថា GVC បានរៀបចំកម្មវិធីពិភាក្សារយៈពេល៣ថ្ងៃ នៅខេត្តសៀមរាប ដោយបានអញ្ជើញភាគីតំណាងរដ្ឋាភិបាលកម្ពុជា-ថៃ គណៈប្រតិភូសហភាពអឺរ៉ុប ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន មកចូលរួមពិភាក្សា ជាលើកទី២ ស្តីពី កិច្ចសហប្រតិបត្តិការឆ្លងកាត់ព្រំដែនការធ្វើចំណាកស្រុក និងការជួញដូរមនុស្ស ដែលផ្តោតលើការពង្រឹងការងារ និងសមត្ថកិច្ចរបស់អ្នកពាក់ព័ន្ធនានា រវាងកម្ពុជានិងថៃ ដើម្បីកែលម្អ ការអនុវត្តគោលនយោបាយ សិទ្ធិពលករចំណាកស្រុកកម្ពុជា។

បច្ចុប្បន្នប្រជាជនកម្ពុជា ជាង ១.២លាននាក់ កំពុងធ្វើការនៅក្រៅប្រទេសខណៈប្រទេសថៃ នៅតែជាប្រទេសគោលដៅសំខាន់ សម្រាប់ជនចំណាកស្រុកពីកម្ពុជា ដែលមានជាង ៩២ ភាគរយ។ ក្នុងនោះមាន ៧៣ ភាគរយ ត្រូវបានអង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តរប្រវេសន៍ អន្តរជាតិ (IOM) នៅអាស៊ីអាគ្នេយ៍ រកឃើញថាបានចំណាកស្រុកចូលទៅប្រទេសថៃ តាមរយៈមធ្យោបាយមិនទៀងទាត់។

អង្គការGVC រកឃើញថា នៅក្នុងប្រទេសថៃ ពលករចំណាកស្រុកកម្ពុជាងាយរងគ្រោះខ្លាំង។ អង្គការនេះទទួលស្គាល់ថា រដ្ឋាភិបាលប្រទេសទាំង២ គឺកម្ពុជា ថៃ បានខិតខំជួយការពារពលករខ្មែរ ប៉ុន្តែចំនួនពលករទាំងជាស្ត្រី ជាបុរស និងជាយុវជន ត្រូវបានរំលោភបំពាន និងកេងប្រវ័ញ្ច នៅតែមានចំនួនកើនឡើង។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់អង្គការសង់ត្រាល់ (Central) លោក ឌី ថេហូយ៉ា យល់ថា កត្តាដែលធ្វើឱ្យពលករខ្មែរ នៅប្រទេសថៃ នៅតែរងការរំលោភបំពាន និងកេងប្រវ័ញ្ច ដោយសារអាជ្ញាធរមិនបានអនុវត្តយន្តការដែលមានស្រាប់ ដែលច្បាប់បានចែង៖ «យន្តការទាំងអស់នោះអត់មានការឆ្លើយតប វាមិនដំណើរការនោះទេ អត់ឆ្លើយតបនឹង គឺមានហេតុផលទី១ រដ្ឋតែងតែលើកឡើងដដែលៗថា មិនមានថវិកាគ្រប់គ្រាន់ក្នុងការបង្កើតគណៈកម្មការនោះទេ»។ ទោះបែបណា តំណាងសង្គមស៊ីវិលឃ្លាំមើលសិទ្ធិពលកររូបនេះ លើកទឹកចិត្តឱ្យមានការជួបជជែកគ្នាញឹកញាប់ រវាងតំណាងរដ្ឋាភិបាលប្រទេសទាំងពីរ តំណាងអ្នកទទួលពលករ និងពលករផ្ទាល់ ដើម្បីបានដឹងពីសុខទុក្ខរបស់ពលករ ដែលរងការរំលោភបំពាន និងកេងប្រវ័ញ្ច៕

## ឃាត់ខ្លួនពលករប្រុសស្រីជាង១០០នាក់ លួចឆ្លងដែនតាមមេខ្យល់ទៅថៃ

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្ដិ៍ ចេញផ្សាយ ថ្ងៃទី 28 April, 2019

បន្ទាយមានជ័យ ៖ ជាការពិតណាស់នៅមុនរដូវចូលឆ្នាំ ក៏ដូចក្រោយចូលឆ្នាំ រាប់ទាំងរដូវបុណ្យភ្ជុំផងនោះ ពលករខ្មែរនៅតែមានការចាញ់បោកមេខ្យល់ ដើម្បីលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ ដែលប្រឈមនឹងគ្រោះថ្នាក់ ស្ទើររៀងរាល់ថ្ងៃ។

សមត្ថកិច្ចបានរាយការណ៍ថា ពលករខ្មែរប្រុស ស្រីរួមទាំងតូចៗត្រូវកម្លាំងនគរបាលការពារព្រំដែនគោក៨១៥ បានចេញល្បាតហើយប្រទះឃើញនៅចំណុចភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ដែលបំរ៉ុងឆ្លងដែនខុសច្បាប់សរុប ១១៤នាក់ ក្នុងនោះស្រី ៤៨នាក់ និងកុមារ ៩នាក់។ តាមរបាយការកម្លាំងនគរបាលបញ្ជាក់ថា ពលករដែលបំរ៉ុងឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ នោះគឺមកពីបណ្ដាខេត្តមួយចំនួន ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចជា ខេត្តពោធិ៍សាត់ ចំនួន១១នាក់/ ខេត្តកំពត០១នាក់/ ខេត្តបាត់ដំបង១៩នាក់/ ខេត្តព្រៃវែង២៤នាក់/ ខេត្តបន្ទាយមានជ័យ២៦នាក់/ ខេត្តកំពង់ធំ០១នាក់/ ខេត្តសៀមរាប១០នាក់/ ឧត្តមានជ័យ៣នាក់/ ស្វាយរៀង៣នាក់/ កំពង់ចាម៨នាក់ និងខេត្តត្បូងឃ្មុំ១នាក់។

លោកនាយប៉ុស្ដិ៍ស្ពាន ហេង ប៉ូរ៉ាម៉ូ ប្រាប់តាមទូរស័ព្ទថា ពលករប្រុស ស្រីទាំងអស់នោះ ក្រោយពីធ្វើការណែនាំរួចរាល់ បានអនុញ្ញាតឲ្យពួកគាត់វិលទៅស្រុកកំណើតរៀងៗខ្លួន ព្រោះពួកគាត់នៅខេត្តផ្សេងគ្នា។ លោកបន្តថា ករណីឆ្លងដែនខុសច្បាប់ គឺជាកត្តាប្រឈមទៅនឹងគ្រោះថ្នាក់គ្រប់បែបយ៉ាង ដោយបងប្អូនប្រជាពលរដ្ឋដែលមានបំណងចង់ចេញទៅធ្វើការនៅប្រទេសថៃ ត្រូវយល់ឲ្យច្បាស់ពីរបៀបរបប និងច្បាប់ទម្លាប់របស់កម្ពុជា និងថៃ ដើម្បីចៀសផុតពីទោសទណ្ឌនានា៕ video_2019-04-28_14-50-25

## អាជ្ញាធរថៃបញ្ជូនអ្នកទោស២នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៩ ម៉ោង ០៩:១០ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរចំនួន២នាក់ដែលជាប់ពន្ធនាគារនៅក្នុងប្រទេសថៃត្រូវបានក្រុមអាជ្ញាធរថៃធ្វើការដោះលែងឱ្យមានសេរីភាពវិញ និងនាំមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា កាលពីវេលាម៉ោង១០និង២៥នាទីព្រឹកថ្ងៃទី២៨ មេសា ឆ្នាំ២០១៩ នៅមាត់ច្រកទ្វារអន្តរជាតិជាំសាងាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

អ្នកទោសខ្មែរទាំង២នាក់ដែលក្រុមអាជ្ញាធរថៃធ្វើការដោះលែង ក្នុងនោះម្នាក់ឈ្មោះជា សម្បត្តិភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិស្រអែម ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៥ មេសា ឆ្នាំ២០១៩ ចូលតាមច្រកជាំ និងជាប់ចោទពីបទកាប់ឈើគ្រញូងខុសច្បាប់ និងម្នាក់ទៀតឈ្មោះ តូ ទុំ ភេទប្រុស អាយុ២៨ឆ្នាំ រស់នៅភូមិត្រពាំងលើ ឃុំត្រពាំងលើ ស្រុកស្វាយលើ ខេត្តសៀមរាប ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២៥ ឧសភា ២០១៧ ចូលតាមច្រកប៉ោយប៉ែត និងជាប់ចោទពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ ។ អ្នកទាំងពីរបានជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា ក្រោយពីបានទទួលអ្នកទោសខ្មែរ២នាក់ពីក្រុមអាជ្ញាធរថៃ សមត្ថកិច្ចកម្ពុជាបានធ្វើការអប់រំ និងធ្វើកិច្ចសន្យារួចឱ្យវិលត្រឡប់ទៅលំនៅឋានវិញជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល៕

# អាជ្ញាធរថៃចំបែកសំបុក ក្រុមមេខ្យល់ ដឹកពលករចំណាកស្រុក កម្ពុជាខិត ១០០នាក់ ចូលប្រទេស ថៃ

https://www.facebook.com/Pheaktra Pheak tra 27-04-2019

នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០១៩ កម្លាំង សមត្ថកិច្ច អន្តោប្រវេសន៍ ថៃ ដឹកនាំដោយលោក ឧត្តមសេនីយ៍ត្រី Som Pong អគ្គនាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងប្រទេសថៃ បានបញ្ជាអោយកម្លាំងសមត្ថកិច្ចពិសេស ធ្វើការស៊ើបអង្កេតបន្ទាន់បន្ទាប់ពីទទួលបានដំណឹងដឹកថា នឹងមានក្រុមមេខ្យល់រកស៊ីដឹកជញ្ជូនពលករចំណាកស្រុកខុសច្បាប់ ចូលប្រទេសថៃ។ តាមការបញ្ជាក់របស់សម្ថកិច្ច ក្រុមមេខ្យល់ទាំងនោះនឹងដឹកពលករចំណាកស្រុកមកទំលាក់នៅក្នុងផ្ទះមួយកន្លែង ស្ថិតក្នុងប្រកម៉េទ្រី សង្កាត់ណងចក ខ័ណ្ឌណងចក ទីក្រុងបាងកក ប្រទេសថៃ សម្ថកិច្ចបានដាក់កម្លាំងពង្រាយ ដើម្បីធ្វើការរង់ចាំ លុះដល់វេលាម៉ោង ១១:០០ សម្ថកិច្ចថៃឃើញរថយន្ត Pickup និងរថយន្តហុកឡ ពីគ្រឿងបានធ្វើដំណើរមកដល់ចំណុចខាងលើ ដោយមានឃ្លុំប៉ាតង់បិតជិត លក្ខណៈដូចរថយន្តដឹកជញ្ជូន សមត្ថកិច្ចបានសុំធ្វើការឆែកឆេរដើម្បីត្រួតពិនិត្យ ។ ក្នុងការឆែកឆេរ សម្ថកិច្ចថៃបានរកឃើញពលរដ្ឋខ្មែរចំណាកស្រុកខុសច្បាប់រួមមាន ប្រុសស្រី ក្មេង ចាស់ សរុប ចំនួន ៩០នាក់ ក្នុងនោះសមត្ថកិច្ចស្រាវជ្រាវដឹងថា ជនសង្ស័យឈ្មោះ កាន់ តាផុន អាយុ៤៥ឆ្នាំ រួមនិងបក្សពួក ០៣នាក់ ទៀត ដែលជាអ្នកបើកបររថយន្តខាងលើ ដោយបានបិតបាំងបំភាន់ភ្នែកសម្ថកិច្ចធ្វើអោយសម្ថកិច្ចត្រួតនិត្យរកឃើញ ក្នុងនោះដែរសម្ថកិច្ចបានឆែករកឃើញអាវុធខ្លី ០១ដើមនៅក្នុងរថយន្តផងដែរ។

១.ឈ្មោះ កាន់ តាផុន អេកអារីយ៉ៈវរវ៉ាត់ អាយុ ៤៥ ឆ្នាំ (១)ចោទប្រកាន់ពីបទនាំយកអាវុធជាតិផ្ទុះទៅកន្លែង សាធារណៈ ,ភូមិ ,បុរី និងផ្លូវសាធាណៈដោយមិនសមហេតុផល (២)ជួយលាក់បាំងជនអន្តោប្រវេសន៍ខុសច្បាប់ អោយគេចផុតពីការឃាត់ខ្លួន។

២.ឈ្មោះ ស៊ុនថន សុម៉េត នុនថាឆៃ អាយុ ៤៣ឆ្នាំ ចោទប្រកាន់ពីបទជួយឱ្យជនអន្តោប្រវេសន៍ ខុសច្បាប់ចូលប្រទេសថៃ និងលាក់បាំងពីការឃាត់ខ្លួន និងបំពាន់ច្បាប់ក្នុងប្រទេស។

៣.ឈ្មោះ អឿកាយ សុវត្តិ ឆាក់រើន អាយុ ២៧ឆ្នាំ ចោទប្រកាន់ពីបទជួយឱ្យជនអន្តោប្រវេសន៍ខុសច្បាប់ចូលប្រទេសថៃ និងលាក់បាំងពីការឃាត់ខ្លួន និងបំពាន់ច្បាប់ក្នុប្រទេស។

៤.ឈ្មោះ វីរ៉ាត ជុងផាន់ អាយុ ៤៤ឆ្នាំ ចោទប្រកាន់ពីបទជួយឱ្យជនអន្តោប្រវេសន៍ខុសច្បាប់ ចូលប្រទេសថៃ និងលាក់បាំងពីការឃាត់ខ្លួន និងបំពាន់ច្បាប់ក្នុងប្រទេស។

៥.ឈ្មោះ អួន អី អាយុ ២៤ឆ្នាំ សញ្ជាតិខ្មែរ រួមបក្សពួកចំនួន៧២នាក់ (និងអ្នកក្នុងបន្ទុកចំនួន១៦នាក់ ) សង្ស័យដែលមានអាយុខ្ពស់បំផុត៤៧ឆ្នាំ និងជនសង្ស័យមានអាយុទៀបបំផុតអាយុ ០១ខែ ។

**វត្ថុតាំងរួមមាន ៖**

១.អាវុធ ខ្លី ម៉ាក SmithandWesson ប័ណ្ណ កាន់ កាប់ អាវុធ លេខ 3928823

២.គ្រាប់ កាំភ្លើង ខ្លី ចំនួន ៧២គ្រាប់

៣.រថយន្ត ហុកឡ ម៉ាក យ៉ឺណូ ពាក់ ស្លាក លេខ 70 – 2481 បុរី រ៉ាម

៤.រថយន្ត Pickup ម៉ាក តូយ៉ូតា វីហ្គូ ពាក់ស្លាកលេខ 8915 ស្រះកែវ

ចំពោះទេសន្តប្រវេសន៍ទាំងអស់បានប្រគល់ជូនអាជ្ញាធរពាក់ព័ន្ធធ្វើការកំណត់អត្តសញ្ញាណ អោយបានច្បាស់ រួចបន្តទៅតាមនីតិវិធីច្បាប់របស់ប្រទេសថៃ ។ ពលករខ្មែរ

## ដំណើរទស្សនកិច្ចសិក្សាអន្តរជាតិ និងជំនួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍រវាងប្រតិភូថៃ ជាមួយគណៈ កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ)

https://www.facebook.com/Cambodia-Migrant-Labour-Group-CMLG- April 27 at 5:23 PM

នៅថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៩ ក្រោមកិច្ចសម្របសសម្រួលរបស់អង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល (GVC) សហការជាមួយអង្គការដៃគូពាក់ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ បានរៀបចំសន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី លើការងារទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស លើកទី២ រវាងព្រះរាជាណាកម្ពុជា និងព្រះរាជាណាចក្រថៃ នៅសណ្ឋាគារអង្គរមីរ៉ាខល ក្រោមអធិបតីភាព ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនិងការជួញដូរមនុស្ស ( គ.ជ.ប.ជ) និងមានការអញ្ជើញចូលរួម ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ថ្នាក់ដឹកនាំនិង មន្ទីរពាក់ព័ន្ធ មកពីខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកោះកុង និងខេត្តកំពង់ចាម ព្រមទាំងមានការចូលរួមពី អនុប្រធានទី១ សហគមអឺរ៉ុប ប្រចាំកម្ពុជា តំណាងរដ្ឋបាលក្រសួងសន្តិសុខនៃនាយករដ្ឋមន្ត្រីថៃ តំណាងក្រសួងការងារថៃ និងអង្គការជាតិ-អន្តរជាតិផងដែរ។ សន្និសីទអន្តរជាតិទ្វេភាគី នេះធ្វើឡើងដើម្បីបង្កើនកិច្ចសន្ទនា ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនៃប្រទេសកម្ពុជានិងប្រទេសថៃ និងផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនិងការអនុវត្តគោលនយោបាយទាក់ទងនឹងការលើកម្ពស់ការធ្វើចំណាកស្រុកដោយស្របច្បាប់ ។ សូមបញ្ជាក់ផងដែលថា កិច្ចប្រជុំទ្វេភាគីនេះ ធ្លាប់បានធ្វើការរៀបចំលើកទី១ កាលពីខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ រួមម្តងមកហើយ ក្នុងនោះកិច្ចប្រជុំពិភាក្សាក៏បានករឃើញនូវបញ្ហារួម រវាងប្រទេសទាំងពីរ អំពីបញ្ហាទេសន្តរប្រវេសន៍ការងាររបស់ពលករខ្មែរ ដែលបានចំណាកស្រុកទៅធ្វើការក្នុងប្រទេសថៃកន្លងមក។

ដោយឡែកនៅព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ រដ្ឋបាលសាលាខេត្តសៀមរាប បានទទួលជួបពិភាក្សាជាមួយប្រតិភូនៃព្រះរាជាណាចក្រថៃ និងអង្គការពាក់ព័ន្ធ ដែលដឹកនាំដោយ លោកស្រី Manoothum Naovanan អ្នកសម្របសម្រួលរបស់អង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល ហើយលោកស្រីក៏បានលើកឡើងពីគោលបំណងនៃដំណើរទស្សនកិច្ចសិក្សាអន្តរជាតិ ដើម្បីធ្វើ កិច្ចពិភាក្សាគ្នា ព្រមទាំងធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍ពីគ្នាទៅវិញទៅមក រកឲ្យឃើញនូវគន្លឹះល្អៗ ដែលជាយន្តការមួយដ៏សំខាន់ សម្រាប់យកទៅអនុវត្តបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់ទៀតផង ។ កិច្ចប្រជុំនេះក៏ជាការផ្លាស់ប្តូរនូវព័ត៌មានថ្មីៗពីគ្នា ក៏ដូចជាការពង្រឹងស្ថាប័ននៃប្រទេសបញ្ជូន និងប្រទេសទទួលពលករផងដែរ។

ថ្លែងក្នុងកិច្ចជំនួបនេះផងដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានបញ្ជាក់គោលបំណង និងបង្ហាញអំពីឆន្ទៈមុះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងបំផុសការយល់ដឹង ការប្រុងស្មារតី និងធ្វើសកម្មភាពប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សគ្រប់រូបភាព ។ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និង កុមារ តាមគ្រប់រូបភាព នៅទូទាំងខេត្ត ដោយផ្អែកតាមតួនាទីភារកិច្ច លទ្ធភាព សមត្ថភាព ការសហការ និងរួមចំណែកដោយឆន្ទៈនិងមនសិការ ព្រមទាំងធ្វើការពង្រីកការយល់ដឹង និងទទួលបានព័ត៌មានពាក់ព័ន្ធ និង វិសាលភាពនៃបទល្មើសជួញដូរមនុស្សដល់ប្រជាពលរដ្ឋ អំពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូរពាក់ព័ន្ធ ។ លោកស្រីក៏បានបង្ហាញជូនប្រតិភូអំពីការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដែលរួមមានទាំងរចនាសម្ព័ន្ធ យន្តការគាំទ្រ តួនាទីភារកិច្ច ផែនការយុទ្ធសាស្ត្រ លទ្ធផលការងារកន្លងមក បញ្ហាប្រឈម និងទិសដៅសម្រាប់អនុវត្តបន្តទៀតផងដែរ។

បន្ទាប់ពីកិច្ចជំនួបពិភាក្សាត្រូវបានបញ្ចប់នៅថ្នាក់ខេត្ត ប្រតិភូ ក៏បានបន្តដំណើរ ចុះទស្សនកិច្ចនៅសហគមន៍ក្នុងភូមិតារៀម ឃុំជីក្រែង ស្រុកជីក្រែង ដែលមានអតីតពលមួយចំនួន ធ្លាប់បានចំណាកស្រុកទៅប្រទេសថៃហើយរង

គ្រោះ និងមានបងប្អូនពលករជាច្រើនទៀតកំពុងស្នាក់នៅនិងធ្វើការក្នុងប្រទេសថៃទាំងមានឯកសារស្របច្បាប់ និងមិនមានឯកសារស្រប។ នៅក្នុងដំណើរទស្សនកិច្ចនេះផងដែរ ក៏មានការស្វាគមន៍ពីលោកអភិបាលនៃគណៈអភិបាលស្រុកជីក្រែង អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។ក្នុងឱកាសនោះ លោកជំទាវ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិ គ.ខ.ប.ជ បានជម្រាបជូនអំពីការយកចិត្តទុករបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះបងប្អូនប្រជាពលរដ្ឋ ពិសេសសិទ្ធិរបស់បងប្អូនពលករដែលត្រូវទទួលបានការគោរពសិទ្ធិ និងបានលើកទឹកចិត្តដល់ប្រជាពលរដ្ឋទាំងអស់ថា ធ្វើការក្នុងស្រុកក៏ល្អប្រសើរ តែបើចង់ចំណាកស្រុកត្រូវទៅដោយមានឯកសារស្របច្បាប់ត្រឹមត្រូវ។ ឆ្លើយតបទៅនឹងសំណួរមួយចំនួនរបស់បងប្អូនប្រជាពលរដ្ឋកម្ពុជា តំណាងក្រសួងការងារនៃព្រះរាជាណាចក្រថៃក៏បានជម្រាបជូនអំពីប្រភេទការងារដែលផ្តល់ជូនពលករបរទេស មានចំនួនពីរប្រភេទ គឺការងារសំណង់ និងការងារបម្រើតាមផ្ទះ។ ចំពោះបញ្ហាដែលបងប្អូនបានលើកឡើងអំពីថៅកែថៃដកហូត ឬរំលោភបំពានទៅលើសិទ្ធរបស់ពលករ សូមទៅដាក់ពាក្យដំណើរទស្សនកិច្ចសិក្សាអន្តរជាតិ និងជំនួបពិភាក្សាផ្លាស់ប្តូរបទពិសោធន៍រវាងប្រតិភូថៃ ជាមួយគណៈ កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ)។

នៅថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៩ ក្រោមកិច្ចសម្របសម្រួលរបស់អង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល (GVC) សហការជាមួយអង្គការដៃគូពាក់ព័ន្ធក្នុងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ បានរៀបចំសន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី លើការងារទេសន្តប្រវេសន៍ការងារ និងអំពើជួញដូរមនុស្សលើកទី២ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅសណ្ឋាគារអង្គរមីរ៉ាខល ក្រោមអធិបតីភាព ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនិងការជួញដូរមនុស្ស ( គ.ជ.ប.ជ) និងមានការអញ្ជើញចូលរួម ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ថ្នាក់ដឹកនាំនិង មន្ទីរពាក់ព័ន្ធ មកពីខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកោះកុង និងខេត្តកំពង់ចាម ព្រមទាំងមានការចូលរួមពី អនុប្រធានទី១ សហគមអឺរ៉ុប ប្រចាំកម្ពុជា តំណាងរដ្ឋបាលក្រសួងសន្តិសុខនៃនាយករដ្ឋមន្ត្រីថៃ តំណាងក្រសួងការងារថៃ និងអង្គការជាតិ-អន្តរជាតិផងដែរ។ សន្និសីទអន្តរជាតិទ្វេភាគី នេះធ្វើឡើងដើម្បីបង្កើនកិច្ចសន្ទនា ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នពាក់ព័ន្ធនៃប្រទេសកម្ពុជានិងប្រទេសថៃ និងផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនិងការអនុវត្តគោលនយោបាយទាក់ទងនឹងការលើកម្ពស់ការធ្វើចំណាកស្រុកដោយស្របច្បាប់ ។ សូមបញ្ជាក់ផងដែលថា កិច្ចប្រជុំទ្វេភាគីនេះ ធ្លាប់បានធ្វើការរៀបចំលើកទី១ កាលពីខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ រួមម្តងមកហើយ ក្នុងនោះកិច្ចប្រជុំពិភាក្សាក៏បានករឃើញនូវបញ្ហារួម រវាងប្រទេសទាំងពីរ អំពីបញ្ហាទេសន្តប្រវេសន៍ការងាររបស់ពលករខ្មែរ ដែលបានចំណាកស្រុកទៅធ្វើការក្នុងប្រទេសថៃកន្លងមក។

ដោយឡែកនៅព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ រដ្ឋបាលសាលាខេត្តសៀមរាប បានទទួលជួបពិភាក្សាជាមួយប្រតិភូនៃព្រះរាជាណាចក្រថៃ និងអង្គការពាក់ព័ន្ធ ដែលដឹកនាំដោយ លោកស្រី Manoothum Naovanan អ្នកសម្របសម្រួលរបស់អង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល ហើយលោកស្រីក៏បានលើកឡើងពីគោលបំណងនៃដំណើរទស្សនកិច្ចសិក្សាអន្តរជាតិ ដើម្បីធ្វើ កិច្ចពិភាក្សាគ្នា ព្រមទាំងធ្វើការផ្លាស់ប្តូរនូវបទពិសោធន៍ពីគ្នាទៅវិញទៅមក រកឲ្យឃើញនូវគន្លឹះល្អៗ ដែលជាយន្តការមួយដ៏សំខាន់ សម្រាប់យកទៅអនុវត្តបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់ទៀតផង ។ កិច្ចប្រជុំនេះក៏ជាការផ្លាស់ប្តូរនូវព័ត៌មានថ្មីៗពីគ្នា ក៏ដូចជាការពង្រឹងស្ថាប័ននៃប្រទេសបញ្ជូន និងប្រទេសទទួលពលករផងដែរ។

ថ្លែងក្នុងកិច្ចជំនួបនេះផងដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បានបញ្ជាក់គោលបំណង និងបង្ហាញអំពីឆន្ទៈមុះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងបំផុសការយល់ដឹង ការប្រុងស្មារតី និងធ្វើសកម្មភាពប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សគ្រប់រូបភាព ។ ដើម្បីទប់ស្កាត់ការ

ជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និង កុមារ តាមគ្រប់រូបភាព នៅទូទាំងខេត្ត ដោយផ្អែកតាមតួនាទីភារកិច្ច លទ្ធភាព សមត្ថភាព ការសហការ និងរួមចំណែកដោយឆន្ទៈនិងមនសិការ ព្រមទាំងធ្វើការពង្រីកការយល់ដឹង និងទទួលបានព័ត៌មានពាក់ព័ន្ធ និង វិសាលភាពនៃបទល្មើសជួញដូរមនុស្សដល់ប្រជាពលរដ្ឋ អំពីកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូរពាក់ព័ន្ធ ។ លោកស្រីក៏បានបង្ហាញជូនប្រតិភូអំពីការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដែលរួមមានទាំងរចនាសម្ព័ន្ធ យន្តការគាំទ្រ តួនាទីភារកិច្ច ផែនការយុទ្ធសាស្ត្រ លទ្ធផលការងារកន្លងមក បញ្ហាប្រឈម និងទិសដៅសម្រាប់អនុវត្តបន្តទៀតផងដែរ។

បន្ទាប់ពីកិច្ចជំនួបពិភាក្សាត្រូវបានបញ្ចប់នៅថ្នាក់ខេត្ត ប្រតិភូ ក៏បានបន្តដំណើរ ចុះទស្សនកិច្ចនៅសហគមន៍ក្នុងភូមិតារៀម ឃុំជីក្រែង ស្រុកជីក្រែង ដែលមានអតីតពលមួយចំនួន ធ្លាប់បានចំណាកស្រុកទៅប្រទេសថៃហើយរងគ្រោះ និងមានបងប្អូនពលករជាច្រើនទៀតកំពុងស្នាក់នៅនិងធ្វើការក្នុងប្រទេសថៃទាំងមានឯកសារស្របច្បាប់ និងមិនមានឯកសារស្រប។ នៅក្នុងដំណើរទស្សនកិច្ចនេះផងដែរ ក៏មានការស្វាគមន៍ពីលោកអភិបាលនៃគណៈអភិបាលស្រុកជីក្រែង អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋយ៉ាងច្រើនកោះករ។ក្នុងឱកាសនោះ លោកជំទាវ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិ គ.ខ.ប.ជ បានជម្រាបជូនអំពីការយកចិត្តទុករបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះបងប្អូនប្រជាពលរដ្ឋ ពិសេសសិទ្ធិរបស់បងប្អូនពលករដែលត្រូវទទួលបានការគោរពសិទ្ធិ និងបានលើកទឹកចិត្តដល់ប្រជាពលរដ្ឋទាំងអស់ថា ធ្វើការក្នុងស្រុកក៏ល្អប្រសើរ តែបើចង់ចំណាកស្រុកត្រូវទៅដោយមានឯកសារស្របច្បាប់ត្រឹមត្រូវ។

ឆ្លើយតបទៅនឹងសំណួរមួយចំនួនរបស់បងប្អូនប្រជាពលរដ្ឋកម្ពុជា តំណាងក្រសួងការងារនៃព្រះរាជាណាចក្រថៃក៏បានជម្រាបជូនអំពីប្រភេទការងារដែលផ្តល់ជូនពលករបរទេស មានចំនួនពីរប្រភេទ គឺការងារសំណង់ និងការងារបម្រើតាមផ្ទះ។ ចំពោះបញ្ហាដែលបងប្អូនបានលើកឡើងអំពីថៅកែថៃជកហូត ឬរំលោភបំពានទៅលើសិទ្ធរបស់ពលករ សូមទៅដាក់ពាក្យបណ្តឹងនៅមន្ទីរការងារ និងកិច្ចការពារសិទ្ធពលករក្នុងប្រទេសថៃ។ បន្ថែមពីនោះលោកក៏បានជម្រាបជូនអំពីច្បាប់ ទំលាប់នៃការរស់នៅរបស់ពលករក្នុងប្រទេសថៃ និងសេវាដែលរដ្ឋបានកំណត់និងផ្តល់ជូនពលករបរទេស។បណ្តឹងនៅមន្ទីរការងារ និងកិច្ចការពារសិទ្ធពលករក្នុងប្រទេសថៃ។ បន្ថែមពីនោះលោកក៏បានជម្រាបជូនអំពីច្បាប់ទំលាប់នៃការរស់នៅរបស់ពលករក្នុងប្រទេសថៃនិងសេវាដែលរដ្ឋបានកំណត់និងផ្តល់ជូនពលករបរទេស។

## ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩

## គោលនយោបាយការបរទេសត្រឹមត្រូវទើបពលរដ្ឋខ្មែររាប់ម៉ឺននាក់មានឱកាសទៅធ្វើការក្រៅប្រទេស

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៩ ម៉ោង ១៥:១៦ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ គ្មានគោលនយោបាយការបរទេសត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជានោះទេ ប្រជាពលរដ្ឋខ្មែររាប់ម៉ឺននាក់ច្បាស់ជាគ្មានឱកាសបានទៅធ្វើការនៅប្រទេសកូរ៉េឡើយ ។ ផ្ទុយទៅមានគោលនយោបាយបរទេសត្រឹមត្រូវទើបមានពលកររាប់ម៉ឺននាក់ មានឱកាសទៅធ្វើការនៅកូរ៉េ និងបណ្តាប្រទេសផ្សេងៗទៀត ។ នេះបើតាមការអះអាងរបស់អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ។

លោកសុខ ឥសាន បានលើកឡើងតាមប្រព័ន្ធតេឡេក្រាមនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ថា ពីមុនមករាប់សិបឆ្នាំចាប់ពីប្រទេសកូរ៉េបានឯករាជ្យ និងចាប់ពីប្រទេសកម្ពុជាបានឯករាជ្យនាឆ្នាំ១៩៥៣ មកទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរមិនទាន់មាននៅឡើយ ទោះបីប្រទេសកូរ៉េខាងត្បូងជាសមាជិកអង្គការសហប្រជាជាតិដូចប្រទេសកូរ៉េ ខាងជើងដែរក៏ដោយ ។ លោកបន្តថា តែមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ ដោយសារស្នាដៃសម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាទើបប្រទេសទាំងពីរ គឺព្រះរាជាណាចក្រកម្ពុជា និងសាធារណ រដ្ឋកូរ៉េ បានភ្ជាប់ទំនាក់ទំនងការ

ទូតជាមួយគ្នារហូតមកដល់បច្ចុប្បន្ននេះ ។ លោកឲ្យដឹងទៀតថា ដោយសារមានទំនាក់ទំនងការទូតនេះហើយ ទើបកម្ពុជាអាចមានលទ្ធភាពបញ្ជូនពលករខ្មែររាប់ម៉ឺននាក់ទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងនេះ ដែលបានប្រាក់ឈ្នួលខ្ពស់អាចមានលទ្ធភាពផ្ញើមកជួយទ្រទ្រង់ជីវភាពក្រុមគ្រួសារនៅក្នុងប្រទេសបានល្អប្រសើរដូចសព្វថ្ងៃ ។ អ្នកនាំពាក្យសង្កត់ធ្ងន់ថា ពលករខ្មែរដែលបានទៅធ្វើការនៅប្រទេសកូរ៉េកុំភ្លេចគុណសម្បត្តិដ៏ធំធេងរបស់រាជរដ្ឋាភិបាលកម្ពុជារបស់គណបក្សប្រជាជនកម្ពុជាឲ្យសោះ ។ លោកបញ្ជាក់ថា ការទៅប្រឡងធ្វើតេស្ត និងបំពេញបែបបទផ្សេងៗ ដើម្បីទៅប្រទេសកូរ៉េ គ្រាន់តែជានីតិវិធីតែប៉ុណ្ណោះ ។ លោថា «ដូច្នេះ បើគ្មានគោលនយោបាយការបរទេសត្រឹមត្រូវរបស់រាជរដ្ឋាភិបាល កម្ពុជារបស់គណបក្សប្រជាជនកម្ពុជាទេ ពលករខ្មែររាប់ម៉ឺននាក់ច្បាស់ជាគ្មានឱកាសមានមុខបានទៅធ្វើការនៅប្រទេសកូរ៉េជាដាច់ខាត» ។

បើតាមឯកសារមួយរបស់រដ្ឋាភិបាលបានបង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋចំនួន២០៨.៤០០នាក់ បានទទួលការងារថ្មីធ្វើនៅឆ្នាំ២០១៨ ហើយក៏មានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺននាក់ បានទៅធ្វើការងារនៅបរទេស ។ ឯកសារក៏បានឲ្យដឹងថា ក្នុងចំណោមមនុស្សទាំង២០៨.៤០០នាក់ ដែលបានទទួលការងារថ្មីធ្វើនោះ គឺមានស្ត្រីចំនួន១១៧.៧០០នាក់ ។ ក្នុងចំណោមនោះចំនួន១៤០.០០០នាក់ បានធ្វើការងារនៅក្នុងប្រទេស ហើយចំនួនជិត៧ម៉ឺននាក់បានទៅធ្វើការងារនៅក្រៅប្រទេស ។ ក្នុងចំណោមទាំងអស់នោះដែរ គឺមានពលរដ្ឋកម្ពុជាចំនួនជិត៧ម៉ឺន បានទៅធ្វើការងារនៅក្រៅប្រទេស ជាពិសេសប្រទេសថៃចំនួន៦ម៉ឺននាក់ ប្រទេសកូរ៉េខាងត្បូងចំនួនជិត៥.០០០នាក់ និងជប៉ុនជាង៣ពាន់នាក់ ៕

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស បានចុះត្រួតពិនិត្យគោលដៅចំនួន ២៧ និងមាន ៦ក្រុម ក្នុងរាជធានីភ្នំពេញ

https://www.facebook.com/ General Department of Immigration - GDI 29-04-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនយោគឯកជន នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យគោលដៅចំនួន ២៧ និងមាន ៦ក្រុម ក្នុងរាជធានីភ្នំពេញ។ ក្នុងការត្រួតពិនិត្យគោលដៅទាំង ២៧ មាន១- សាលា WESTERN INTERNATIONAL សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក), ២- ក្រុមហ៊ុន អេ ស៊ា សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌទួលគោក), ៣- ក្រុមហ៊ុន ចុង តាវ សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌទួលគោក), ៤- ភោជនីយដ្ឋាន ស៊ីងយ៉ាង តុង សកម្មភាពអាជីវកម្ម ភោជនីយដ្ឋាន (ខណ្ឌទួលគោក), ៥- គ្លីនិកសើរស្បែកឌៃម៉ាដេដ សកម្មភាពអាជីវកម្ម កែសម្ផស្ស (ខណ្ឌទួលគោក), ៦- រោងចក្រ IN KYUNG សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ៧- សិប្បកម្ម ឈានឈុន ហ្វូងជា សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ៨- ក្រុមហ៊ុន CAMBODIA AIRWAY សកម្មភាពអាជីវកម្ម សេវាដឹកជញ្ជូន (ខណ្ឌពោធិ៍សែនជ័យ២), ៩- ហាងEVEN STAR សកម្មភាពអាជីវកម្ម លក់កាហ្វេ (ខណ្ឌចំការមន), ១០- សាលាអន្តរជាតិ ICAN សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌចំការមន), ១១- ក្រុមហ៊ុន មេហ្គាឡាយ សកម្មភាពអាជីវកម្ម ចែកចាយទំនិញ (ខណ្ឌចំការមន), ១២- ក្រុមហ៊ុន ហ៊្វុក ហ៊ុងវេសស៊ិន សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌសែនសុខ), ១៣- ក្រុមហ៊ុន ប៊ូយ៉ុង សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌសែនសុខ), ១៤- សាលាអន្តរជាតិអាស៊ាន សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌច្បារអំពៅ), ១៥- សាលា WESTLINE សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌច្បារអំពៅ), ១៦- សាលាប៊ែលធី អន្តរជាតិ សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌច្បារអំពៅ), ១៧- ធនាគារ SACOM សកម្មភាពអាជីវកម្មធនាគារ (ខណ្ឌច្បារអំពៅ), ១៨- ធនាគារ DIBC សកម្មភាពអាជីវកម្ម ធនាគារ (ខណ្ឌច្បារអំពៅ), ១៩- រោងចក្រ វីន ស ង្វេសិន សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឬស្សីកែវ), ២០- សិប្បកម្ម គួចហៃថេង សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឬស្សីកែវ), ២១- រោងចក្រ សាន យ៉ន សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឬស្សី

កែវ), ២២- សិប្បកម្ម ហ័រស៊ីង សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌពោធិ៍សែនជ័យ២), ២៣- សិប្បកម្ម K.J.P.T BEST សកម្មភាពអាជីវកម្ម សេវាពុម្ព (ខណ្ឌពោធិ៍សែនជ័យ២), ២៤- ក្រុមហ៊ុន EVERGREEN GARMENT សកម្មភាពអាជីវកម្ម កាត់ដេរ (ខណ្ឌឬស្សីកែវ), ២៥- ហាង HUANG HUANG HUPT សកម្មភាពអាជីវកម្ម ប្តូរប្រាក់ (ខណ្ឌចំការមន), ២៦- ក្រុមហ៊ុន SINO GREATWAL សកម្មភាពអាជីវកម្ម សំណង់ (ខណ្ឌចំការមន) និង២៧- សាលារើលដ៍ អន្តរជាតិ សកម្មភាពអាជីវកម្ម អប់រំ (ខណ្ឌទួលគោក)។

ការត្រួតពិនិត្យនេះ ទទួលបានលទ្ធផលមានប្រើប្រាស់ពលករខ្មែរ សរុបចំនួន ៤២៩៩នាក់ ស្រី ២៩៩៣នាក់ និងប្រើប្រាស់ពលករបរទេសសរុបចំនួន ៤៤១នាក់ ស្រី ៨៩នាក់ បានប្រើប្រាស់ទិដ្ឋាការ E ចំនួន ៤៤១ មាន ២៦ សញ្ជាតិ រួមមាន ចិន ៣០១នាក់ ស្រី ៣៧នាក់, ហ្វីលីពីន ៣៦នាក់ ស្រី ១៨នាក់, សឹង្ហបុរី ០១នាក់, នីហ្សេរីយ៉ា ០៩នាក់ ស្រី ០៣នាក់, កាមីរ៉ូត ០១នាក់, យូកានដា ០៣នាក់ ស្រី ០១នាក់, ប៉ាគីស្ថាន ០១នាក់, កេនយ៉ា ០១នាក់, ហ្គាណា ០២នាក់, អាហ្វ្រិកខាងត្បូង ០៣នាក់, សាវ៉ង់០១នាក់, កូរ៉េ ០៩នាក់, បង់ក្លាដេស ០១នាក់, វៀតណាម ២៤នាក់ ស្រី ០៨នាក់, តៃវ៉ាន់ ០៨នាក់ ស្រី ០១នាក់, ហូឡង់ ០១នាក់, មីយ៉ាន់ម៉ា ០១នាក់, អង់គ្លេស ១៦នាក់ ស្រី ១៣នាក់, ឥណ្ឌា ០៦នាក់ ស្រី ០២នាក់, អាមេរិក ០៣នាក់, ម៉ាឡេស៊ី ០៦នាក់ ស្រី ០១នាក់, ញូហ្សីឡែន ០២នាក់ ស្រី ០១នាក់, អាយឡែន ០២នាក់ ស្រី ០១នាក់, ស្រីលង្កា ០១នាក់ ស្រី ០១នាក់, អូស្ត្រាលី ០១នាក់, អ៊ូហ្គាន់ដា ០១នាក់ ស្រី ០១នាក់ មានសៀវភៅការងារ និងប័ណ្ណការងារចំនួន ៤៤១នាក់៕

## កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស បានចុះត្រួតពិនិត្យការដ្ឋានសំណង់ ០១កន្លែង នៅខេត្តព្រះសីហនុ

https://www.facebook.com/ General Department of Immigration - GDI 29-04-2019

កម្លាំងក្រុមចម្រុះអធិការកិច្ចហត្ថពលករបរទេស នៃនាយកដ្ឋានជនបរទេស ជាអ្នកវិនិយោគឯកជន នាថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៩ បានចុះត្រួតពិនិត្យការដ្ឋានសំណង់ចំនួន ០១កន្លែង ស្ថិតនៅសង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ការដ្ឋានសំណង់នេះ មានឈ្មោះការដ្ឋានសំណង់ការតុបតែងភោជនីយដ្ឋាន ប្រើប្រាស់ពលករសរុបចំនួនៈ ៦១នាក់ ស្រី ០៨នាក់ (ពលករខ្មែរ ២៥នាក់ ស្រី ០៨នាក់ និងពលករបរទេសសរុបចំនួន ៣៦នាក់ ស្រី ០០នាក់) បានពិនិត្យលិខិតឆ្លងដែនច្បាប់ដើម សរុបចំនួន ២៨នាក់ និងមិនបានពិនិត្យលិខិឆ្លងដែនច្បាប់ដើម សរុបចំនួន ០៨នាក់ (មូលហេតុយកទៅពន្យាទិដ្ឋាការស្នាក់នៅ) រួមមាន ០១សញ្ជាតិ ចិន ៣៦នាក់ ស្រី ០០នាក់៕

## ប្រជាជនកម្ពុជាធ្វើការនៅក្រៅប្រទេស ផ្ញើប្រាក់មកផ្ទះវិញ $១,៤០០ លាន ក្នុងឆ្នាំ ២០១៨

https://www.postkhmer.com/ ហ៊ី គីមសាយ | Publication date 30 April 2019 | 10:41 ICT

**ភ្នំពេញៈ** ប្រជាជនកម្ពុជាទៅធ្វើការនៅក្រៅប្រទេសបានបន្តផ្ញើប្រាក់ត្រឡប់មកផ្ទះវិញកាន់តែច្រើនជាងមុន ដោយទឹកប្រាក់សរុបមានរហូតដល់ ១,៤០០ លានដុល្លារ ក្នុងឆ្នាំ ២០១៨ ដែលភាគច្រើនជាទឹកប្រាក់ផ្ញើត្រឡប់ពីប្រទេស ថៃ និង កូរ៉េខាងត្បូង។ នេះបើយោងតាមទិន្នន័យរបស់ធនាគារជាតិនៃកម្ពុជា (NBC)។ ចំនួនទឹកប្រាក់កាលពីឆ្នាំ ២០១៨ មានការកើនឡើង ១១ ភាគរយធៀបនឹងទឹកប្រាក់កាលពីឆ្នាំ ២០១៧។ យោងតាមរបាយការណ៍ស្ថិតិជញ្ជីងទូទាត់របស់ NBC ដែលបានកត់ត្រាការផ្ទេរប្រាក់របស់ប្រជាជនធ្វើការនៅក្រៅប្រទេស មកតាមគ្រឹះស្ថានហិរញ្ញវត្ថុ បានបង្ហាញថា ក្នុងចំណោមទឹកប្រាក់ផ្ញើមកសរុប ទឹកប្រាក់ដែលពលរដ្ឋកម្ពុជាផ្ញើមកពីថៃ មានចំណែករហូតដល់ ៦៨ ភាគរយ ស្របពេលពី កូរ៉េមានចំនួន ២១,៥ ភាគរយ។ ទឹកប្រាក់ដែលពលករកម្ពុជាផ្ញើមកផ្ទះវិញពីប្រទេស ជប៉ុន មានចំណែក ៣,៣ ភាគរយនៃបរិមាណសរុប ខណៈ ពីម៉ាឡេស៊ីមានចំណែក ២,៥ ភាគរយ។

លោក ង៉ែត ជូ អ្នកស្រាវជ្រាវ និងអ្នកប្រឹក្សាយោបល់ផ្នែកអាជីវកម្មឯករាជ្យបានឲ្យដឹងកាលពីម្សិលមិញថា កំណើនទឹកប្រាក់ផ្ញើមកផ្ទះ ឆ្លុះបញ្ចាំងពីកំណើនលំហូរចេញនៃប្រជាជនកម្ពុជា ដើម្បីស្វែងរកការងារធ្វើនៅបរទេស ជាពិសេសប្រទេស ថៃ និងកូរ៉េ។ លោក ជូ ថ្លែងថា៖ «នៅក្នុងរយៈពេលខ្លី កំណើនទឹកប្រាក់ផ្ញើមកផ្ទះពីការធ្វើការក្រៅប្រទេសនេះជួយប្រជាជនកម្ពុជាក្នុងការសម្រួលជីវភាពគ្រួសាររបស់ពួកគេ ដោយសារថា ការពឹងផ្អែកលើកសិកម្មតែមួយមុខ ដូចមានភាពលំបាកជាងមុនណាស់សម្រាប់ពួកគេ»។ ប៉ុន្តែលោកបន្ថែមថា លំហូរចេញក្នុងចំនួនច្រើននៃកម្មករចំណាកស្រុក មិនមែនជាការល្អសម្រាប់សេដ្ឋកិច្ចនៅក្នុងរយៈពេលវែងនោះទេ ដោយសារកម្ពុជាមិនអាចទទួលបានអត្ថប្រយោជន៍អតិបរមាពីសក្តានុពលរបស់ខ្លួនក្នុងនាមជាប្រទេសមួយមានកម្លាំងពលកម្មច្រើន។ លោកថ្លែងថា៖ «ពលរដ្ឋកម្ពុជាយើងកំពុងជួយដោយផ្ទាល់ដល់ប្រទេសផ្សេងទៀត ដើម្បីជំរុញកំណើនសេដ្ឋកិច្ចរបស់ពួកគេ ដោយសារតែយើងកំពុងធ្វើការងារដែលប្រជាជនគេមិនចង់ធ្វើ ឬក៏អាចឲ្យគេយកពេលទៅធ្វើការងារផ្សេងដែលទទួលបានប្រាក់ខែខ្ពស់ជាង»។ លោកបន្ថែមថា៖ «យើងមានធនធាន ប៉ុន្តែមិនទាន់ប្រើប្រាស់ធនធានរបស់យើងឲ្យបានល្អ។ យកល្អយើងគួរស្វែងរកយុទ្ធសាស្ត្រផ្សេងក្នុងការប្រើប្រាស់កម្លាំងពលកម្មយើងឲ្យបានកាន់តែច្រើន និងដើម្បីធ្វើឲ្យប្រសើរឡើងជំនាញរបស់ពួកគេ ដើម្បីបង្កើនកំណើនសេដ្ឋកិច្ចកាន់តែធំ»។ ទំហំពិតនៃលំហូរប្រាក់ផ្ញើមកកម្ពុជាពីការធ្វើការនៅក្រៅប្រទេស អាចមានចំនួនច្រើនជាងនេះ ដោយសារពលរដ្ឋចំណាកស្រុកមួយចំនួន ជាពិសេសអ្នកដែលធ្វើការនៅប្រទេស ថៃ និងមានស្រុកកំណើតតាមខេត្តនៅជិតប្រទេសនេះ តែងផ្ញើប្រាក់មកផ្ទះតាមរយៈបណ្តាញក្រៅផ្លូវការ។

មិនមានការស្រាវជ្រាវលម្អិតណាមួយនៅឡើយថា តើប្រាក់ផ្ញើមកផ្ទះពីពលរដ្ឋចំណាកស្រុកត្រូវបានប្រើប្រាស់ដូចម្តេចនៅក្នុងប្រទេស កម្ពុជា។ ប៉ុន្តែមានប្រព័ន្ធព័ត៌មានរាយការណ៍ថា ប្រាក់ដែលផ្ញើមកពីពលករចំណាកស្រុកនៅបរទេស គឺជាប្រភពដ៏សំខាន់មួយនៃមូលធនសម្រាប់គ្រួសារកម្ពុជាដែលទទួលប្រាក់ផ្ញើទាំងនោះ និងអាចត្រូវបានប្រើប្រាស់លើការចាយវាយប្រចាំថ្ងៃ ការវិនិយោគលក្ខណៈគ្រួសារ ឬប្រភពដ៏សំខាន់មួយនៃប្រាក់ចំណូលសម្រាប់ការសងកម្ចី។

យោងតាមទិន្នន័យស្ថាប័នរដ្ឋាភិបាល ប្រជាពលរដ្ឋកម្ពុជាទៅធ្វើការស្របច្បាប់នៅថៃមានជាង ១ លាននាក់ គិតមកត្រឹមដំណាច់ឆ្នាំ ២០១៨ ខណៈនៅប្រទេស កូរ៉េ ត្រូវបានប៉ាន់ស្មានថាអាចមានប្រមាណ ៥៤.០០០ នាក់។ ពលរដ្ឋទៅធ្វើការនៅប្រទេសផ្សេងៗទៀតដូចជា ម៉ាឡេស៊ី ជប៉ុន ជាដើមនៅមានចំនួនតិចតួចនៅឡើយ។ ក្នុងចំណោមគោលដៅការងារក្រៅប្រទេស កូរ៉េខាងត្បូង ត្រូវបានគិតថា ជាគោលដៅមានភាពទាក់ទាញជាងគេដោយសារមានប្រាក់បៀវត្សរ៍ខ្ពស់។

លោក អ៊ឹម តារា ជាកសិករមួយរូបនៅខេត្តកណ្តាល ដែលប្អូនប្រុសរបស់លោកកំពុងធ្វើការងារនៅប្រទេស កូរ៉េខាងត្បូង បានឲ្យដឹងនៅក្នុងបទសម្ភាសតាមទូរស័ព្ទថា ប្រាក់ដែលបានផ្ញើមកផ្ទះរបស់ប្អូនប្រុសរបស់លោក ពីប្រទេស កូរ៉េ បានជួយកែលម្អជីវភាពរស់នៅឪពុកម្តាយរបស់លោក។ លោក តារា ឲ្យដឹងថា ប្អូនប្រុសរបស់លោកទទួលប្រាក់ឈ្នួលប្រហែល ១ ៥០០ ដុល្លារក្នុង ១ ខែ ពីការងាររបស់គេក្នុងវិស័យកសិកម្ម និងតែងតែផ្ញើប្រាក់មកផ្ទះជាញឹកញាប់ ដើម្បីជួយសម្រាប់ការចំណាយមួយចំនួនរបស់ឪពុកម្តាយរបស់លោក។ លោកថ្លែងថា៖ «តាមរយៈទឹកប្រាក់ដែលប្អូនខ្ញុំបានផ្ញើមកផ្ទះ ឪពុកម្តាយខ្ញុំអាចសាងសង់ផ្ទះថ្មីមួយ និងអាចចាយវាយប្រចាំថ្ងៃបានស្រួលជាងមុន»។ លោកបន្ថែមថា ការមានប្អូនប្រុសធ្វើការងារនៅបរទេស បានជួយកាត់បន្ថយហានិភ័យគ្រួសារ និងមានភាពប្រសើរជាងឆ្ងាយ ជាជាងមានសមាជិកគ្រួសារទាំងអស់ បន្តពឹងផ្អែកលើការធ្វើស្រែចម្ការនៅក្នុងប្រទេស។ លោកបញ្ជាក់ថា៖ «ប្អូនខ្ញុំ អាចសន្សំប្រាក់មួយចំនួនមកពីការងារ ហើយគិតថាអាចមានគ្រួសារល្អនឹងគេនៅពេលគាត់ត្រឡប់មកវិញ»។LA